ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ផែនការប្រើប្រាស់ដី នៅក្នុងឃុំ សំព្រោជ
ស្រុកស្ទោង ខេត្តកំពង់ធំ
ឆ្នាំ២០១៧ ដល់ ២០៣២



រៀបចំដោយ : ក្រុមហ៊ុនផ្តល់សេវាកម្ម SBK R&D

សម្របសម្រួលដោយ : ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីស្រុកស្ទោង

គាំទ្របច្ចេកទេសដោយ : អង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ (NIO-MLMUPC) និងថ្នាក់ខេត្ត (PIO)

ឧបត្ថម្ភថវិកាដោយ : រាជរដ្ឋាភិបាលកម្ពុជា (RGC), ADB_Loan, GAFSP_Grant និងSCF_ADB

មាតិកា

អារម្ភកថា VII

សេចក្តីផ្តើម 1

ជំពូក ១៖ ព័ត៌មានស្តីពីស្ថានភាពឃុំសំព្រោជ 3

១.១. ស្ថានភាពឃុំ 3

១.១.១.ទីតាំងរដ្ឋបាលឃុំ 3

១.១.២. ប្រជាសាស្ត្រ 6

ក. ចំនួនប្រជាជន 6

ខ. អត្រាកំណើន ដង់ស៊ីតេ និងរបាយប្រជាជន 8

គ. ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់ 8

ឃ. របររកទទួលទាន 9

ង. ចំណូលស្រុក និងចំណាកស្រុក 10

១.១.៣.ស្ថានភាពសេដ្ឋកិច្ច 12

ក. ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ 12

ខ. កម្រិតជីវភាពរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ 12

គ. ស្ថានភាពបំណុលសរុប និងអត្រាការប្រាក់ 13

ឃ. ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬក្រោមរូបភាពផ្សេងៗ 14

ង. ចំណូលពីប្រភពផ្សេងៗ 14

១.១.៤.ស្ថានភាពអប់រំ និងសិក្សាធិការ 14

ក. ស្ថានភាពអប់រំ 14

ខ. ស្ថានភាពអក្ខរកម្ម 15

គ. ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត 16

១.១.៥.ស្ថានភាពសុខាភិបាល 17

១.១.៦. ស្ថានភាពយេនឌ័រ 20

១.២.ស្ថានភាពភូមិសាស្ត្រ 22

១.២.១. ទីតាំងភូមិសាស្ត្រ 22

១.២.២.អាកាសធាតុ (ពិពណ៌នាតាមរដូវកាល) 32

១.២.៣.ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន 33

១.២.៤.បរិក្ខាសាធារណ: 35

ក. ស្ថានភាពប្រើប្រាស់អគ្គិសនី 35
ខ. ប្រព័ន្ធទឹកស្អាត 35
១.៣. ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន 36
១.៣.១. ស្ថានភាពការកាន់កាប់ និងគ្រប់គ្រង 36
ក. ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ 38
ខ. ដីកសិកម្ម 39
ខ.១. ដីស្រែវស្សា៖ 39
ខ.២. ដីស្រែប្រាំង៖ 41
ខ.៣. ដីស្រែប្រាំង និងស្រែវស្សា៖ 42
គ. ព្រៃលិចទឹក៖ 43
ឃ. ផ្ទៃទឹក និងខ្សែទឹក 44
១.៣.២ .ផលិតកម្មកសិកម្ម 47
ក. ផលិតកម្មដំណាំស្បៀង 47
ខ. ផលិតកម្មដំណាំរួមផ្សំ 48
គ. ផលិតកម្មខ្វស្សាហកម្ម 48
១.៣.៣. ធនធានធម្មជាតិ 48
ក. ធនធានព្រៃឈើ 48
ខ. ធនធានជលផល 49
១.៣.៤. ធនធានដី 50
១.៤. ទីផ្សារ និងខ្សែសង្វាក់ផលិតផល 50
១.៤.១. ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ 50
១.៤.២. ខ្សែសង្វាក់ និងចរាចរផលិតផល 51
១.៤.៣. ឧបសគ្គ និងឱកាស 53
ជំពូក ២៖ ការវិភាគ តម្រូវការ សក្តានុពល និងឧបសគ្គសម្រាប់អនាគត 54
២.១. តម្រូវការសម្រាប់អនាគត 54
២.១.១.ផែនការអភិវឌ្ឍន៍ឃុំ 54
ក. ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ(២០១៨-២០២២) 54
ខ. គម្រោងអភិវឌ្ឍន៍ផ្សេងៗទៀត ដែលបានអនុម័តរួច 57
២.១.២.ចំណោលប្រជាសាស្ត្រគិតទៅដល់ឆ្នាំ២០៣២ 59

២.១.៣. តម្រូវការដីធ្លីជាមូលដ្ឋាន 60
ក. ដីលំនៅឋាន 60
ខ. ដីកសិកម្ម 61
គ. ដីព្រៃឈើ 62
ឃ. ធនធានទឹក 62
ង. ហេដ្ឋារចនាសម្ព័ន្ធ និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត 63
ង.១. វិស័យអប់រំ 63
ង.២. វិស័យសុខាភិបាល 65
ង.៣. អគ្គិសនី 65
ង.៤. ទីលានចាក់សំរាម 65
ង.៥. ដីកប់ខ្មោច 66
ង.៦. ស្រះ និងអណ្តូងទឹក 66
២.២. តំបន់រសើប 67
២.៣.ការប្រឈម 69
២.៣.១.ការប្រឈមដោយធម្មជាតិ 69
ក. កំណើនប្រជាជន 69
ខ. គ្រោះធម្មជាតិ ការរេចរឹល នៃធម្មជាតិ 69
២.៣.២. ការប្រឈមដោយ ការអភិវឌ្ឍន៍ដែលពុំមាននិរន្តរភាព 69
២.៤. ឱកាស 70
២.៤.១.ដោយអំណោយផលពីធម្មជាតិ 70
២.៤.២.ដោយបច្ចេកវិទ្យាថ្មីៗ 70
២.៤.៣.ដោយគម្រោងវិនិយោគ 71
២.៥. បញ្ហា មូលហេតុ និងដំណោះស្រាយ 71
ជំពូក ៣៖ ផែនការប្រើប្រាស់ដីពេលអនាគតឆ្នាំ២០១៧-២០៣២ 74
៣.១.តម្រូវការ ស្ថានភាព និងសក្តានុពលដីជាក់ស្តែង 74
៣.១.១.តម្រូវការដីទៅតាមប្រភេទ 74
៣.១.២.ស្ថានភាពនៃដីធ្លី និងសក្តានុពល 74
៣.២.ការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់ 75
៣.២.១.ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ 75

៣.២.២.ផែនទីប្រើប្រាស់ដីអនាគត 77
៣.២.៣.សេចក្តីអត្ថាធិប្បាយអំពីការប្រើប្រាស់ដីនាពេលអនាគត 79
ក. ដីលំនៅឋាន តួមិះ 79
ខ. ដីស្រែវស្សាះ 79
គ. ដីស្រែប្រាំងះ 80
ឃ. ដីស្រែប្រាំង និងស្រែវស្សាះ 81
ង. ព្រៃពុម្ពោតះ 82
ច. ព្រៃលិចទឹក 82
ឆ. ទន្លេមានទឹកជាអចិន្ត្រៃយ៍ 82
ជ. ស្ទឹងមានទឹកតាមរដូវ 83
ឈ. ស្រះទឹក 83
ញ. បឹង 83
ដ. អាងស្តុកទឹក 83
៣.៣.ដំណោះស្រាយផ្សេងៗ ក្នុងករណីខ្វះខាតដីធ្លី 84
៣.៤. កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព 84
៣.៤.១.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព 84
ក. ការគ្រប់គ្រងប្រព័ន្ធកសិកម្ម 84
ខ. ការគ្រប់គ្រងព្រៃឈើ ជលផល និង ធនធានសំខាន់ៗផ្សេងៗទៀត 86
៣.៤.២. គម្រោងគាំទ្រចាំបាច់ សម្រាប់គាំទ្រនិរន្តរភាព 86
៣.៥. សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់២០៣២) 87

បញ្ជីតារាង

តារាង 1៖ ស្ថានភាពទូទៅនៃឃុំ 3
តារាង 2៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្តាភូមិ 6
តារាង 3៖ ស្ថិតិប្រជាជន ឆ្នាំ២០១៧ តាមក្រុមអាយុ 7
តារាង 4៖ ស្ថិតិប្រជាជនតាមបណ្តាឆ្នាំ និងការគណនាអត្រាកំណើនមធ្យម 8
តារាង 5៖ តារាងមុខរបរ 9
តារាង 6៖ មុខរបរបន្ទាប់បន្សំ 10
តារាង 7៖ ស្ថិតិប្រជាជនផ្លាស់ប្តូរទីលំនៅក្នុងឆ្នាំ២០១៦-២០១៧ 11
តារាង 8៖ ស្ថិតិប្រជាជនចំណាកស្រុក 11
តារាង 9៖ តារាងកម្រិតជីវភាពរបស់ប្រជាជន 12

តារាង 10៖ ស្ថិតិសាលារៀន ស្ថានភាពអប់រំ និងសិក្សាធិការក្នុងឃុំឆ្នាំ២០១៧ 15
តារាង 11៖ ស្ថិតិអ្នកមិនចេះអក្សរ 16
តារាង 12៖ ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត 17
តារាង 13៖ សុខភាពមាតានិងទារក 18
តារាង 14៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព 19
តារាង 15៖ ការវិភាគលើតួនាទីយេនឌ័រ ឃុំសំព្រោជ 20
តារាង 16៖ ដ្យាក្រាមពំនុះកាត់ទទឹងឃុំសំព្រោជ ស្រុកស្ទោង 31
តារាង 17៖ ប្រព័ន្ធធារាសាស្ត្រ 34
តារាង 18៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ 32
តារាង 19៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន 33
តារាង 20៖ ស្ថិតិអ្នកប្រើប្រាស់អគ្គិសនី 35
តារាង 21៖ ស្ថិតិប្រភពទឹកប្រើប្រាស់ 35
តារាង 22៖ តារាងរាយលម្អិតតាមប្រភេទនៃការប្រើប្រាស់ដីបច្ចុប្បន្ន ឃុំសំព្រោជ 38
តារាង 23៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស 47
តារាង 24៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស 48
តារាង 25៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស 49
តារាង 26៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស 49
តារាង 27៖ ស្ថិតិផលិតផលស្រូវ និងតម្លៃ 50
តារាង 28៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ទីផ្សារនិងខ្សែសង្វាក់ផលិតផល 53
តារាង 29៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ និងជម្រើសនៃការប្រាស់ដីធ្លីអនាគត 54
តារាង 30៖ ចំណោលប្រជាសាស្ត្រនៃចំនួនគ្រួសារ និងប្រជាជនសរុប (០៥ឆ្នាំ) 59
តារាង 31៖ ចំណោលប្រជាសាស្ត្រតាមក្រុមអាយុ (០៥ឆ្នាំ) 60
តារាង 32៖ តម្រូវការដីសម្រាប់លំនៅឋានក្នុងឆ្នាំ២០៣២ 61
តារាង 33៖ តម្រូវការដីសម្រាប់កសិកម្មក្នុងឆ្នាំ២០៣២ 62
តារាង 34៖ កំណើនកុមារ តម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១៨ ដល់ឆ្នាំ ២០៣២ 64
តារាង 35៖ បញ្ហាប្រឈម និងសក្តានុពល(ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ) 71
តារាង 36៖ តារាងប្រើប្រាស់ដីនាពេលអនាគតឃុំសំព្រោជ 76
តារាង 37៖ តារាងផែនការផ្អែកហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត 76
តារាង 38៖ តារាងផែនការផ្អែកសេវាកម្មនាពេលអនាគត 77

បញ្ជីដ្យាក្រាម

ដ្យាក្រាម 1៖ ស្ថិតិប្រជាជនឆ្នាំ២០១៧ 7
ដ្យាក្រាម 2៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព 20
ដ្យាក្រាម 3៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ 32
ដ្យាក្រាម 4៖ គំនូសតាងនៃការលំហូផលិតផលកសិកម្ម នៅក្នុងភូមិ និង ការប្រើប្រាស់ 52

បញ្ជីផែនទី

ផែនទី 1៖ ផែនទីទីតាំងព្រំប្រទល់រដ្ឋបាលស្រុកស្ទោង 4
ផែនទី 2៖ ផែនទីព្រំប្រទល់រដ្ឋបាលឃុំសំព្រោជ 5
ផែនទី 3៖ ផែនទីសណ្ឋានដីឃុំសំព្រោជ 23
ផែនទី 4៖ ផែនទីតំបន់ក្សេត្រ-បរិស្ថាន ឃុំសំព្រោជ 24
ផែនទី 5៖ ផែនទីប្រព័ន្ធធារាសាស្ត្រ ឃុំសំព្រោជ 37
ផែនទី 6៖ ផែនទីហេដ្ឋារចនាសម្ព័ន្ធ ឃុំសំព្រោជ 34
ផែនទី 7 ៖ ផែនទីប្រើប្រាស់ដីសាមញ្ញ ឃុំសំព្រោជ 36
ផែនទី 8៖ ផែនទីប្រើប្រាស់ដីលម្អិត ឃុំសំព្រោជ 37
ផែនទី 9៖ ផែនទីគម្រោងជាអាទិភាព ឃុំសំព្រោជ 58
ផែនទី 10៖ ផែនទីតំបន់រសើប ឃុំសំព្រោជ 68
ផែនទី 11៖ ផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ 73
ផែនទី 12៖ ផែនទីប្រើប្រាស់ដីពេលអនាគតឃុំសំព្រោជ 78

បញ្ជីរូបភាព

រូបភាព 1៖ សាលារៀន 15
រូបភាព 2៖ មណ្ឌលសុខភាព ឃុំសំព្រោជ 19
រូបភាព 3៖ ប្រព័ន្ធធារាសាស្ត្រ 36
រូបភាព 4៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន 33
រូបភាព 5៖ លំនៅឋានភូមិ 39
រូបភាព 6៖ ដីស្រែវស្សា 40
រូបភាព 7៖ ស្រែប្រាំង 41
រូបភាព 8៖ ស្រូវប្រាំង និងស្រូវវស្សា 43
រូបភាព 9៖ ព្រៃគុម្ពោត 43
រូបភាព 10៖ ព្រៃលិចទឹក 44
រូបភាព 11៖ ទន្លេមានទឹកជាអចិន្ត្រៃយ៍ 44
រូបភាព 12៖ ស្ទឹងមានទឹកតាមរដូវ 45
រូបភាព 13៖ ស្រះទឹក 45
រូបភាព 14៖ បឹង 46
រូបភាព 15៖ អាងស្តុកទឹក 46
រូបភាព 16៖ ផលនេសាទ 50
រូបភាព 17៖ ផលិតផលកសិកម្ម 51

អារម្ភកថា

ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ គឺជាឧបករណ៍មួយដ៏សំខាន់ក្នុងការជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ផ្ទាល់ ក៏ដូចជាដល់អ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងសមធម៌ ជាពិសេសការគ្រប់គ្រងនិងប្រើប្រាស់ដី ដែលជាកត្តាស្នូលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងលើកស្ទួយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ដូច្នេះក្រោយពេលមានផែនការប្រើប្រាស់ដីនេះអាជ្ញាធរគ្រប់ផ្នែកនៅថ្នាក់ក្រោមជាតិ ជាពិសេសអាជ្ញាធរដែនដី នឹងមានមូលដ្ឋានកាន់តែគ្រប់ជ្រុងជ្រោយ ក្នុងការរៀបចំបញ្ចូលផែនការប្រើប្រាស់នៅក្នុងឃុំ/សង្កាត់នេះទៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយធ្វើសមាហរណកម្មផែនការនៅថ្នាក់ស្រុក និងការអនុម័តនៅថ្នាក់រាជធានី/ខេត្ត តាមនីតិវិធីដូចដែលធ្លាប់អនុវត្តក្នុងការកសាង ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច កន្លងមក ដោយមានគ្រប់ភាគីពាក់ព័ន្ធចូលរួមធ្វើការសម្រេច។ ក្នុងទឹកចិត្តសោមនស្សរីករាយជាអនេក ខ្ញុំមានកិត្តិយសសូមបង្ហាញនូវរបាយការណ៍បច្ចេកទេសស្តីពីផែនការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជមានចក្ខុវិស័យរហូតដល់ឆ្នាំ ២០៣២ ដែលក្រុមការងារបានប្រឹងប្រែងសិក្សាស្រាវជ្រាវ និងរៀបចំឡើងអស់រយៈពេលជាងពីរឆ្នាំកន្លងមកនេះ ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងកម្មវិធីកសិកម្មនិងសន្តិសុខស្បៀងពិភពលោក (GAFSP) ដែលបានគាំទ្រឧបត្ថម្ភថវិកា ក្រុមហ៊ុនផ្តល់សេវាកម្មមកជួយសិក្សារៀបចំផែនការនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលបានទទួលគ្រប់គ្រងគម្រោងនិងគាំទ្របច្ចេកទេស រដ្ឋបាលខេត្តកំពង់ធំ និងរដ្ឋបាលស្រុកស្ទោង ដែលបានសម្របសម្រួលដល់កិច្ចដំណើរការរបស់គម្រោង និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមនៅក្នុងដំណើរការរៀបចំផែនការប្រើប្រាស់ដី នៅក្នុងឃុំសំព្រោជនេះ ។

ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ផែនការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជនេះ នឹងបានចូលរួមចំណែកដល់ការអភិវឌ្ឍន៍ឃុំប្រកបដោយចីរភាព ថែមទាំងត្រូវបានប្រើប្រាស់ដោយមានការចូលរួម និងគាំទ្រយ៉ាងពេញទំហឹងពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ៕

ថ្ងៃ ចន្ទ ១៤កើត ខែស្រាពណ៍ឆ្នាំ ជូតទោស័ក ព.ស. ២៥៦៤

សំព្រោជ ថ្ងៃទី...០៣...ខែ...សីហា...ឆ្នាំ២០២០

ប្រធានក្រុមប្រឹក្សាឃុំ

ពាញ ភួង

សេចក្ដីផ្ដើម

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញនិងច្បាប់រាជរដ្ឋាភិបាលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា ។ រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់គុណភាពសេវាសាធារណៈ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ។

ផ្អែកតាមយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយ**គតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជាសំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍ តាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាន ឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ ។ ឃុំសំព្រោជជាឃុំមួយក្នុងចំណោមឃុំចំនួន១៣ ស្ថិតក្នុងស្រុកស្ទោង ខេត្តកំពង់ធំ គឺជាតំបន់ជនបទ មានផ្ទៃដីសរុបចំនួន ២២ ៣៧៤ ហិកតា មានព្រំប្រទល់ខាងជើងជាប់នឹង ឃុំកំពង់ចិនត្បូង ឃុំទ្រា និងឃុំបន្ទាយស្ទោង ស្រុកស្ទោង ខាងត្បូងជាប់នឹងទន្លេសាប ឃុំពាមបាង ស្រុកស្ទោង និងឃុំផាត់សណ្តាយ ស្រុកកំពង់ស្វាយ ខាងកើតជាប់នឹង ឃុំចំណាក្រោម ស្រុកស្ទោង ខាងលិចជាប់នឹងឃុំម្សាក្រង ស្រុកស្ទោង ។ មានគ្រួសារសរុបចំនួន ២ ៨០៨គ្រួសារ មានប្រជាជនសរុប ១៣ ៦២៩នាក់ ក្នុងនោះស្រ្តី ៦ ៨៦៥នាក់ ហើយមានប្រជាពលរដ្ឋ ៨៦,៨%ជាកសិករ។ ឃុំសំព្រោជមានផ្ទៃដីស្រែសរុបទំហំ ៩ ៧៣៧,១២ហិកតា គឺជាផ្ទៃដីដែលមានទំហំធំទូលាយមានវិសាលភាពស្រូបអស់ ៤៣,៦%នៃផ្ទៃដីសរុបរបស់ឃុំ ដែលជាបង្អែកដ៏មានសក្តានុពលតែមួយគត់ សម្រាប់ការអភិវឌ្ឍន៍ឃុំសំព្រោជប្រកបដោយចីរភាព ។

ក្នុងគោលដៅធានាការគ្រប់គ្រងនិងអភិវឌ្ឍឃុំសំព្រោជ ប្រកបដោយចីរភាពនេះ គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ និងស្រុកស្ទោង ព្រមទាំងក្រុមប្រឹក្សាឃុំសំព្រោជ ក្រោមការទទួលសិទ្ធិផ្តល់សេវាកម្មរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជដោយក្រុមហ៊ុន SBK Co.LTd និងមានការគ្រប់គ្រងគាំទ្របច្ចេកទេសដោយអង្គភាពអនុវត្តគម្រោងថ្នាក់ខេត្ត (PIO) និងអង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ (NIO)នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងមានការគាំទ្រនិងឧបត្ថម្ភថវិកាពីរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី បានរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជ ចក្ខុវិស័យឆ្នាំ២០៣២ សម្រាប់តម្រង់ទិសដល់ការអភិវឌ្ឍន៍ឃុំពាក់ព័ន្ធការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជ ឆ្លើយតបទៅនឹងកំណើនប្រជាសាស្ត្រ ដើម្បីជាមូលដ្ឋានជួយដល់ក្រុមប្រឹក្សាឃុំសំព្រោជផ្ទាល់ ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងសមធម៌ ដែលក្នុងនោះមានការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដែលជាកត្តាស្នូលនៃការអភិវឌ្ឍន៍ឃុំ ធ្វើឱ្យជីវភាពប្រជាពលរដ្ឋមានភាពប្រសើរឡើងរួចផុតពីភាពក្រីក្រ ជាពិសេសប្រើប្រាស់ដីកសិកម្មនៅក្នុងឃុំសំព្រោជ ឱ្យអស់សក្តានុពលដែលមាន ក្នុងការផលិតស្រូវ ដើម្បីបង្កើនការនាំចេញអង្ករឱ្យបានច្រើននៅពេលខាងមុខ ឆ្លើយតបបានទៅនឹងគោលនយោបាយ ស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្កររបស់រាជរដ្ឋាភិបាល ដែលនៅសល់ពីការហូបចុក តាមរយៈការប្រើប្រាស់ផែនការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជនេះ ធ្វើជាមូលដ្ឋានបង្អែកសម្រាប់រៀបចំផែនការអភិវឌ្ឍឃុំនៅតាមអាណត្តិនីមួយៗរបស់ខ្លួន ។

ផែនការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជ ត្រូវបានរៀបចំឡើងដោយមានការសិក្សាស្រាវជ្រាវច្បាស់លាស់លើកត្តាភូមិសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន ព្រមទាំងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដី និងនគរូបនីយកម្មនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិមានជាអាទិ៍ ដូចជា ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារ បរិស្ថាននិងធនធានធម្មជាតិច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយ-កម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ និងអនុក្រឹត្យស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន ។ ចំពោះនីតិវិធីនៃការរៀបចំផែនការនេះវិញត្រូវបានរៀបចំឡើងដោយផ្អែកលើអនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ព្រមទាំងប្រកាសរួមស្តីពីនីតិវិធីលម្អិត សម្រាប់ការរៀបចំ និងអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ និង ឯកសារណែនាំអនុវត្តស្តីពីការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ ដែលមានដំណើរការរៀបចំផែនការដូចមានសង្ខេបក្នុងដ្យាក្រាមខាងក្រោម ។

ដ្យាក្រាម៖ ដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់



ជំពូក ១៖ ព័ត៌មានស្តីពីស្ថានភាពឃុំសំព្រោជ

១.១. ស្ថានភាពឃុំ

មានតំណាលតៗគ្នាថាពាក្យសំព្រោជគឺជាពាក្យដែលកំឡាយមកពីពាក្យសៀមប្រួច(សៀមដាក់មេប្រួច) ដោយកាលនោះ ប្រទេសសៀមធ្វើការគ្រប់គ្រង ខេត្តបាត់ដំបង ខេត្តស្វាយស៊ីសុផុន និងខេត្តសៀមរាប ពួកកងទ័ពសៀមបានធ្វើសង្គ្រាម និងចូលចាប់កូនក្រមុំអ្នកស្រុកនៅក្នុងតំបន់នោះ តែមិនបានសម្រេចដូចបំណងឡើយ ដោយសារប្រជាពលរដ្ឋខ្មែរយើងនៅតំបន់នោះភាគច្រើនចេះវិជ្ជាគុនការពារខ្លួនដូចជា៖ ល្បុក្កតោ គុនដាវ និងគុនដំបងជាដើម បានធ្វើការច្បាំងតទល់នឹងកងទ័ពសៀមរហូតទទួលបានជោគជ័យ ធ្វើឱ្យពួកចោរសៀមទាំងនោះរត់យកតែអាយុរៀងៗខ្លួនទៅ ហើយប្រជាពលរដ្ឋបានហៅទីកន្លែងនោះថាភូមិ **"សៀមប្រួច"** ក្រោយមកក៏បានប្តូរទៅជា **"ភូមិសំព្រោជ"** រហូតមកដល់សម័យសង្គមរាស្ត្រនិយម បានដាក់ឈ្មោះតំបន់នោះទៅជា **"ឃុំសំព្រោជ"** វិញ រហូតដល់សព្វថ្ងៃនេះ តាមប្រកាសលេខ៤៩៣ប្រ.ក/ ចុះថ្ងៃទី៣០-មេសា-២០០១ ។

១.១.១.ទីតាំងរដ្ឋបាលឃុំ

ឃុំសំព្រោជ គឺជាឃុំមួយដែលស្ថិតនៅភាគខាងត្បូងទីរួមស្រុក និងមានចម្ងាយប្រហែល០៧គីឡូម៉ែត្រពីរួមស្រុក ហើយស្ថិតនៅក្រោមការគ្រប់គ្រង របស់រដ្ឋបាលស្រុកស្ទោង ខេត្តកំពង់ធំ ហើយមានផ្ទៃដីសរុបចំនួន ២២ ៣៧៤ហិកតា (ប្រភពទិន្នន័យ៖ ក្រុមការងារបច្ចេកទេស GIS អេស ប៊ី ខេ) មានព្រំប្រទល់ជាប់នឹង៖

- ខាងជើង ជាប់នឹង ឃុំកំពង់ចិនត្បូង ឃុំទ្រា និងឃុំបន្ទាយស្ទោង ស្រុកស្ទោង
- ខាងត្បូង ជាប់នឹង បឹងទន្លេសាប ឃុំពាមបាង ស្រុកស្ទោង និងផាត់សណ្តាយ ស្រុកកំពង់ស្វាយ
- ខាងកើត ជាប់នឹង ឃុំចំណាក្រោម ស្រុកស្ទោង
- ខាងលិច ជាប់នឹង ឃុំម្សាក្រង ស្រុកស្ទោង (ភ្ជាប់ជាមួយផែនទីរដ្ឋបាលឃុំ)។

ឃុំនេះមានចំនួន១៧ភូមិ គឺមានភូមិក្រសាំងជ្រុំត្បូង ភូមិក្រសាំងជ្រុំជើង ភូមិត្នោតគម ភូមិសំព្រោជ ភូមិគោកស្នាយ ភូមិពៃ ភូមិចំបក់ខ្ពស់ ភូមិត្រាចជ្រុំ ភូមិស្រះពន្លក ភូមិអំពិល ភូមិមឈាយ ភូមិដូនល្អ ភូមិប្រដិត ភូមិល្វា ភូមិអូររំចេក ភូមិអំពៅព្រៃ ភូមិស្លាក់ក្រាញ់ ។

តារាង 1៖ ស្ថានភាពទូទៅនៃឃុំ

ខេត្ត	កំពង់ធំ	លេខកូដខេត្ត:៦
ស្រុក	ស្ទោង	លេខកូដស្រុក: ៦០៨
ឃុំ	សំព្រោជ	លេខកូដឃុំ: ៦០៨១២
ចំនួន១៧ភូមិ	១. ភូមិក្រសាំងជ្រុំត្បូង	លេខកូដភូមិ: ៦០៨១២០១
	២. ភូមិក្រសាំងជ្រុំជើង	លេខកូដភូមិ: ៦០៨១២០២
	៣. ភូមិត្នោតគម	លេខកូដភូមិ: ៦០៨១២០៣
	៤. ភូមិសំព្រោជ	លេខកូដភូមិ: ៦០៨១២០៤
	៥. ភូមិគោកស្នាយ	លេខកូដភូមិ: ៦០៨១២០៥

	៦. ភូមិពៃ	លេខកូដភូមិៈ ៦០៨១២០៦
	៧. ភូមិចំបក់ខ្ពស់	លេខកូដភូមិៈ ៦០៨១២០៧
	៨. ភូមិត្រាចជ្រុំ	លេខកូដភូមិៈ ៦០៨១២០៨
	៩. ភូមិស្រះពត្លក	លេខកូដភូមិៈ ៦០៨១២០៩
	១០. ភូមិអំពិល	លេខកូដភូមិៈ ៦០៨១២១០
	១១. ភូមិមឈាយ	លេខកូដភូមិៈ ៦០៨១២១១
	១២. ភូមិដូនល្អ	លេខកូដភូមិៈ ៦០៨១២១២
	១៣. ភូមិប្រដិត	លេខកូដភូមិៈ ៦០៨១២១៣
	១៤. ភូមិល្វា	លេខកូដភូមិៈ ៦០៨១២១៤
	១៥. ភូមិអូររំចេក	លេខកូដភូមិៈ ៦០៨១២១៥
	១៦. ភូមិអំពៅព្រៃ	លេខកូដភូមិៈ ៦០៨១២១៦
	១៧. ភូមិស្លាក់ក្រាញ់	លេខកូដភូមិៈ ៦០៨១២១៧

ប្រភពទិន្នន័យៈ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨*

ផែនទី 1៖ ផែនទីទីតាំងព្រំប្រទល់រដ្ឋបាលស្រុកស្ទោង



ផែនទី 2៖ ផែនទីព្រំប្រទល់រដ្ឋបាលឃុំសំព្រោជ



១.១.២. ប្រជាសាស្ត្រ

ក. ចំនួនប្រជាជន

នៅក្នុងឃុំសំព្រោជ ត្រូវបានចែកចេញជា១៧ភូមិ ដែលមានគ្រួសារសរុបចំនួន ២ ៨០៨គ្រួសារ និងមានប្រជាជនសរុប១៣ ៦២៩នាក់ ក្នុងនោះស្ត្រី៦ ៨៦៥នាក់ ។ ក្នុងនោះប្រជាជនដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងមានចំនួន៧ ៧៧១នាក់ ជាស្ត្រីភេទចំនួន ៣ ៩៣៨នាក់ ។ ដោយឡែកនៅឃុំសំព្រោជភូមិដែលមានប្រជាជនច្រើនជាងគេ គឺភូមិដូនល្អ ដែលមានគ្រួសារសរុបចំនួន ៣២៧គ្រួសារ ស្មើនឹង១១,៦ភាគរយ ប្រជានជនសរុបចំនួន១ ៧៥២នាក់ ក្នុងនោះស្ត្រីមានចំនួន៨៩៣នាក់ ។ ប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅមានចំនួន៦៨៦នាក់ ក្នុងនោះស្ត្រីមានចំនួន៣៣៤នាក់ ។ ចំណែកភូមិដែលមានប្រជាជនតិចជាងគេ គឺភូមិសំព្រោជដែលមានប្រជាជនចំនួន៥៦គ្រួសារ ស្មើងនឹង៤,២ភាគរយ ប្រជាជនសរុបចំនួន៣១០នាក់ នៅក្នុងនោះស្ត្រីមានចំនួន១៦៥នាក់ ។ ប្រជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅមានចំនួន១៤២នាក់ ក្នុងនោះស្ត្រីមានចំនួន៧១នាក់ ។ ទន្ទឹមនេះ ក៏សង្កេត និងកត់សម្គាល់ឃើញថា ស្ថិតិប្រជាពលរដ្ឋនៅក្នុងឃុំ គឺស្ត្រីមានចំនួនច្រើនជាងបុរស ដូចមានក្នុងតារាងសង្ខេបខាងក្រោម ។

តារាង 2៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្តាភូមិ

ឈ្មោះភូមិ	គ្រួសារ	គិតជា%	មនុស្ស			១៨ឆ្នាំឡើង		
			សរុប	ប្រុស	ស្រី	សរុប	ប្រុស	ស្រី
ក្រសាំងជ្រុំត្បូង	១២៦	៤,៥	៧១៥	៣៧៧	៣៣៨	៤៤៨	២០៦	២៤២
ក្រសាំងជ្រុំជើង	១៨៨	៦,៧	៩១៤	៤៤៩	៤៦៥	៤៩៦	២៣៤	២៦២
ត្នោតគម	៧២	២,៦	៤៨០	២៣១	២៤៩	២៣៩	១២០	១១៩
សំព្រោជ	៥៦	២,០	៣១០	១៤៥	១៦៥	១៤២	៧១	៧១
គោកស្វាយ	១១៩	៤,២	៦៨៣	៣៤១	៣៤២	៤០៧	១៩៦	២១១
ពៃ	១៤៩	៥,៣	៦៣៩	៣១៩	៣២០	៣៨៣	២០១	១៨២
ចំបក់ខ្ពស់	១៦៩	៦,០	៧០៦	៣៣៧	៣៦៩	៤៤៩	២១៦	២៣៣
ត្រាចជ្រុំ	២២៨	៨,១	១១៥០	៥៦៨	៥៨២	៧៦៨	៣៩៥	៣៧៣
ស្រះពន្លក	១៥២	៥,៤	៧០៣	៣៦៥	៣៣៨	៣៥៩	១៨៧	១៧២
អំពិល	១៦៨	៨,១	៨៥៨	៤២៥	៤៣៣	៥២៨	២៦៣	២៦៥
មឈាយ	១៥១	៥,៤	៦៩៩	៣៤៥	៣៥៤	៤៥៣	២០៤	២៤៩
ដូនល្អ	៣២៧	១១,៦	១៧៥២	៨៥៩	៨៩៣	៦៨៦	៣៥២	៣៣៤
ប្រដិត	១៤៨	៥,៣	៦៧៩	៣២៩	៣៥០	៣០៥	១៤៥	១៦០
ល្វា	១៥០	៥,៣	៦៨៤	៣៦៦	៣១៨	៣១៩	១៧៧	១៤២
អូររំចេក	២៣២	៨,៣	១០៣៦	៥០៤	៥៣២	៧៨០	៣៧៨	៤០២

អំពៅព្រៃ	១៥៥	៥,៥	៦៧៣	៣៤៤	៣២៩	៤២៥	២១១	២១៤
ស្លាក់ក្រាញ់	២១៨	៧,៨	៩៤៨	៤៦០	៤៨៨	៥៨៤	២៧៧	៣០៧
សរុប	**២ ៨០៨**	**១០០**	**១៣ ៦២៩**	**៦ ៧៦៤**	**៦ ៨៦៥**	**៧ ៧៧១**	**៣ ៨៣៣**	**៣ ៩៣៨**

ប្រភពទិន្នន័យៈ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨

ដ្យាក្រាម 1៖ ស្ថិតិប្រជាជនឆ្នាំ២០១៧



ប្រភពទិន្នន័យៈ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨

បើយោងទៅតាមតារាស្ថិតិប្រជាជនតាមក្រុមអាយុនៅឆ្នាំ២០១៧ ក្នុងឃុំសំព្រោជ បង្ហាញឱ្យឃើញថា ប្រជាជនមានកម្លាំងពលកម្ម ដែលមានអាយុចាប់ពី២៥ឆ្នាំទៅដល់៦១ឆ្នាំ ៦ ០៨៩នាក់ ស្មើប្រហាក់ប្រហែល ៤៥ភាគរយនៃប្រជាជនសរុបក្នុងឃុំ ក្រៅពីនេះមានអាយុពីកើតដល់២៤ឆ្នាំ មានចំនួន ៧ ៥៤០នាក់ ស្មើនឹង ៥៥ ភាគរយនៃប្រជាជនសរុប និងប្រជាជនមានអាយុពី៦០ឆ្នាំឡើងទៅ មានចំនួន ១៣៦០នាក់ ស្មើនឹង១០ភាគរយ ដែលជាវ័យចូលនិវត្តន៍ការងារនៃប្រជាជនក្នុងឃុំទាំងមូល ។ ដូច្នេះសន្និដ្ឋានបានថា នៅក្នុងឃុំសំព្រោជ មាន មនុស្សពេញកម្លាំងពលកម្មមួយនាក់ ដែលរកចំណូលបានគិតជាមធ្យមត្រូវចិញ្ចឹមមនុស្សជិតពីរនាក់បន្ថែម ។

តារាង 3៖ ស្ថិតិប្រជាជន ឆ្នាំ២០១៧ តាមក្រុមអាយុ

តាមក្រុមអាយុ	**២០១៧**			**ផ្សេងៗ**
	សរុប	**ប្រុស**	**ស្រី**	
អាយុពី០-២ឆ្នាំ	៧៦០	៤១៤	៣៤៦	កុមារ
អាយុពី៣-៤	៧០០	៣៦៤	៣៣៦	អាយុចូលរៀនសាលាមត្តេយ្យ
អាយុពី៥ឆ្នាំ	៥៥៩	២៧៣	២៨៦	អាយុចូលរៀនសាលាមត្តេយ្យ
អាយុពី៦ឆ្នាំ	៦១០	៣០៦	៣០៤	អាយុចូលរៀនសាលាបឋម
អាយុពី៧-១១ឆ្នាំ	១ ១៩៦	៥៩០	៦០៦	អាយុចូលរៀនសាលាបឋម
អាយុពី១២-១៤ឆ្នាំ	៩៨១	៤៥៤	៥២៧	អាយុចូលរៀនអនុវិទ្យាល័យ
អាយុពី១៥-១៧ឆ្នាំ	១ ០៥២	៥៣០	៥២២	អាយុចូលរៀនវិទ្យាល័យ
អាយុពី១៨-២៤ឆ្នាំ	១ ៦៨២	៨២៥	៨៥៧	អាយុចូលរៀនមហាវិទ្យាល័យ

អាយុពី២៥-៣៥ឆ្នាំ	១ ៦៦៩	៨៦៦	៨០៣	អាយុពេញពលកម្ម
អាយុពី៣៦-៤៥ឆ្នាំ	១ ៤៧៣	៧០៤	៧៦៩	អាយុពេញពលកម្ម
អាយុពី៤៦-៦០ឆ្នាំ	១ ៥៨៧	៧៦៧	៨២០	អាយុពេញពលកម្ម
អាយុពី៦១ឆ្នាំឡើង	១ ៣៦០	៦៧១	៦៨៩	អាយុចូលនិវត្តន៍
សរុប	**១៣ ៦២៩**	**៦ ៧៦៤**	**៦ ៨៦៥**	

ប្រភពទិន្នន័យៈ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨

ខ. អត្រាកំណើន ដង់ស៊ីតេ និងរបាយប្រជាជន

ដោយយោងតាមប្រភពទិន្នន័យ ឆ្នាំ២០១៧ បានឱ្យដឹងថា អត្រាកំណើនប្រជាជនជាមធ្យមក្នុងអំឡុងពេលចន្លោះពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៧ មានចំនួន -០,៨២ភាគរយ ដោយសង្កេតឃើញមានការធ្លាក់ចុះខ្លាំងនៅឆ្នាំ២០១៤មានអត្រាកំណើនប្រជាជនចំនួន -៧,០៥ភាគរយ ដែលការធ្លាក់ចុះនេះដោយសារមានការផ្លាស់ប្តូរលំនៅឋានចេញ ចំណាកស្រុក ការពន្យាកំណើត មរណភាពកុមារ និងដោយកត្តាគ្រោះថ្នាក់ចរាចរណ៍ ជម្ងឺ។ល។ ប៉ុន្តែអត្រាកំណើននេះមានកើនឡើងខ្លាំងជាងគេនៅឆ្នាំ ២០១៦ ដែលមានអត្រាកំណើនប្រជាជនមានចំនួន ៤,០១ភាគរយ ដែលការកើនឡើងនេះដោយសារមានការផ្លាស់ប្តូរទីលំនៅចូលតាមរយៈអាពាហ៍ពិពាហ៍ និងការកើតថ្មី ។តែបើពិនិត្យទៅលើជំរឿនទូទៅប្រជាជនឆ្នាំ២០១៩បានឱ្យដឹងថា អត្រាកំណើនជាមធ្យមក្នុងអំឡុង១០ឆ្នាំ២០០៨-២០១៨ នៅខេត្តកំពង់ធំមានចំនួន០,៦ភាគរយ មានភាពលំអៀងច្រើនបើធៀបទៅនឹងអត្រាកំណើនខាងលើដែរ ។ ដូច្នេះយើងបានកំណត់យកអត្រាកំណើនប្រជាជនជាមធ្យមប្រចាំឆ្នាំនៅក្នុងឃុំសំព្រោជ ០,៦ភាគរយ ទៅតាមជំរឿនទូទាំងប្រទេសប្រចាំខេត្តកំពង់ធំ ដើម្បីប្រើប្រាស់ក្នុងការព្យាករណ៍កំណើនប្រជាជនក្នុងឃុំ ។

នៅក្នុងឃុំសំព្រោជ ក្នុងឆ្នាំ២០១៧ មានដង់ស៊ីតេប្រជាជនរស់នៅ ៦១នាក់/គម^{២} ដោយការរស់នៅរបស់ប្រជាពលរដ្ឋភាគច្រើនតាំងលំនៅឋានជាលក្ខណៈរាយប៉ាយតាមភូមិ នៅតាមដងផ្លូវសំខាន់ៗនៅក្នុងឃុំ ។

តារាង 4៖ ស្ថិតិប្រជាជនតាមបណ្តាឆ្នាំ និងការគណនាអត្រាកំណើនមធ្យម

ចំនួន	២០១៣	២០១៣	២០១៤	២០១៥	២០១៦	២០១៧	កំណើនមធ្យម
ចំនួនប្រជាជនសរុប	១៤២៥៤	១៤០២៧	១៣០៣៨	១៣១៨២	១៣៧១០	១៣៦២៩	
កំណើនមធ្យម(%)		-១,៥៩	-៧,០៥	១,១០	៤,០១	-០,៥៩	-០,៨២

ប្រភពទិន្នន័យៈ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨

៙ចំណាំ

- អត្រាកំណើនសម្រាប់ចន្លោះឆ្នាំនីមួយៗ៖ (ឆ្នាំចុងក្រោយ-ឆ្នាំដំបូង) x ១០០ / ឆ្នាំដំបូង
- អត្រាកំណើនមធ្យមប្រចាំឆ្នាំ៖ (បូកសរុបអត្រាកំណើនតាមឆ្នាំនិមួយ/ចំនួនឆ្នាំ)

គ. ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់

នៅក្នុងឃុំសំព្រោជមាន ជនជាតិខ្មែរ និងខ្មែរកាត់ចិន ដែលភាគច្រើនកាន់សាសនាព្រះពុទ្ធ និងគោរពប្រពៃណី និងទំនៀមទម្លាប់បែបខ្មែរដូចជា ពិធីរៀបមង្គលការប្រារព្ធពីធីបុណ្យទាននៅតាមវត្តអារាមនិងតាមផ្ទះ និមន្តព្រះសង្ឃសូត្រមន្តតាមផ្ទះ ពិធីបូជាសព និងមួយចំនួនតិចមានទំនៀមទម្លាប់បែបចិនដូចជាពិធីសែនព្រេន

ជូនតា ពីធីបញ្ចុះសព ។ និយាយរួមប្រជាជនក្នុងឃុំសំព្រោជ តែងតែប្រារព្ធពិធីបុណ្យទានតាមប្រពៃណីទំនៀមទម្លាប់ ពីបុរាណរៀងមក តាមជំនឿបែបខ្មែរ បែបចិនតិចតួច ។

ឃ. របររកទទួលទាន

បើយោងទៅតាមទិន្នន័យពីមន្ទីរផែនការក្នុងឆ្នាំ២០១៧ នៅតារាងខាងក្រោម បានបង្ហាញឱ្យឃើញថា នៅក្នុងឃុំសំព្រោជ អ្នកដែលមានមុខរបរចម្បងចំនួន ៦ ១៣២នាក់ ស្មើនឹង ៩៥,៦ភាគរយ ហើយនៅក្នុងនោះប្រជាពលរដ្ឋភាគច្រើនប្រកបមុខរបរកសិកម្ម ជាចម្បងមានចំនួន ៥ ០១៤នាក់ ស្មើនឹង ៨១,៨ភាគរយ អ្នកប្រកបមុខរបរសិប្បកម្មមានចំនួន១២នាក់ ស្មើនឹង0,២ភាគរយ និងអ្នកប្រកបមុខរបរសេវាកម្មមានចំនួន ១ ១០៦នាក់ ស្មើនឹង១៨ភាគរយ ហើយមុខរបរទាំងអស់នោះមានដូចជាៈ នេសាទត្រី ធ្វើស្រែ ចិញ្ចឹមសត្វ ដាំដំណាំបន្លែ កម្មករសំណង់ ស៊ីឈ្នួលដកស្ទូង ហាលស្រូវ ច្រកស្រូវ លីស្រូវ លក់ដូរ មន្ត្រីរាជការ អាជីវករលក់ដូរធ្វើការជាមួយវិស័យឯកជន និងអង្គការនានា ហើយភាគច្រើនធ្វើការមានជំនាញច្បាស់លាស់ ។

តារាង 5ៈ តារាងមុខរបរ

បរិយាយ		២០១៦	២០១៧
សរុបអ្នកមានមុខរបរចម្បង		៦ ៥២៧	៦ ១៣២
%សរុបអ្នកមានមុខរបរចម្បង		៩៨,៩	៩៥,៦
%ស្រីមានមុខរបរចម្បង(គិតក្នុងស្រី១៨-៦០ឆ្នាំ)		៧៨,៨	៦៨,៤
%ប្រុសមានមុខរបរចម្បង(គិតក្នុងប្រុស១៨-៦០ឆ្នាំ)		៨៦,៧	៨៩,៧
សរុបអ្នកមានមុខរបរចម្បងក្នុងផ្នែកសិកម្ម		**៥ ៦៦៥**	**៥ ០១៤**
%អ្នកមានមុខរបរចម្បងផ្នែកសិកម្ម(គិតក្នុងមុខរបរចម្បង)		**៨៦,៨**	**៨១,៨**
%ស្រីមានមុខរបរចម្បងផ្នែកសិកម្ម(គិតក្នុងមុខរបរចម្បង)		**៤២,៩**	**៣៥,៨**
ក្នុងនោះ	%អ្នកមានមុខរបរធ្វើស្រែ	៨០,១	៧២,៥
	%អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលវែង	0,២	0,៦
	%អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលខ្លី	១,៥	១,៩
	%អ្នកមានមុខរបរដាំដំណាំបន្លែ	0,៩	១,៧
	%អ្នកមានមុខរបរនេសាទ	១,៥	២,៣
	%អ្នកមានមុខរបរចិញ្ចឹមសត្វ	២,៦	២,៧
	%អ្នកមានមុខរបរពីអនុផលព្រៃឈើ	0,0	0,0
សរុបអ្នកបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសិប្បកម្ម		**១២**	**១២**
%អ្នកបម្រើការងារក្នុងផ្នែកសិប្បកម្ម		**0,២**	**0,២**
%ស្រីបម្រើការងារក្នុងផ្នែកសិប្បកម្ម		**0,0**	**0,0**
ក្នុងនោះ	%អ្នកបម្រើការងារសិប្បកម្មត្បាញរវៃ	0,0	0,0
	%អ្នកបម្រើការងារសិប្បកម្មផលិតពីផ្តៅ វល្លិ ល្ពាក់...	0,0	0,0
	%អ្នកបម្រើការងារសិប្បកម្មផលិតគ្រឿងសង្ហារឹម	0,0	0,0
	%អ្នកបម្រើការងារសិប្បកម្មចម្លាក់ធ្វើពីឈើ ថ្ម ស្ពាន់..	0,0	0,0

បរិយាយ		២០១៦	២០១៧
	%អ្នកបម្រើការងារសិប្បកម្មផលិតពីដែក អាលុយមីញ៉ូម	០,២	០,២
	%អ្នកបម្រើការងារសិប្បកម្មផលិតពីជ័រ ប្លាស្ទីក ...	០,០	០,០
	%អ្នកបម្រើការងារសិប្បកម្មកែច្នៃ ឬវិចខ្ចប់គ្រាប់ធញ្ញជាតិ	០,០	០,០
	%អ្នកបម្រើការងារសិប្បកម្មផលិតផ្សេងៗ	០,០	០,០
សរុបអ្នកបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសេវាកម្ម		៨៥០	១ ១០៦
%អ្នកបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសេវាកម្ម		១៣,០	១៨,០
%ស្រីបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសេវាកម្ម		៦,១	៨,១
ក្នុងនោះ	%អ្នកបម្រើការងារលក់ដូរ និងជំនួញ	១,៩	២,០
	%អ្នកបម្រើការងារជាជាងជួសជុល	០,៤	០,៥
	%អ្នកបម្រើការងារក្នុងផ្នែកដឹកជញ្ជូន	០,២	០,១
	%អ្នកបម្រើការងារស៊ីឈ្នួលក្នុងវិស័យកសិកម្ម កម្មកររសំណង់	៣,៣	៧,២
	%អ្នកបម្រើការងារក្នុងវិស័យឯកជន(កម្មកររោងចក្រ បុគ្គលិក អង្គការ)	៦,០	៧,៣
	%អ្នកបម្រើការងារជាមន្ត្រីរាជការ	១,២	១,០

ប្រភពទិន្នន័យៈ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨

ប្រជាពលរដ្ឋនៅក្នុងឃុំសំព្រោជ ពួកគាត់បានបង្កើតមុខរបរបន្ទាប់បន្សំបន្ថែមទៀត ក្រៅពីមុខរបរចម្បង ដើម្បីទ្រទ្រង់ជីវភាពក្នុងគ្រួសារឱ្យកាន់តែប្រសើរឡើង ហើយយោងទៅតាមទិន្នន័យមន្ទីរផែនការឆ្នាំ២០១៧ បានបង្ហាញឱ្យឃើញថា ប្រជាជនដែលមានមុខរបរបន្ទាប់បន្សំផ្នែកសិកម្មចំនួន១៦៩៥នាក់ ស្មើនឹង ៧២,៨ភាគរយ ក្នុងនោះមានស្ត្រីចំនួន ៦៦៧នាក់ ស្មើនឹង ២៨,៧ភាគរយ អ្នកដែលមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្មមានចំនួន២៧,២ភាគរយ ក្នុងនោះមានស្រី ១២,៨ភាគរយ និងមិនមានអ្នកប្រកបមុខរបរសិប្បកម្មនោះទេ ។

តារាង 6៖ មុខរបរបន្ទាប់បន្សំ

បរិយាយ	២០១៧	២០១៧ចំនួន (នាក់)
%អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសិកម្ម	៧២,៨%	១៦៩៥នាក់
%ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកសិកម្ម	២៨,៧%	៦៦៧នាក់
%អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្ម	0,0%	0នាក់
%ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្ម	0,0%	0នាក់
%អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម	២៧,២%	១នាក់
%ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម	១២,៨%	២៩៧នាក់

ប្រភពទិន្នន័យៈ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨

ង. ចំណូលស្រុក និងចំណាកស្រុក

កត្តាដែលធ្វើឱ្យមានការផ្លាស់ប្តូរលំនៅឋាន គឺដោយសារនៅភូមិចាស់ដែលគាត់បានរស់នៅពិបាកក្នុងការរកស៊ី និងគ្មានការងារធ្វើនៅក្នុងភូមិ ព្រមទាំងមូលហេតុមួយចំនួនទៀតដូចជាៈ ស្ថានភាពដី នៅក្នុងតំបន់មូលដ្ឋានមួយចំនួន

មានការប្រែប្រួលដោយដីខូច ងាប់សារធាតុបម្រុង ហើយឡើងខ្សោះជីជាតិ ឬដីហិរ ខ្វះប្រភពទឹក ធ្វើឱ្យទទួលបានទិន្នផលទាប តម្លៃផលិតផលកសិកម្មមិនទៀងទាត់ និងគ្មានទីផ្សារផលិតផល ចំណែកសមាជិកគ្រួសារកើនឡើង និងមួយចំនួនជាប់បំណុលធនាគារ និងមីក្រូហិរញ្ញវត្ថុជាដើម។ល។ ការផ្លាស់ប្តូរលំនៅឋានរបស់ប្រជាជនមួយចំនួនទៅរស់នៅទីប្រជុំជនឃុំ/សង្កាត់ ស្រុក/ក្រុង រាជធានី/ខេត្ត និងទៅធ្វើការងារនៅប្រទេសផ្សេងៗ។ មូលហេតុចម្បងនៃការធ្វើចំណាកស្រុកគ្រប់ប្រភេទ គឺក្នុងគោលបំណងលើកស្ទួយតម្លៃសេដ្ឋកិច្ចគ្រួសារ ។ តាមរបាយការណ៍របស់រដ្ឋបាលឃុំ នៅក្នុងឃុំសំព្រោជ គ្រួសារផ្លាស់លំនៅឋានចូលមានចំនួន៣៣គ្រួសារ ក្នុងនោះមនុស្សសរុបមានចំនួន១៣២នាក់ ស្រីចំនួន៧៩នាក់ និងគ្រួសារផ្លាស់លំនៅឋានចេញមានចំនួន១១គ្រួសារ មនុស្សសរុបមានចំនួន៥៥នាក់ ស្រីមានចំនួន១០នាក់ ។

តារាង 7៖ ស្ថិតិប្រជាជនផ្លាស់ប្តូរទីលំនៅក្នុងឆ្នាំ២០១៦-២០១៧

ល.រ	បរិយាយ	ចំនួនគ្រួសារ	ចំនួនប្រជាជនសរុប	
			សរុប	ស្រី
១	ចំនួនគ្រួសារផ្លាស់លំនៅឋានចូល	៣៣	១៣២	៧៩
២	ចំនួនគ្រួសារផ្លាស់លំនៅឋានចេញ	១១	៥៥	១០

ប្រភពទិន្នន័យ៖ *ក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨*

បើយោងទៅតាមទិន្នន័យមន្ទីរផែនការខេត្តឆ្នាំ២០១៧ បានបង្ហាញថានៅក្នុងឃុំទាំងមូលមានប្រជាពលរដ្ឋធ្វើចំណាកស្រុកសរុបចំនួន ២ ៣២៤នាក់ ស្រីភេទចំនួន១ ០០២នាក់ នៅក្នុងនោះអ្នកធ្វើចំណាកស្រុកក្នុងប្រទេសមានចំនួន ១ ៣០៣នាក់ ស្រីមានចំនួន ៦១៤នាក់។ ចំណាកស្រុករបស់ប្រជាពលរដ្ឋមិនអចិន្ត្រៃយ៍នោះទេ ពួកគាត់ទៅធ្វើការនៅ ស្រុក ខេត្តផ្សេង ឬរាជធានីភ្នំពេញតែមួយរយៈប៉ុណ្ណោះ ហើយពួកគាត់តែងតែមកស្រុកជារឿយៗ ។

សម្រាប់អ្នកធ្វើចំណាកស្រុកក្រៅប្រទេសមានចំនួន ១ ០២១នាក់ ស្រី៣៨៨នាក់ មានដូចជា៖ ប្រទេសថៃ ម៉ាឡេស៊ី ជប៉ុន និងប្រទេសកូរ៉េជាដើម ពួកគាត់ទៅតែមួយរយៈប៉ុណ្ណោះនិងត្រលប់មកស្រុកកំណើតវិញ។

ហើយកត្តាដែលបណ្តាលឲ្យមានចំណាកស្រុកបែបនេះដោយសារ៖

- ខ្វះឬគ្មានដីបង្កបង្កើនផលសម្រាប់វិស័យកសិកម្ម និងមួយចំនួនទៀតមានដីកសិកម្មតិចតួចធ្វើស្រែបានផលទាប
- ការធ្វើស្រែចម្ការបានតែមួយរដូវ និងតម្លៃទីផ្សារមិនទៀងទាត់
- មិនមានការងារគ្រប់គ្រាន់នៅក្នុងស្រុក
- ជំពាក់បំណុលធនាគារ ឬឯកជនមិនមានលទ្ធភាពសង
- គ្មានមុខរបរច្បាស់លាស់ និងមានប្រាក់ចំណូលប្រចាំថ្ងៃទាប
- ដើម្បីរកចំណូលបន្ថែមនៅស្រុកផ្សេង
- លក់ដីនៅក្នុងឃុំ ហើយទៅទិញនៅកន្លែងដែលមានតម្លៃទាប

តារាង ៨៖ ស្ថិតិប្រជាជនចំណាកស្រុក

បរិយាយ	២០១៦			២០១៧		
	សរុប	ប្រុស	ស្រី	សរុប	ប្រុស	ស្រី

ចំនួនអ្នកធ្វើចំណាកស្រុកក្នុងប្រទេស	១១៧១	៦៦១	៥១០	១៣០៣	៦៨៩	៦១៤
ចំនួនអ្នកធ្វើចំណាកស្រុកក្រៅប្រទេស	១ ១៩៧	៧៧៥	៤២២	១ ០២១	៦៣៣	៣៨៨
សរុប	**២ ៣៦៨**	**១ ៤៣៦**	**៩៣២**	**២ ៣២៤**	**១ ៣២២**	**១ ០០២**

ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨

១.១.៣.ស្ថានភាពសេដ្ឋកិច្ច

ក. ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ

បើយោងតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន នៅត្រង់ចំណុចនៃការវិភាគចំណាត់ថ្នាក់ទ្រព្យធនបានឱ្យដឹងថាគ្រួសារដែលមានជីវភាពគ្រាន់បើ ជីវភាពមធ្យម និងក្រ មានប្រភពចំណូលទី១ គឺស្រូវ ប្រភពចំណូលទី២ គឺចំណាកស្រុក (ភ្នំពេញ និងប្រទេសថៃ) និងប្រភពចំណូលទី៣ គឺលក់ដូរ ក្រៅពីនោះមានកម្មកររោង ចក្រលក់ដូរ សំណង់។ ចំណែកគ្រួសារក្រណាស់មានប្រភពចំណូលតែមួយគត់ គឺលក់ពលកម្ម ។

ខ. កម្រិតជីវភាពរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ

បើយោងទៅតាមតារាងចំណាត់ថ្នាក់ទ្រព្យធននៅក្នុងឆ្នាំ២០១៧ ដែលទទួលបានពីរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធ ក្សេត្រ-បរិស្ថានខាងលើ បានបង្ហាញឱ្យឃើញថា ក្នុងឆ្នាំ២០១៧ ប្រជាពលរដ្ឋក្នុងឃុំសំព្រោជមានកម្រិតជីវភាពរស់នៅចែកចេញជាបួនកម្រិតគឺ ១)គ្រួសារបង្គួរ/គ្រាន់បើ មានចំនួន ១០,៣៩ភាគរយ ដែលជាគ្រួសារមានកម្រិតជីវភាពធូរធាជាងគេមានដីកាន់កាប់ពី ៥,២៥ហិកតា ២)គ្រួសារមធ្យមមានចំនួន៦៧,៥១ភាគរយជាចំនួនច្រើនជាងគេ មានដីកាន់កាប់ពី ២,៧ហិកតា ៣) គ្រួសារក្រមានចំនួន១៥,៧ភាគរយមានដីកាន់កាប់ពី០,៨៨ហិកតា និង ៤) គ្រួសារក្រណាស់ដែលជាគ្រួសារក្រីក្របំផុត និងមានចំនួនតិចជាងគេត្រឹមតែ ៦,៤ភាគរយមានដីកាន់កាប់ពី០,៣០ហិកតាចុះក្រោមរហូតដល់អ្នកគ្មានដី ។

តាមរយៈការសាកសួរទៅលើប្រជាពលរដ្ឋ និងមេឃុំផ្ទាល់បានឱ្យដឹងថាប្រជាជននៅក្នុងឃុំសំព្រោជមានចំណូលប្រចាំថ្ងៃពី១៧ ០០០ ទៅ ២០ ០០០រៀល សម្រាប់១គ្រួសារ/ថ្ងៃ និង៦ ២០៥ ០០០ទៅ ៧ ៣០០ ០០០ រៀល សម្រាប់១គ្រួសារ/ឆ្នាំ និងការចំណាយប្រចាំឆ្នាំដូចជា៖ ស្បៀងអាហារ សម្លៀកបំពាក់ ឧបករណ៍ប្រើប្រាស់ សម្ភារៈសិក្សា និងថ្នាំសង្កូវ ព្រមទាំងចំណាយផ្សេងៗចាប់ពី ៥ ១១០ ០០០ ទៅ៦ ២០៥ ០០០រៀលសម្រាប់១គ្រួសារ/ឆ្នាំ ។

តារាង ១៖ តារាងកម្រិតជីវភាពរបស់ប្រជាជន

ចំណាត់ថ្នាក់ធនធាន	បង្គួរ/គ្រាន់បើ	មធ្យម	ក្រ	ក្រណាស់/គ្មានដី	សរុប
ប្រៀបធៀបជា%	១០,៣៩%	៦៧,៥១%	១៥,៧%	៦,៤%	១០០%
ទូទាំងឃុំ	១០,៣៩%	៦៧,៥១%	១៥,៧%	៦,៤%	១០០%
ទំហំគ្រួសារ	២៨៩	១ ៩០៤	៤៣៧	១៧៨	២ ៨០៨
ទំហំគ្រួសារ	៥នាក់/គ្រួសារ	៤នាក់/គ្រួសារ	៥នាក់/គ្រួសារ	៤នាក់/គ្រួសារ	
កម្លាំងពលកម្ម	៣នាក់/គ្រួសារ	៣នាក់/គ្រួសារ	៣នាក់/គ្រួសារ	២នាក់/គ្រួសារ	
ទំហំដីកាន់កាប់សរុប(ហ.ត)	៥,២៥	២,៧	០,៨៨	០,៣០	

ចំនួននិងប្រភេទក្បាលដី	៤	៣	២	១	
ដីលំនៅឋាន(ហ.ត)	០,២៥	០,២០	០,១៨	០,០៥	
ដីស្រែ(ហ.ត)	៥	២,៥	០,៧	០,២៥	
ដីដាំបន្លែ(ហ.ត)	មានតិចតួច	មានតិចតួច	មានតិចតួច	មានតិចតួច	
ប្រភេទពូជស្រូវដាំដុះ	៨៥,៥៤៥១ សែនក្រអូប រំដួល ម្លិះ	៨៥ ,៥៤៥១ សែនក្រអូប រំដួល ម្លិះ	៨៥,៥៤៥១ សែនក្រអូប រំដួល ម្លិះ	រំដួលតិច	
ដំណាំទី១៖ ស្រូវ(ហ.ត)	៥	២,៥	០,៧	០,២៥	
ដំណាំទី២៖ បន្លែ(ហ.ត)	មានតិចតួច	មានតិចតួច	មានតិចតួច	មានតិចតួច	
ការចិញ្ចឹមត្រីគ្រួសារ	មានតិចតួច	មានតិចតួច	គ្មាន	គ្មាន	
ចំនួនគោក្បាល/គ្រួសារ	៣	២	១	គ្មាន	
ចំនួនក្របីក្បាល/គ្រួសារ	២	១	១	គ្មាន	
ចំនួនជ្រូក	មិនទាន់ច្បាស់	មិនទាន់ច្បាស់	មិនទាន់ច្បាស់	មិនទាន់ច្បាស់	
ការប្រើប្រាស់ឧបករណ៍នេសាទ	សាច់រ៉ាយ ប្រើស ១០០ ឆ្នុក	សាច់រ៉ាយ ប្រើស ១០០ ឆ្នុក មង លន់សំណាញ់ ទ្រូ សន្ទូច ឈឺប សាបត្រី......	បង់សំណាញ់ ដាក់ទ្រូ ចងសន្ទូច អូសឈឺប លន់មងដាក់ សាបត្រី...	សន្ទូចទ្រូបាច	
ប្រភពចំណូលទី១៖	ដំណាំស្រូវ	ដំណាំស្រូវ	ដំណាំស្រូវ	កម្លាំងពលកម្ម	
ប្រភពចំណូលទី២៖	ចំណាកស្រុក (ភ្នំពេញ និង ប្រទេសថៃ)	ចំណាកស្រុក (ភ្នំពេញ និង ប្រទេសថៃ)	ចំណាកស្រុក (ភ្នំពេញនិង ប្រទេសថៃ)	កម្លាំង ពលកម្ម	
ប្រភពចំណូលទី៣៖	លក់ដូរ	លក់ដូរ	លក់ដូរ	កម្លាំងពលកម្ម	
ការងារក្រៅពីកសិកម្ម (**ប្រភេទពលកម្ម**)	កម្មកររោង ចក្រលក់ដូរ សំណង់	កម្មកររោង ចក្រលក់ដូរ សំណង់	កម្មកររោង ចក្រលក់ដូរ សំណង់	កម្លាំង ពលកម្ម	
ការប្រើប្រាស់ឥណទាន	៩៥%	៦០%	២០%	៥%	

ប្រភពទិន្នន័យ៖ *របាយការណ៍ក្សេត្រ-បរិស្ថាន*

គ. ស្ថានភាពបំណុលសរុប និងអត្រាការប្រាក់

ប្រជាពលរដ្ឋនៅក្នុងឃុំសំព្រោជមានចំនួន ១ ២៩២គ្រួសារ ស្មើនឹងប្រមាណ ៤៦ភាគរយ ដែលមានបំណុលពីមីក្រូហិរញ្ញវត្ថុ និងធនាគារ ដូចមានរាយខាងក្រោម៖

- អ្នកមានជីវភាពបង្គួរ៖ មានលទ្ធភាពខ្ចីប្រាក់ពីធនាគារ យកមកចងការបន្ត និងពង្រីកមុខរបរដូចជា កសិកម្ម សិប្បកម្ម និងលក់ដូរ។ល។

- អ្នកមានជីវភាពមធ្យមៈ មានលទ្ធភាពខ្ចីប្រាក់ពីធនាគារ យកមកចងការបន្ត និងពង្រីកមុខរបរ ដូចជា កសិកម្ម សិប្បកម្ម និងលក់ដូរ។ល។
- អ្នកមានជីវភាពខ្សត់ខ្សោយក្រៈ ពុំមានលទ្ធភាពខ្ចីប្រាក់ពីធនាគារ ឬមីក្រូហិរញ្ញវត្ថុឯកជន ដោយសារគ្មានទ្រព្យប្រចាំ តែត្រូវខ្ចីប្រាក់បន្តពីអ្នកមានជីវភាពបង្គួរ និងមធ្យម ។
- ចំណែកអ្នកក្រុបំផុតៈ ប្រកបរបរដោយលក់កម្លាំងពលកម្ម និងធ្វើចំណាកស្រុក ។

នៅក្នុងឃុំសំព្រោជ មិនមានទីតាំងធនាគារ ស្ថាប័នមីក្រូហិរញ្ញវត្ថុ ឬសាខានៅក្នុងឃុំនោះទេ តែមានសេវាប្រាក់កម្ចីពីធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុជាច្រើននៅក្នុងមូលដ្ឋាន ។ ចំពោះអាត្រានៃការប្រាក់វិញ គិតតាមចំនួនប្រាក់កម្ចី បើកម្ចីកាន់តែច្រើនអាត្រាការប្រាក់កាន់តែទាបរហូត០,៩ភាគរយ តែបើកម្ចីកាន់តែតិចនោះអាត្រាការប្រាក់កាន់តែខ្ពស់រហូតដល់១,៨ភាគរយ ទាំងធនាគារ និងស្ថាប័នគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទាំងអស់មានអាត្រាការប្រាក់ គឺប្រហាក់ប្រហែលគ្នា ហើយប្រជាពលរដ្ឋទូទៅអាចទទួលបានសេវាកម្ចីពីធនាគារ កាណាឌីយ៉ា អេស៊ីលីដា ប្រៃសណីយ៍ និងស្ថាប័នគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនដូចជាៈ ស្ថាបនា ហត្ថាកសិករ ប្រាសាក់ អេអឹមខេ ក្រេឌីត បណ្ដាញសេដ្ឋកិច្ច មហានគរ អម្រឹត វីសិនហ្វាន់។ល។ ចំណែកអ្នកខ្សត់ខ្សោយដែលខ្ចីប្រាក់បន្តពីអ្នកមានជីវភាពបង្គួរ និងមធ្យម មានអត្រាការប្រាក់ខ្ពស់គឺចាប់ពី១,៥ភាគរយទៅ១០ភាគរយ ។

ឃ. ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬក្រោមរូបភាពផ្សេងៗ

ជាទូទៅនៅក្នុងឃុំសំព្រោជ មានការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់សុទ្ធ ដើម្បីយកទៅប្រើប្រាស់ពង្រីកមុខរបរ ចងការបន្តរ ទិញសម្ភារៈកសិកម្ម ទិញជី និងប្រើប្រាស់តាមតម្រូវការចាំបាច់ផ្សេងៗទៀត ក៏នៅមានក្រោមរូបភាពប្រជាពលរដ្ឋមួយចំនួនទៅទទួលយកជីដាក់ស្រូវមុន និងសន្យាសងប្រាក់នៅពេលប្រមូលផលស្រូវផងដែរ ។

ង. ចំណូលពីប្រភពផ្សេងៗ

ប្រជាពលរដ្ឋនៅក្នុងឃុំសំព្រោជ ពួកគាត់អាចទទួលបាននូវប្រភពចំណូលពីប្រភពផ្សេងៗដូចជាៈ

- ចំណាកស្រុកក្រៅប្រទេស(ពលករផ្នែក កសិកម្ម ឧស្សាហកម្ម) ដូចជាប្រទេសថៃ ជាដើម
- និងចំណូលមួយចំនួនតូចទៀត បានមកពីគ្រួសារ ឬបងប្អូនរស់នៅជាអចិន្ត្រៃយ៍នៅបរទេស ដែលពួកគាត់បានផ្ញើមកដើម្បីផ្គត់ផ្គង់គ្រួសារនៅស្រុកខ្មែរ។

១.១.៨.ស្ថានភាពអប់រំ និងសិក្សាធិការ

ក. ស្ថានភាពអប់រំ

យោងតាមផែនការអភិវឌ្ឍឃុំសំព្រោជ៥ឆ្នាំ (២០១៧-២០២២) បានឱ្យដឹងថា ជារៀងរាល់ឆ្នាំកុមារាកុមារី គ្រប់អាយុចូលរៀន បានចុះឈ្មោះចូលរៀនគ្រប់គ្នា ទោះបីជាកុមារ ស្ថិតនៅក្នុងស្ថានភាពគ្រួសារក្រីក្រ គ្រួសារដែលជាស្ត្រីមេម៉ាយ ឬក្មេងកំព្រា កុមារពិការក៏ដោយក្តី។ មកដល់ពេលបច្ចុប្បន្ន វិស័យអប់រំនៅក្នុងឃុំសំព្រោជ មានការរីកចម្រើនជាងមុនដូចជាៈ អគារសិក្សាត្រូវបានសាងសង់ថ្មីៗ និងមានការកែលម្អបន្ទប់រៀនថែមទៀត នៅតាមសាលារៀនគ្រប់កម្រិត ដែលផ្តល់លទ្ធភាពឱ្យសិស្សបានរៀនសូត្រគ្រប់ពេលពុំមានការខ្វះខាតឡើយ។ ចំណុចអវិជ្ជមានក៏មាននៅក្នុងឃុំផងដែរដូចជាៈ ខ្វះគ្រូបង្រៀន មិនទាន់មានសាលាមត្តេយ្យសហគមន៍គ្រប់គ្រាន់នៅតាម

តាមភូមិនៅឡើយ មានអ្នកមិនចេះអក្សរ(អនក្ខរជន) ជាពិសេសមនុស្សមានវ័យចំណាស់ពួកគាត់ពុំសូវមានស្មារតីសិក្សារៀនសូត្រ ទោះបីមានការយកចិត្តទុកដាក់ជម្រុញលើកទឹកចិត្តពីអាជ្ញាធរមូលដ្ឋានយ៉ាងណាក៏ដោយ ។

រូបភាព 1៖ សាលារៀន

សាលាបឋមសិក្សា

សាលាបឋមសិក្សា

នៅក្នុងឃុំសំព្រោជ មានកម្រិតសិក្សាចាប់ពីមត្តេយ្យសិក្សារហូតដល់អនុវិទ្យាល័យ ចំណែកសាលាវិទ្យាល័យមិនមាននោះទេ ប៉ុន្តែមាននៅឃុំកំពង់ចិនត្បូងដែលជាប់ព្រំប្រទល់គ្នានោះ ។ សាលាមត្តេយ្យចំនួន ០៣កន្លែង ០៤បន្ទប់ ០៤ថ្នាក់ មានគ្រូបង្រៀនចំនួន ០៣នាក់ជាស្ត្រី និងសិស្សកំពុងរៀនមានចំនួន២២២នាក់ ក្នុងនោះស្រីចំនួន១០៧នាក់ ។ សាលាបឋមសិក្សាមានចំនួន ០៨កន្លែង ៥៧បន្ទប់ ៥៥ថ្នាក់ មានគ្រូបង្រៀនសរុបចំនួន២៩នាក់ ក្នុងនោះស្រី១៤នាក់ និងសិស្សដែលកំពុងរៀនមានចំនួនសរុប១៨០៨នាក់ មានសិស្សស្រីចំនួន៨៥៣នាក់ ។ សាលាអនុវិទ្យាល័យមានចំនួន០១កន្លែង ១៦បន្ទប់ ១០ថ្នាក់ ហើយសិស្សដែលកំពុងរៀនមានចំនួនសរុប៥២៣នាក់ ស្រីចំនួន២៩៦នាក់ និងគ្រូបង្រៀនមានចំនួន១៣នាក់ ក្នុងនោះស្រី០៥នាក់ ។

តារាង 10៖ ស្ថិតិសាលារៀន ស្ថានភាពអប់រំ និងសិក្សាធិការក្នុងឃុំឆ្នាំ២០១៧

ស្ថានភាពសាលា	ចំនួនសាលារៀន			ចំនួនសិស្ស		គ្រូបង្រៀន	
	សាលា	បន្ទប់	ថ្នាក់	សរុប	ស្រី	សរុប	ស្រី
១.សាលាមត្តេយ្យ	៣	៤	៤	២២២	១០៧	៣	៣
២.សាលាបឋមសិក្សា	៨	៥៧	៥៥	១៨០៨	៨៥៣	២៩	១៤
៣.អនុវិទ្យាល័យ	១	១៦	១០	៥២៣	២៩៦	១៣	០៥

ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨

ខ. ស្ថានភាពអក្ខរកម្ម

ដោយយោងទៅតាមទិន្នន័យពីមន្ទីរផែនការឆ្នាំ២០១៧ នៅក្នុងឃុំសំព្រោជ ប្រជាជនដែលមានអាយុពី ១៥ ទៅ៤៥ឆ្នាំ មានចំនួន ៥ ៨៧៦នាក់ នៅក្នុងចំណោមអ្នកទាំងនោះ មានអ្នកដែលមិនចេះអក្សរ ចំនួន១២,១ ភាគរយ ហើយបើគិតទៅតាមក្រុមអាយុវិញយើងឃើញថាប្រជាជនមិនចេះអក្សរអាយុពី១៥ ទៅ ២៤ឆ្នាំ មានចំនួន១៩១នាក់ ស្មើនឹង ៧ភាគរយ និងប្រជាជនមានអាយុពី ២៥ ទៅ ៤៥ឆ្នាំ មានអ្នកមិនចេះអក្សរចំនួន ៥១៨នាក់ ស្មើនឹង ១៦,៥ភាគរយ ។

ប្រជាពលរដ្ឋភាគច្រើនដែលមិនចេះអក្សរ គឺដោយសារមិនបានចូលរៀន មូលហេតុដោយសារសាលារៀននៅឆ្ងាយពីភូមិ ឃុំ ។ ប្រជាពលរដ្ឋនៅតែមានកង្វះមធ្យោបាយធ្វើដំណើរទៅសាលារៀន ខ្វះថវិកាសម្រាប់ទិញសម្ភារៈសិក្សា សម្លៀកបំពាក់ និងផ្នត់គំនិតរបស់ឪពុកម្តាយចាស់គំរឹលឬមិនជឿនលឿន ។ ទោះបីយ៉ាងនោះក្តី នៅក្នុងឃុំនៅមានថ្នាក់អក្ខរកម្មជាប្រចាំ តែពួកគាត់ពុំទាន់មានពេលចូលសិក្សាព្រោះជាប់រវល់ប្រកបរបរចិញ្ចឹមជីវិត ជាហេតុនាំមកនូវការភ្លេចអក្សរ ក្នុងចំណោមអ្នកដែលបានចូលមកសិក្សាក្នុងថ្នាក់អក្ខកម្មករន្លងមក ។

- អនុវិស័យអប់រំក្រៅប្រព័ន្ធ

ក្របខ័ណ្ឌស្ថាប័ន និងគោលនយោបាយត្រូវបានពង្រឹង តាមរយៈការពិនិត្យឡើងវិញគោលនយោបាយអប់រំក្រៅប្រព័ន្ធ ការបង្កើតអនុក្រុមការងារអប់រំក្រៅប្រព័ន្ធនិងមានភារកិច្ចច្បាស់លាស់ ការវាយតម្លៃសមត្ថភាពអប់រំក្រៅប្រព័ន្ធនិងការកសាងផែនទី ក៏ដូចជាការពិនិត្យឡើងវិញកម្មវិធីចូលរៀន ឡើងវិញនិងការរៀបចំសេចក្តីណែនាំស្តីពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធនិងកម្មវិធីសមមូល។ ដើម្បីជម្រុញអោយផែនការយុទ្ធសាស្ត្រអនុវិស័យអប់រំក្រៅប្រព័ន្ធបានទទួលជោគជ័យ ត្រូវបន្តអនុវត្តសកម្មភាពដូចខាងក្រោម៖

១. បន្តពង្រឹងសកម្មភាពមជ្ឈមណ្ឌលសិក្សាសហគមន៍ បណ្ណាល័យ និងមណ្ឌលអានដែលមានស្រាប់

២. បន្តពង្រឹងការអនុវត្តកម្មវិធីសមមូលបឋមសិក្សា និងមធ្យមសិក្សា

៣. អនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ

៤. បន្តអនុវត្តការងារអក្ខរកម្មតាមការជាក់ស្តែង

៥. បន្តអនុវត្តកម្មវិធីចូលរៀនឡើងវិញ។

តារាង 11៖ ស្ថិតិអ្នកមិនចេះអក្សរ

បរិយាយ	២០១៦	២០១៧
ចំនួនអ្នកមិនចេះអក្សរអាយុ១៥-២៤ឆ្នាំ	២១៦	១៩១
%អ្នកមិនចេះអក្សរអាយុ១៥-២៤ឆ្នាំ	៧,៨	៧
ចំនួនអ្នកមិនចេះអក្សរអាយុ២៥-៤៥ឆ្នាំ	៥៣០	៥១៨
%អ្នកមិនចេះអក្សរអាយុ២៥-៤៥ឆ្នាំ	១៦,៣	១៦,៥
សរុបមនុស្សអាយុ១៥-៤៥ឆ្នាំ	៦០២៤	៥៨៧៦
%អ្នកមិនចេះអក្សរអាយុ១៥-៤៥ឆ្នាំ	១២,៤	១២,១

ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨

គ. ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត

បើយោងទៅតាមប្រភពទិន្នន័យមន្ទីរផែនខេត្តឆ្នាំ២០១៧បានបង្ហាញឲ្យឃើញថាលទ្ធភាពក្នុងការបន្តការសិក្សារបស់សិស្សនៅក្នុងឃុំសព្រោចទៅថ្នាក់ខ្ពស់ទៀតមានដូចខាងក្រោម៖

- អាយុពី១២-១៤ឆ្នាំរៀនអនុវិទ្យាល័យសរុបចំនួន ២៦៤ នាក់ ស្រីមានចំនួន ១២៦នាក់
- អាយុពី១៥-១៧ឆ្នាំរៀនអនុវិទ្យាល័យសរុបចំនួន៣៨២នាក់ ស្រីមានចំនួន២០១នាក់
- អាយុពី១៥-១៧ឆ្នាំរៀនវិទ្យាល័យសរុបចំនួន១៤០នាក់ ស្រីមានចំនួន៦១នាក់
- អាយុពី១៨-២៤ឆ្នាំរៀនវិទ្យាល័យសរុបចំនួន ១៧៧ នាក់ ស្រីមានចំនួន៨៤នាក់
- អាយុពី១៨-២៤ឆ្នាំរៀនសកលវិទ្យាល័យសរុបចំនួន ៥៥ នាក់ ស្រីមានចំនួន៣០នាក់។

- អាយុពី២៥-៣៥ឆ្នាំរៀនសកលវិទ្យាល័យសរុបចំនួន៩៩នាក់ ស្រីចំនួន៣៥នាក់
- អាយុពី១៨-២៤ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈសរុបចំនួន៨៥ ស្រីចំនួន១៥នាក់
- អាយុពី២៥-៣៥ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈសរុបចំនួន៩៦ស្រីចំនួន២៤នាក់

តារាង 12៖ ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត

ការអប់រំតាមក្រុមអាយុ	សរុប	ស្រី
អាយុពី១២-១៤ឆ្នាំរៀនអនុវិទ្យាល័យ	២៦៤	១២៦
អាយុពី១៥-១៧ឆ្នាំរៀនអនុវិទ្យាល័យ	៣៨២	២០១
អាយុពី១៥-១៧ឆ្នាំរៀនវិទ្យាល័យ	១៤០	៦១
អាយុពី១៨-២៤ឆ្នាំរៀនវិទ្យាល័យ	១៧៧	៨៤
អាយុពី១៨-២៤ឆ្នាំរៀនសកលវិទ្យាល័យ	៥៥	៣០
អាយុពី២៥-៣៥ឆ្នាំរៀនសកលវិទ្យាល័យ	៩៩	៣៥
អាយុពី១៨-២៤ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ	៨៥	១៥
អាយុពី២៥-៣៥ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ	៩៦	២៤

ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨

១.១.៩.ស្ថានភាពសុខាភិបាល

មណ្ឌលសុខភាព គឺជាកន្លែងផ្តល់សេវាអប់រំសុខភាព ថែទាំ និងព្យាបាលអ្នកជម្ងឺផ្សេងៗ ដែលជាកន្លែងសាធារណៈរបស់រដ្ឋ ។ ឃុំសំព្រោជ មានមណ្ឌលសុខភាពចំនួន០១កន្លែង ឈ្មោះថាមណ្ឌលសុខភាពសំព្រោជ ស្ថិតនៅខាងត្បូងឃុំ ដែលមានចម្ងាយប្រហែល៥០ម៉ែត្រ។ មណ្ឌលសុខភាពនេះមានចំនួនគ្រូពេទ្យ ០៨នាក់ ឆ្មបចំនួន០២នាក់ មាន០៨បន្ទប់ និងគ្រែចំនួន០៤។ ប្រភេទជម្ងឺ ដែលកាចសាហាវ ឬជម្ងឺឆ្លង ដែលកើតញឹកញាប់ គឺជម្ងឺរលាកផ្លូវដង្ហើម ។ ស្ថានភាពមាតា និងទារកនៅក្នុងឃុំសំព្រោជ មិនមានស្ត្រីដែលសម្រាលកូនដោយឆ្មបបុរាណក្នុង១ឆ្នាំកន្លងទៅនោះទេ ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបមានការបណ្តុះបណ្តាលក្នុង១ឆ្នាំកន្លងទៅមានចំនួន២៣៩នាក់ ចំនួនទារកដែលបានកើតរស់ដោយឆ្មបបុរាណមិនមែនទេ ចំនួនទារកដែលបានកើតរស់ដោយឆ្មបពេទ្យមានចំនួន២៣៩នាក់ ចំនួនមរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ0-១ខែ ដោយឆ្មបបុរាណមិនមាននោះទេ ចំនួនមរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ0-១ខែ ដោយឆ្មបពេទ្យមានចំនួន១នាក់ ចំនួនមរណភាពទារកក្នុងចន្លោះអាយុ 0-១ខែ ដោយឆ្មបបុរាណមិននោះទេ ចំនួនមរណភាពទារកក្នុងចន្លោះអាយុ0-១ខែដោយឆ្មបពេទ្យមានចំនួន១នាក់ ចំនួនទារកដែលបានចុះសំបុត្រកំណើតមានចំនួន១៧៤នាក់ ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែមានចំនួន១៥៤នាក់ ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន១៤៣នាក់ ដែលការចាក់ថ្នាំបង្ការជម្ងឺផ្សេងៗនេះធ្វើនៅមណ្ឌលសុខភាព និងតាមភូមិជូនប្រជាពលរដ្ឋ មានជម្ងឺមួយចំនួនដូចជា៖ ជម្ងឺកញ្ជ្រិល ស្វិតដៃជើង ក្អកមាន់ របេង តេតាណូស រលាកថ្លើមប្រភេទបេ ផ្តាសាយបក្សី គ្រុនចាញ់ រាករូស និងគ្រុនឈាម។ ករណីជម្ងឺធ្ងន់ធ្ងរការបញ្ជូនអ្នកជម្ងឺដោយមធ្យោបាយខ្លួនឯងផ្ទាល់ មកមណ្ឌលសុខភាព ព្រោះមណ្ឌល សុខភាពស្ថិតនៅជិតពួកគាត់ ឯការបញ្ជូនទៅមន្ទីរពេទ្យបង្អែកដោយ

មធ្យោបាយផ្ទាល់ខ្លួន និង រថយន្ត សង្គ្រោះរបស់ពេទ្យបង្អែកទាំងការចំណាយវាយផ្សេងៗ ជាបន្ទុករបស់អ្នកជម្ងឺក្នុងករណីអ្នកជម្ងឺមិនមានប័ណ្ណក្រីក្រ ។

តារាង 13៖ សុខភាពមាតានិងទារក

ល.រ	សុខភាពមាតានិងទារក	ឆ្នាំ២០១៧
១	ចំនួនបុគ្គលិកពេទ្យនៅមណ្ឌលសុខភាព	៨
២	ចំនួនពេទ្យឆ្មបនៅមណ្ឌលសុខភាព	២
៣	ចំនួនឆ្មបបុរាណនៅមណ្ឌលសុខភាព	0
៤	ចំនួនបន្ទប់នៅមណ្ឌលសុខភាព	៨
៥	ចំនួនគ្រែនៅមណ្ឌលសុខភាព	៤
៦	ចំនួនឆ្មបដែលបានបណ្តុះបណ្តាលមានក្នុងភូមិ	២
៧	ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបបុរាណក្នុង១ឆ្នាំកន្លងទៅ	0
៨	ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបមានការបណ្តុះបណ្តាលក្នុង ១ឆ្នាំកន្លងទៅ	២៣៩
៩	ចំនួនទារកដែលបានកើតរស់ដោយឆ្មបបុរាណ	0
១០	ចំនួនទារកដែលបានកើតរស់ដោយឆ្មបពេទ្យ	២៣៩
១១	ចំនួនមរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ 0-១ខែដោយឆ្មបបុរាណ	0
១២	ចំនួនមរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ 0-១ខែដោយឆ្មបពេទ្យ	១
១៣	ចំនួនមរណភាពទារកក្នុងចន្លោះអាយុ 0-១ខែដោយឆ្មបបុរាណ	0
១៤	ចំនួនមរណភាពទារកក្នុងចន្លោះអាយុ 0-១ខែដោយឆ្មបពេទ្យ	១
១៥	ចំនួនទារកដែលបានចុះសំបុត្រកំណើត	១៧៤
១៦	ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែ	១៥៤
១៧	ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន	១៤៣

ប្រភពទិន្នន័យ៖ *ក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨*

រូបភាព 2៖ មណ្ឌលសុខភាពឃុំ

យោងតាមពីទិន្នន័យពីមន្ទីរផែនការខេត្ត ឆ្នាំ២០១៧ បានឱ្យដឹងថា ចម្ងាយពីភូមិនីមួយៗទៅកាន់មណ្ឌលសុខភាព មិនឆ្ងាយណាស់ណានោះទេ គឺឆ្ងាយបំផុតត្រឹមពី០,២ទៅ ៦គីឡូម៉ែត្របុ៉ណ្ណោះ ដូចមានក្នុងតារាងសង្ខេបខាងក្រោម ។ ចំណែកស្ថានភាពផ្លូវទៅកាន់មណ្ឌលសុខភាពក៏មិនពិបាកក្នុងការធ្វើដំណើរដែរ ដែលអំណោយផលដល់ការបញ្ជូនអ្នកជម្ងឺទៅកាន់មណ្ឌលសុខភាពបានទាន់ពេលវេលា ។

តារាង 14៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព

ល.រ	ឈ្មោះភូមិ	ចម្ងាយជាមធ្យម ពីភូមិទៅមណ្ឌលសុខភាព	ផ្សេងៗ
១	ក្រសាំងជ្រុំត្បូង	១ គីឡូម៉ែត	
២	ក្រសាំងជ្រុំជើង	២០០ ម៉ែត	
៣	ត្នោតគម	១ គីឡូម៉ែត	
៤	សំព្រោជ	១ គីឡូម៉ែត	
៥	គោកស្វាយ	២,៥គីឡូម៉ែត	
៦	ពៃ	៤ គីឡូម៉ែត	
៧	ចំបក់ខ្ពស់	៤ គីឡូម៉ែត	
៨	ត្រាចជ្រុំ	៦ គីឡូម៉ែត	
៩	ស្រះពភ្លូក	១ គីឡូម៉ែត	
១០	អំពិល	៣ គីឡូម៉ែត	
១១	មឈាយ	២ គីឡូម៉ែត	
១២	ដូនល្អ	២,៥ គីឡូម៉ែត	
១៣	ប្រជិត	៣ គីឡូម៉ែត	
១៤	ល្វា	៩៥០ ម៉ែត	
១៥	អូររំចេក	២ គីឡូម៉ែត	

១៦	អំពៅព្រៃ	២ គីឡូម៉ែត	
១៧	ស្លាក់ក្រាញ់	៥ គីឡូម៉ែត	

ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨

ដ្យាក្រាម 2៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព



ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨

១.១.៦. ស្ថានភាពយេនឌ័រ

បើយោងតាមផែនការអភិវឌ្ឍឃុំសំព្រោជរយៈពេល៥ឆ្នាំ(២០១៨-២០២២) បានឱ្យដឹងថា សមភាពការងាររបស់ស្ត្រី និងបុរសក្នុងឃុំសំព្រោជនាពេលបច្ចុប្បន្នគ្មានការរើសអើង ឬគាបសង្កត់ទៅលើស្ត្រីនោះទេ។ ផ្ទុយទៅវិញការងារយេនឌ័រកំពុងមានការគាំទ្រយ៉ាងពេញទំហឹង ជាក់ស្តែងក្នុងការងារមានថ្នាក់ដឹកនាំជាស្ត្រីនៅថ្នាក់ភូមិ និងថ្នាក់ឃុំកំពុងត្រូវបានលើកកម្ពស់ និងលើកទឹកចិត្តស្ត្រីឱ្យមានការចូលរួមយ៉ាងសកម្មក្នុងការកសាងផែនការអភិវឌ្ឍឃុំ ក៏ដូចជាផែនការ វិនិយោគផងដែរ។ ទោះជាយ៉ាងនេះក្តី បញ្ហាប្រឈមនៅតែកើតមានឡើងទៅលើសមត្ថភាពស្ត្រី ដោយមានមួយចំនួននៅតែមានកម្រិតជីវភាពក្រីក្រ ខ្លះបោះបង់ការសិក្សាដើម្បីរកចំណូលមកទ្រទ្រង់ជីវភាពក្នុងគ្រួសារ អ្នកខ្លះចំណាកស្រុកទៅភ្នំពេញដើម្បីធ្វើកម្មកររោងចក្រ។ ដើម្បីដោះស្រាយបញ្ហានេះក្រុមប្រឹក្សាឃុំ បានសហការជាមួយមន្ទីរការិយាល័យជំនាញ និងដៃគូរអភិវឌ្ឍនានាជុំវុញ និងលើកទឹកចិត្តឱ្យមានការបណ្តុះបណ្តាលបច្ចេកទេសនានា និងជំនាញវិជ្ជាជីវៈបង្កើនមុខរបរថ្មីៗ ដើម្បីបង្កើនប្រាក់ចំណូល និងកាត់បន្ថយការចំណាកស្រុក។ ប៉ុន្តែបើតាមរយៈរបាយការណ៍នៃការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំសំព្រោជ ឆ្នាំ២០១៧ បានឱ្យដឹងអំពីតួនាទីយេនឌ័រក្នុងការចូលរួមសកម្មភាពការងារផលិតកម្មកសិកម្ម និងការងារទូទៅក្នុងជីវភាពគ្រួសាររបស់កសិករក្នុងឃុំសំព្រោជ មានលម្អិតក្នុងតារាងខាងក្រោម ។

តារាង 15៖ ការវិភាគលើតួនាទីយេនឌ័រ ឃុំសំព្រោជ

សកម្មភាព	**បុរស**	**ស្ត្រី**	**យោបល់បន្ថែម**
ស្រូវវស្សា			
ការរៀបចំដីលើកទី១	៧០%	៣០%	ការប្រើប្រាស់កម្លាំងធ្ងន់
ការរៀបចំដីលើកទី២	៧០%	៣០%	ស្ត្រីជួយរៀបចំម្ហូបអាហារ
ដឹកគ្រាប់ពូជ	៧០%	៣០%	លើកដាក់ធ្ងន់
ព្រួសគ្រាប់	១០០%		ការងារនៅទីវាល

ការដាក់ជីបំប៉នលើកទី១	៧៥%	២៥%	ស្ត្រីជាអ្នកជួយរៀបចំ
ការដាក់ជីបំប៉នលើកទី២	៧៥%	២៥%	ស្ត្រីជាអ្នកជួយរៀបចំ
គ្រប់គ្រងទឹកស្រែ	៨០%	២០%	ការងារនៅទីវាល
ការគ្រប់គ្រងភ្លឺស្រែ	៨០%	២០%	ស្ត្រីធ្វើការងារផ្ទះ
ការបាញ់ថ្នាំកសិកម្ម	៩០%	១០%	ការប្រើប្រាស់កម្លាំងធ្ងន់
ការបាញ់ថ្នាំបំប៉ន	៩៥%	៥%	ការងារនៅទីវាល ស្ត្រីរវល់ការងារផ្ទះ
ការច្រូតកាត់	៥០%	៥០%	ជួយការងារគ្នា
ការដឹកជញ្ជូន	៥០%	៥០%	ជួយការងារគ្នា
ហាលសម្ងួត	៣០%	៧០%	ស្ត្រីធ្វើការងារនៅផ្ទះ
ទុកដាក់ស្រូវ	៥០%	៥០%	ស្ត្រីរៀបចំទុកដាក់
លក់ស្រូវ	៥០%	៥០%	ការសម្រេចចិត្តស្មើគ្នា
សកម្មភាពមុខរបរចិញ្ចឹមជីវិតសំខាន់ផ្សេងទៀត			
សួនបន្លែ	៥០%	៥០%	ជួយការងារគ្នា
ចិញ្ចឹមជ្រូក	៥០%	៥០%	ជួយការងារគ្នា
ចិញ្ចឹមគោ ក្របី	៧០%	៣០%	ការងារនៅទីវាល
ចិញ្ចឹមមាន់ ទា	៣០%	៧០%	ការងារនៅផ្ទះ
ការប្រមូលអនុផលព្រៃឈើ	៦០%	៤០%	ស្ត្រីជួយបានពេលខ្លះនិងរៀបចំម្ហូបអាហារ
រកត្រី ខ្យង ក្តាម ខ្ទៅ	៧០%	៣០%	ទៅរកទីតាំងឆ្ងាយៗ
ការរកឧស	៧៥%	២៥%	ការនៅទីវាល
សិប្បកម្មផ្សារដែក	១០០%		ការប្រើកម្លាំង
ដំណាំរួមផ្សំ	៣០%	៧០%	ការងារនៅផ្ទះ
ផលិតកម្មដំណាំឈើហូបផ្លែ	៦៥%	២៥%	ការងារនៅចម្ការ
ជំនួញទូទៅ	៧០%	៣០%	ការងារនៅឆ្ងាយផ្ទះ
ការថែទាំប្រព័ន្ធធារាសាស្ត្រ	៧៥%	២៥%	ការងារនៅទីវាល

ប្រភពទិន្នន័យ៖ *របាយការណ៍ក្សេត្រ-បរិស្ថានឆ្នាំ២០១៧*

យោងតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំសំព្រោជ ឆ្នាំ២០១៧ បានរកឃើញ ពីការវិភាគតួនាទីយេនឌ័រក្នុងឃុំដូចខាងក្រោម៖

១. ស្ត្រីភាគច្រើនជាអ្នកផលិតផលកសិកម្ម

២. បុរសទៅរកចំណូលនៅឆ្ងាយៗផ្ទះ

៣. ស្ត្រីមើលថែការងារនៅផ្ទះជាប្រចាំ

៤. សកម្មភាពការងារមានការចូលរួមធ្វើទាំងអស់គ្នា

៥. ការងារធ្ងន់ៗជាបន្ទុករបស់បុរស

តាមប្រភពព័ត៌មានដែលទទួលបាន ដូចមានរៀបរាប់ខាងលើពាក់ព័ន្ធ ការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិអំណាចស្ត្រីនៅក្នុងឃុំសំព្រោជ យើងសង្កេតឃើញថា បុរស និងស្ត្រីមិនមានការរើសអើងគ្នាធ្ងន់ធ្ងរនោះទេ គឺមានភាពលំអៀងតិចតួចប៉ុណ្ណោះ ដូចជាការងារធ្វើស្រែសង្កេតឃើញបុរសមានការចូលរួមច្រើនជាងស្ត្រី ជាពិសេសការងាររៀបចំដីស្រែ ឃើញការងារនេះបុរសទទួលរ៉ាប់រងស្ទើរតែទាំងស្រុង ដែលស្ត្រីមានកម្លាំងទន់ខ្សោយជាងជាអ្នកចម្អិនអាហារនៅផ្ទះ ចំណែកការងារដឹកជញ្ជូនគ្រាប់ស្រូវ បាញ់ថ្នាំ សម្លាប់សត្វល្អិត និងដាក់ជី ច្រូតកាត់ និងការងារទុកដាក់ស្រូវជាដើម គឺបុរសបានចូលរួមច្រើនជាងស្ត្រី ប៉ុន្តែការងារក្នុងផ្ទះ និងនៅជិតផ្ទះ ឃើញស្ត្រីបានចូលរួមច្រើនជាងបុរសវិញ តែនៅក្នុងនោះក៏បានរកឃើញថា ការសម្រេចចិត្តក្នុងគ្រួសារបុរសនៅមានសិទ្ធិច្រើនជាងស្ត្រី និងមានស្ត្រីមួយចំនួននៅទទួលរងអំពើហិង្សាក្នុងគ្រួសារនៅឡើយ ។ ប៉ុន្តែទោះបីមានបញ្ហាប្រឈមខ្លះក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិអំណាចស្ត្រីក៏ដោយ ក៏យើងឃើញកិច្ចការនេះមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដែលទៅថ្ងៃអនាគតនឹងឈានទៅកាន់តែប្រសើរឡើង ។

១.២.ស្ថានភាពភូមិសាស្ត្រ

១.២.១. ទីតាំងភូមិសាស្ត្រ

ឃុំសំព្រោជ ជាឃុំមួយនៅក្នុងស្រុកស្ទោង ខេត្តកំពង់ធំ មានទីតាំងផ្អែកលើនិយាមកាផែនទី (អាប់ស៊ីស) ៤៣៣ ៤១២,២៦ និង(អ័រដោនេ) ១ ៤២៨ ៤៦០,១១។ សណ្ឋានដីនៅក្នុងឃុំសំព្រោជ បើផ្អែកតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំ បានឱ្យដឹងថា ជាដីមិនរាបស្មើមានទាបមានខ្ពស់ ដោយបានចែកចេញជា ០៤ តំបន់គឺ

តំបន់ I៖ នៅប៉ែកខាងជើងឈាងខាងកើត ជាតំបន់ទំនាបមធ្យម មានដីជាប្រភេទដីល្បាយខ្សាច់ពណ៌ក្រហម និងក្រម៉ៅ(ដីប្រទះឡាង បាកាន) ត្រូវបានប្រើប្រាស់សម្រាប់ លំនៅឋាន ដំណាំជម្រុះ និងធ្វើស្រែប្រើពូជស្រូវផ្ការំដួល ស្រូវម្លិះ ស្រូវខា១១ ស្រូវនាងគង់ខ្សាច់ ស្រូវដំណើប ស្រូវខា៣ ស្រូវរាំងជ័យ ស្រូវម្លិះក្រហម ស្រូវខា១៥ ស្រូវប្រាំង៨៥ ស្រូវ៧៥ ស្រូវ៥១៥៤ ស្រូវសែនក្រអូប ស្រូវក្រមួន។

តំបន់ II៖ ស្ថិតនៅកណ្តាលឃុំ ជាតំបន់វាលទំនាបទាបជម្រាលស្មើ ប្រភេទដីកណ្តេងពណ៌ខ្មៅ ក្រហមប្រផេះ(បាកាន ក្បាលពោធិ៍ ក្រគរ) ត្រូវបានប្រើប្រាស់សម្រាប់ដំណាំស្រូវ ដោយប្រើពូជស្រូវផ្ការំដួល IR ៥០៤ ៥១៥៤ និង៨៥ ។

តំបន់ III៖ នៅប៉ែកខាងត្បូងឈាងខាងលិច ជាតំបន់វាលទំនាបទាប មានជម្រាលរាបស្មើលិចទឹករយៈពេលយូរ(ខែ៧-១២) ជាដីកណ្តេងខ្មៅលាយល្បាប់ (ដីក្បាលពោធិ ដីក្រគរ ដីបាកាន) ត្រូវបានប្រើប្រាស់សម្រាប់ព្រៃលិចទឹក ដំណាំ ដំណាំឈូក និងស្រូវប្រាំងដោយប្រើប្រាស់ពូជស្រូវប៨៥ ៧៥ ៥១៥៤ ៤៩ និងពូជស្រូវក្រមួនជាប្រភេទពូជនាំចូលពីវៀតណាម ។

តំបន់ IV៖ ស្ថិតនៅភាគខាងត្បូង ជាតំបន់វាលទំនាបទាបមានជម្រាលរាបស្មើ ជាដីកណ្តេងខ្មៅលាយល្បាប់(ដីក្បាលពោធិ ដីក្រគរ ដីបាកាន) ត្រូវបានប្រើប្រាស់សម្រាប់ដំណាំឈូក និងស្រែប្រាំងដោយប្រើប្រាស់ពូជស្រូវ៨៥ ស្រូវ ៧៥ ស្រូវ ៥១៥៤ ៤៩ និងពូជស្រូវក្រមួនជាប្រភេទពូជនាំចូលពីវៀតណាម ។

ផែនទី 3៖ ផែនទីសណ្ឋានដីឃុំសំព្រោជ



ផែនទី 4៖ ផែនទីតំបន់ក្បេត្រ-បរិស្ថាន ឃុំសំព្រោជ



តារាង 16៖ ដ្យាក្រាមពំនុះកាត់ទទឹងឃុំសំព្រោជ ស្រុកស្ទោង

ឈ្មោះតំបន់	តំបន់ទី I ទំនាបមធ្យម ដំណាំស្រូវ ដំណាំជម្រុះ និង លំនៅដ្ឋាន	តំបន់ទី II តំបន់វាល រាបទាប ដំណាំស្រូវ និងលិចទឹករយៈពេល ខ្លី(ខែ៨-១០)	តំបន់ទី III តំបន់វាលរាប ទាបដំណាំ ស្រូវប្រាំង និងលិចទឹក រយៈពេលយូរ(ខែ៧-១២)	តំបន់ទី IV តំបន់ព្រៃលិច ទឹករយៈពេល យូរ
រៀបរាប់ដោយសង្ខេប	-ជាដីទំនាបមធ្យម ជម្រាលស្មើជាដីប្រភេទ ល្បាយខ្សាច់ពណ៌ក្រហម និងក្រម៉ៅ(ប្រទះឡាង និង ដីបាកាន)មានជីវជាតិ មធ្យមស្រោចស្រពដោយ ទឹកភ្លៀងទឹកប្រឡាយ១ខ្សែ ៣០កញ្ញា ទឹកអណ្តូង ស្រះ ទឹកអណ្តូងស្នប់លំនៅឋាន -ដំណាំស្រូវវស្សា និងស្រូវប្រាំង -ដំណាំឈើហូបផ្លែ បន្លែជម្រុះ -ផ្ទៃដីភាគច្រើនជាណាំស្រូវ ពូជផ្ការំដួលនិងស្រូវប្រាំង ពូជស្រូវប្រាំង៨៥.ស្រូវ៧៥ ស្រូវ៥១៥៤.ស្រូវក្រមួន ស្រូវសែនក្រអូប -ដីស្រែមិនរៀបស្មើនិងពុំសូវ មានភ្លឺបើមានភ្លឺតូៗដែរ -មានលំនៅឋាន និងប្រជា ជនរស់នៅព្រមទាំង ហេដ្ឋារចនាសម្ព័ន្ធ	-តំបន់វាលទំនាបទាប ជម្រាលស្មើ -ជាដីកណ្តែងពណ៌ខ្មៅ ក្រហមប្រផេះ(បាកាន. ក្បាលពោធិ៍ ក្រគរ -ស្រោចស្រពដោយទឹក ភ្លៀងទឹកប្រឡាយ១ខ្សែ ៣០កញ្ញា បឹង ត្រពាំង. អាងទឹក -ពុំមានភ្លឺស្រែគ្រប់គ្រាន់ ផ្ទៃដីភាគច្រើនដាំដំណាំ ស្រូវពូជផ្ការំដួល	-តំបន់វាលទំនាបទាប មានជម្រាលរាបស្មើជា ដីកណ្តែងខ្មៅលាយ ល្បាប់(ដីក្បាលពោធិ.ដី ក្រគរ.ដីបាកាន) ស្រោចស្រពដោយទឹក ភ្លៀង ទឹកទន្លេសាប.អាង ទឹកទឹកត្រពាំង.បឹង -មានព្រៃលិចទឹកនិង ដំណាំស្រូវប្រាំង.ដំណាំ ឈូកប្រាំង -ប្រើប្រាស់ពូជស្រូវប៨៥. ស្រូវ៧៥ ៥១៥៤. ៤៩. និងស្រូវក្រមួនជាពូជនាំ ចូលពីវៀតណាមនិង នាំស្រូវទៅវៀតណាមវិញ	តំបន់វាលទំនាបទាបមាន ជម្រាលរាបស្មើជាដីកណ្តែង ខ្មៅ លាយល្បាប់(ដីក្បាល ពោធិ.ដីក្រគរ.ដីបាកាន) ស្រោចស្រពដោយទឹកភ្លៀង ទឹកទន្លេសាប.អាងទឹក ទឹកត្រពាំង.បឹង -មានព្រៃលិចទឹកនិងដំណាំ ស្រូវប្រាំង.ដំណាំឈូកប្រាំង -ប្រើប្រាស់ពូជស្រូវប៨៥. ស្រូវ៧៥.ស្រូវ៥១៥៤. ៤៩. និងពូជស្រូវក្រមួនជាប្រភេទ ពូជនាំចូលពីវៀតណាមនិង នាំស្រូវទៅវៀតណាមវិញ
ឋានលេខា	ទំនាបមធ្យម	តំបន់វាលទំនាបទាប	តំបន់វាលទំនាបទាប	វាលទំនាបទាប
ប្រភេទដី	ដីល្បាយខ្សាច់ពណ៌ក្រហម និងក្រម៉ៅ(ដីប្រទះឡាង បាកាន)	ដីកណ្តែងពណ៌ខ្មៅ ក្រហមប្រផេះ(បាកាន ក្រគរក្បាលពោធិ)	ដីកណ្តែងខ្មៅ លាយ ល្បាប់(បាកានក្រគរ ក្បាលពោធិ)	ដីល្បាប់មាត់បឹងទន្លេសាប (ក្រគរ ក្បាលពោធិ)
ជលសាស្ត្រ	ទឹកភ្លៀង. ទឹកប្រឡាយ ៣០កញ្ញា	ទឹកភ្លៀង ទឹកជំនន់ ទន្លេសាប. ទឹកអាង. ទឹកត្រពាំង	ទឹកភ្លៀង ទឹកទន្លេសាប អាងទឹក.ទឹកត្រពាំង. ទឹកបឹង	ទឹកភ្លៀងទឹកអាង.ទឹកត្រពាំង បឹង.ព្រែក
ធនធានទឹក	ទឹកភ្លៀង ទឹកប្រឡាយ១ខ្សែ ៣០កញ្ញាទឹកអណ្តូងលូ ទឹកអណ្តូងស្នប់ ទឹកស្រះ	ទឹកភ្លៀងទឹកប្រឡាយ១ ខ្សែ ៣០កញ្ញា បឹង ត្រពាំង.អាងទឹក	ទឹកភ្លៀង ទឹកទន្លេសាប អាងទឹក ទឹកត្រពាំង	ទឹកភ្លៀងទឹកអាង.ទឹកត្រពាំង បឹង.ព្រែក
គម្របដីនិងការប្រើប្រាស់ដី	-លំនៅឋាន -ដំណាំស្រូវវស្សា និងស្រូវប្រាំង -ដំណាំឈើហូបផ្លែ	-ដំណាំស្រូវវស្សា ស្រូវ ប្រាំ(២ដង) -ដំណាំឪឡឹក -ដំណាំឈូក	-មានព្រៃលិចទឹកនិង ដំណាំស្រូវប្រាំង -ដំណាំឈូកប្រាំង	-ព្រៃលិចទឹក -ដំណាំឈូកនិងស្រែប្រាំង

	បន្លែជម្រុះ			
ដំណាំសំខាន់ៗ	-ស្រូវវស្សា -ស្រូវប្រាំង -បន្លែត្រសក់ទ្រើង -ត្រសក់ស្រូវ -ត្រកួន.ត្រប់.ស្ពៃ.ល្ពៅ ត្រឡាច...	-ស្រូវវស្សា និងស្រូវប្រាំង -ដំណាំឪឡឹក -ដំណាំឈូក	-ដំណាំស្រូវប្រាំង -ដំណាំឈូក	-ដំណាំឈូកនិងស្រែប្រាំង
ពូជស្រូវ	-ស្រូវវស្សាផ្ការំដួល. -ស្រូវម្លិះ. -ស្រូវខា១១. -ស្រូវនាងគង់ខ្សាច់ -ស្រូវដំណើប -ស្រូវខា៣ -ស្រូវរាំងជ័យ -ស្រូវម្លិះក្រហម. -ស្រូវខា១៥ -ស្រូវប្រាំង៨៥. -ស្រូវ៧៥ -ស្រូវ៥១៥៤ -ស្រូវសែនក្រអូប -ស្រូវក្រមួន	-ស្រូវវស្សា ម្លិះខា១១ -ស្រូវនាងគង់ខ្សាច់ -ស្រូវប្រាំង៨៥. -ស្រូវ៧៥ -ស្រូវ៥១៥៤ -ស្រូវសែនក្រអូប -ស្រូវក្រមួន -ស្រូវ៤៩	-ស្រូវប្រាំង៨៥. -ស្រូវ៧៥. -ស្រូវ៥១៥៤ -ស្រូវ៤៩ -ស្រូវក្រមួន	-ស្រូវប្រាំង៨៥. -ស្រូវ៧៥. -ស្រូវ៥១៥៤ -ស្រូវ៤៩ -ស្រូវក្រមួន
ការប្រើប្រាស់ជី	**-ស្រូវវស្សា** -ជីគីមី DAP ១បេ/ha -ជីជប៉ុន ២បេ/ha -ជីអ៊ុយរេ ១បេ/ha -ជីធម្មជាតិ(ប្រើទ្រាប់បាត) ៤00គីឡូ/ha **-ស្រូវប្រាំង** -ជីគីមី DAP ២បេ/ha -ជីអ៊ុយរេ ២បេ/ha -ជីជប៉ុន៧៥គីឡូក្រាម/ha (ខាងលើថ្នល់)	**-ស្រូវវស្សា** -ជីគីមី DAP ១បេ/ha -ជីអ៊ុយរេ ១បេ/ha -ជីជម្រុះ ២បេ/ha -ជីធម្មជាតិ(ប្រើទ្រាប់បាត) -ប្រើអង្កាមស្រស់ **-ស្រូវប្រាំង** ជីគីមី DAP ៤បេ/ha -ជីអ៊ុយរេ ២បេ/ha -ជីជម្រុះ ១បេ/ha	**-ស្រូវប្រាំង** -ជីគីមី DAP ៤បេ/ha -ជីអ៊ុយរេ ២បេ/ha -ជីជម្រុះ ១បេ/ha	-ដំណាំឈូក ប្រើជីជម្រុះ ១បេ/ha
ការចិញ្ចឹមសត្វ	-ជ្រូក មាន់ ទា -គោ ក្របី -ចិញ្ចឹមត្រី -ចិញ្ចឹមក្រពើ(បីគ្រួសារនៅភូមិអំពិល) លោកឡាយ តុម លោកកាក់ហួរ. លោកវួន សុឃួន	-វាលស្មៅគោ ក្របី រដូវប្រាំង -ចិញ្ចឹមទា រដូវប្រាំង	-ច្រូតស្មៅគោ ក្របី រដូវវស្សា -ឃ្វាលគោ ក្របី រដូវប្រាំង	-ស្មៅគោ ក្របី
ដីរបស់រដ្ឋនិងសហគមន៍	-ដីប្រឡាយ -ដីផ្លូវ -ដីសាលារៀន	-ដីប្រឡាយ -ដីផ្លូវ	-ដីផ្លូវ -ដីព្រៃលិចទឹក -បឹង	-ដីព្រៃលិចទឹក -ព្រៃក -អូរ

	-ដីទួលអ្នកតា -ដីស្រះសហគមន៍ -ដីវត្ត -ដីបញ្ចុះសព -ដីសាលាឃុំ. ប៉ុស្តិ៍រដ្ឋបាល -ដីមណ្ឌលសុខភាព -ដីត្រពាំងចក -ទួលអ្នកតាទ្វារប្រាំបី (១២ha) -ដីទួលក្តីចាស -ដីទួលសំរោង -ដីទួលប៉ាលណាល -ដីទួលសូពុង	-អាងសហគមន៍ស្រែ ប្រាំង ៤អាង -ត្រពាំងកូនកុក -ត្រពាំងបឹងងួន -ត្រពាំងប្រនិតក្នុង -ត្រពាំងប្រនិតក្រៅ -ត្រពាំងកណ្តឹង -ត្រពាំងព្រៃសៀម -ត្រពាំងព្រះស្លែង -ត្រពាំងគេ -ត្រពាំងចក -ត្រពាំងខ្យូវ -ត្រពាំងក្របីរត់ -ត្រពាំងត្រដេវិច -ត្រពាំងត្រសកឪឡឹក -ត្រពាំងចម្ការក្នុង ក្រៅ -ត្រពាំងក្តោង -ត្រពាំងបង្គោលកី -ត្រពាំងបាក់ធ្មេញ -ត្រពាំងកំភួនមាន់ -ត្រពាំងមហាប្រា	-ត្រពាំង -ព្រៃក	-បឹង
បញ្ហាផ្សេងៗ	-ខ្វះទឹកស្រោចស្រព -ជង្គ្រួវស៊ីស្លឹក. ស៊ីដើម(ក្រា) -ជម្ងឺផ្សិត -ជម្ងឺផ្លាស់ -ដង្កូវបំពង់កាត់ស្លឹក -លិចដោយទឹកជំនន់ -ដីមិនរាបស្មើ -ស្រែមានស្មៅច្រើន -ត្រប់មានដង្កូវស៊ីត្រួយ -ជម្ងឺលឿងស្លឹកលើបន្លែ ត្រសក់. ល្ពៅ. ប៉េងប៉ោះ -ជម្ងឺផ្សិត -សត្វមាន់មានជម្ងឺហៀទឹក មាត់ ហើមភ្នែក អាសន្នរោគ -កើតជម្ងឺអ៊ុតក្តាមសាទឹក ខាន់ស្លាក់ -ផ្លូវពិបាកធ្វើដំណើរ -កសិករខ្វះដីធ្វើស្រែប្រាំង -ដីស្រែប្រាំងមួយចំនួនជាដី ក្នុងតំបន់ហាមឃាត់	-ជម្ងឺមមាចត្នោត -ដង្កូវស៊ីស្លឹក និងស៊ីដើម -ជម្ងឺផ្សិត -ជម្ងឺផ្លាស់ -មូសប្លុង -ដីស្រែមិនទានស្មើ -ជួបស្មៅកន្ទុយចចក -ប្រើប្រាស់ឧបករណ៍នេ សាទខុសច្បាប់ -គោក្របីស្លាប់នៅ តំបន់៉ ច្រើន -ខ្វះប្រព័ន្ធប្រឡាយជើង ក្អែប - ផ្លូវពិបាកធ្វើដំណើរ	-ជម្ងឺផ្សិត -ជម្ងឺផ្លាស់ -ជម្ងឺប្លុង -ស្មៅកន្ទុយក្ងោក -ការកាប់ព្រៃលិចទឹកយក ដី ធ្វើស្រែ -គោក្របីដែលយកទៅ ឃ្វាល ឈឺស្លាប់នៅច្រើន	-ឈូកកើតរោគមូស្លឹក -ប្រើប្រាស់ឧបករណ៍នេសាទ ខុសច្បាប់ -គោក្របីដែលយកទៅឃ្វាល ឈឺស្លាប់នៅច្រើន

	-ខ្វះបច្ចេកទេសផលិតកម្មដំណាំស្រូវ -ខ្វះបច្ចេកទេសផលិតពូជស្រូវ -មិនទាន់មានសហគមន៍កសិកម្ម -មិនទាន់មានសហគមន៍ប្រើប្រាស់ទឹក			
កាលានុវត្តភាព/ឱកាស	-កៀរពង្រាបដីស្រែឱ្យស្មើ -ពង្រីកការដាំដំណាំស្រូវឱ្យបាន២ទៅ៣ដងក្នុងមួយឆ្នាំ -ស្តារនិងសាងសង់ប្រឡាយជើងក្អែប -កែលម្អផ្លូវពីគ្រួសក្រហមទៅជាផ្លូវបេតុងកៅស៊ូ -ពង្រីកការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ -ពង្រីកការដាំបន្លែជាលក្ខណៈ គ្រួសារ	-កៀរពង្រាបដីស្រែឲ្យស្មើ -ពង្រីកការដាំដំណាំស្រូវឲ្យបាន២ទៅ៣ដងក្នុងមួយឆ្នាំ -ស្តារនិងសាងសង់ប្រឡាយ ជើងក្អែប -កែលម្អផ្លូវពីគ្រួសក្រហមទៅជាផ្លូវបេតុងកៅស៊ូ	-កៀរពង្រាបដីស្រែឱ្យស្មើ -ពង្រីកការដាំដំណាំស្រូវឱ្យបាន២ទៅ៣ដងក្នុងមួយឆ្នាំ -ស្តារនិងសាងសង់ប្រឡាយ ជើងក្អែប -ទប់ស្កាត់ការកាប់បំផ្លាញព្រៃ លិចទឹក -ទប់ស្កាតបទល្មើសនេសាទ	-ទប់ស្កាត់ការកាប់បំផ្លាញ ព្រៃលិចទឹក -ទប់ស្កាតបទល្មើសនេសាទ

ប្រភពទិន្នន័យ៖ *របាយការណ៍ក្សេត្រ-បរិស្ថាន និងក្រុមប្រឹក្សាឃុំសំព្រោជឆ្នាំ២០១៧*

បើយោងទៅតាមរបាយការណ៍ក្សេត្រ-បរិស្ថាន និងក្រុមប្រឹក្សាឃុំសំព្រោជ បានបង្ហាញឱ្យឃើញថា នៅក្នុងឃុំមានប្រភពទឹកសំខាន់ៗដូចជា៖ ទឹកភ្លៀង ទឹកប្រឡាយ ៣០កញ្ញា ទឹកអណ្តូងលូ ទឹកស្រះ ទឹកអណ្តូងស្នប់ បឹង អាងទឹក និងទឹកទន្លេសាប ព្រមទាំងមានប្រឡាយចំនួន២៤ខ្សែ ដែលនៅក្នុងនោះប្រឡាយមេមានចំនួន ៣ខ្សែ ប្រវែង ៧ ៦៧៤,២០ម៉ែត្រ ប្រឡាយរងចំនួន១ខ្សែ ប្រវែង ៤ ០៨៤,៧៣ម៉ែត្រ ប្រឡាយតូចៗចំនួន ២០ខ្សែ ប្រវែង៤១ ០១៨,១៨ម៉ែត្រ និងទ្វារស្ទាក់ទឹក ៨កន្លែង ចំណែកទឹកក្រោមដីនៅក្នុងឃុំ មានការប្រើប្រាស់តាមរយៈអណ្តូងស្នប់សម្រាប់ស្រោចស្រព និងសម្រាប់ការប្រើប្រាស់ទូទៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋប៉ុណ្ណោះ។ ប្រភពទឹកដែលនាំទឹកមកប្រើប្រាស់នៅក្នុងឃុំ មានតែរដូវវស្សាពីស្ទឹងស្ទោងតាមរយៈប្រឡាយមេនិងប្រឡាយរង ដែលឃុំបានជីក និងស្តារសម្រាប់នាំយកទឹកមកស្រោចស្រពនៅក្នុងភូមិសាស្ត្រស្រែវស្សា និងស្រែប្រាំង ក្រៅពីស្ទឹង ឃុំមានតែបឹង និងស្រះទឹក ដែលជាប្រភពទឹកបន្ទាប់បន្សំតែប៉ុណ្ណោះ ។

តារាង 17៖ ប្រព័ន្ធធារាសាស្ត្រ

ល.រ	**ប្រព័ន្ធធារាសាស្ត្រ**	**ប្រវែង(ម) ឆ្នាំ ២០១៧**	**ការពិពណ៌នា**
១	ប្រឡាយមេ	២ ១៥៥,៩៦	ចេញពីភូមិពន្លាជ័យ ឃុំបន្ទាយស្ទោង ធ្លាក់ដល់ ការិយាល័យពន្ធដារ ស្រុងស្ទោង
២	ប្រឡាយមេ	៣ ៤៥៩,៧៥	ប្រឡាយមេ ពីផ្លូវជាតិលេខ៦ក្បែរពន្ធដារ ស្រុកស្ទោងភូមិមឈាយក្បែរទួលសុពង្ស

៣	ប្រឡាយមេ	២ ០៥៨,៤៩	ភ្ជាប់ពីផ្លូវបំបែក ក្រវ៉ាត់ស្រុកស្ទោង ត្រង់ភូមិមឈាយ ធ្លាក់ទៅភូមិត្នោតគម
៤	ប្រឡាយរង	៤ ០៨៤,៧៣	ចេញពីប្រឡាយមេ ៣០កញ្ញា ឃុំសំព្រោជ កាត់ឃុំរុងរឿង ឃុំបន្ទាយស្ទោង ឃុំសំព្រោជ ធ្លាក់មកកាត់
៥	ប្រឡាយតូច	២ ៧៩៤,១៤	ស្នាមប្រឡាយចាស់ទ្រុឌទ្រោម ប្រឡាយទី៩ ពីភូមិបេង ទៅដល់ព្រំប្រទល់ឃុំសំព្រោជ ដល់ទួលក្តីចាស់
៦	ប្រឡាយតូច	២ ១៤៦,៤៨	ពីប្រឡាយខ្សែទី១ ដល់បឋមសិក្សា ត្រាចជ្រុំ
៧	ប្រឡាយតូច	២ ១៨៤,០៨	ពីផ្លូវជាតិលេខ ៦ ធ្លាក់ដល់ភូមិត្រាចជ្រុំ កាត់និងប្រឡាយទី១៨
៨	ប្រឡាយតូច	២ ៣៦១,២៧	ចេញពីប្រឡាយខ្សែទី១៣ ភូមិដូនល្អ កាត់ប្រឡាយខ្សែទី១ ដល់ក្រោយវត្តសំរោងសែនជ័យ
៩	ប្រឡាយតូច	៨៦០,៥៧	ចេញពីប្រឡាយខ្សែទី១១ ធ្លាក់ដល់ប្រឡាយខ្សែទី១៥ ភូមិដូនល្អ
១០	ប្រឡាយតូច	២ ៥៩០,៥៦	ពីម៉ុំទួលក្តីចាស់ ធ្លាក់មកកាត់ ប្រឡាយខ្សែទី១៨ និងឆ្ពោះទៅដល់ភូមិពៃ
១១	ប្រឡាយតូច	១ ៨៨៩,៨៧	ចេញពីទួលប្រាសាទ ព្រៃឥដ្ឋ ភូមិដូនល្អ ភូមិពៃ
១២	ប្រឡាយតូច	១ ២៩៣,៣៨	ពីភូមិសំព្រោជ ធ្លាក់ដល់ភូមិដូនល្អ
១៣	ប្រឡាយតូច	១ ០៥៥,៦៥	ពីប្រឡាយខ្សែទី៧ កាត់ប្រឡាយខ្សែទី១០ ឆ្ពោះទៅភូមិពត្លក
១៤	ប្រឡាយតូច	៥៩៣,៣២	ពីភូមិល្វា ឆ្ពោះទៅនឹងប្រឡាយខ្សែទី១១ ភូមិសំព្រោជ
១៥	ប្រឡាយតូច	៥ ០៥១,៤១	ប្រឡាយចាស់ទ្រុឌទ្រោម ចេញពីភូមិអំពិល ធ្លាក់ដីស្រែភូមិពៃ
១៦	ប្រឡាយតូច	២ ៦៤៧,១៥	ពីប្រឡាយខ្សែទី៧ កាត់វត្តល្វា ភូមិល្វា ដល់ក្បែរទួលក្តីចាស់ ភូមិស្លាក់ក្រាញ់
១៧	ប្រឡាយតូច	៤១៧,២៥	ប្រឡាយតូចជីក ក្រោយពន្ធដារ ស្រុកស្ទោងភូមិមឈាយ
១៨	ប្រឡាយតូច	៣២៤,៥៧	ពីប្រឡាយខ្សែទី៧ ភូមិត្នោតគម ទៅព្រំប្រទល់ឃុំកំពង់ចិនត្បូង
១៩	ប្រឡាយតូច	២ ១៧២,២០	ពី បំបែកចេញ ប្រឡាយខ្សែទី៣ ក្នុងភូមិមឈាយ ទៅដល់ភូមិអំពៅព្រៃ ភូមិពត្លក
២០	ប្រឡាយតូច	៥៩៦,៦៣	បំបែកចេញ ប្រឡាយខ្សែទី៤ ពីភូមិពន្លាជ័យ ឃុំបន្ទាយស្ទោង ដល់ឃុំទ្រា និងផ្លូវជាតិ
២១	ប្រឡាយតូច	១ ២៧០,៩១	ពីប្រឡាយខ្សែទី១១ ឆ្ពោះទៅភូមិដូនល្អ
២២	ប្រឡាយតូច	៤៧១,២៩	បំបែកចេញពីប្រឡាយខ្សែទី៧ កាត់ប្រឡាយខ្សែទី១២ និងទី១៣
២៣	ប្រឡាយតូច	៣ ៤៣២,៧៨	ភ្ជាប់ពីប្រឡាយមេទី៩ ភូមិត្នោតគម ធ្លាក់មកភូមិគោកស្វាយកាត់ទួលសូពង្ស ដីស្រែក្រោម
២៤	ប្រឡាយតូច	៦ ៨៦៤,៦៦	ភ្ជាប់ពីប្រឡាយបេតុង ទី១៤ ភូមិពត្លក ឆ្ពោះទៅភូមិពៃ ភូមិដូនល្អ រហូតដល់ដីស្រែក្រោម

ប្រភពទិន្នន័យៈ *ក្រុមការងារបច្ចេកទេស GIS អេស ប៊ី ខេ ឆ្នាំ២០១៨*

រូបភាព ៣៖ ប្រព័ន្ធធារាសាស្ត្រ

ប្រឡាយ	ប្រឡាយរង

ផែនទី 5៖ ផែនទីប្រព័ន្ធធារាសាស្ត្រ ឃុំសំព្រោជ



១.២.២.អាកាសធាតុ (ពិពណ៌នាតាមរដូវកាល)

នៅក្នុងឃុំសំព្រោជ ក៏ដូចជានៅទូទាំងខេត្ត គឺទទួលរបបខ្យល់មកពីតំបន់ត្រូពិច ដែលមានអាកាធាតុក្តៅហើយសើម ។ របបខ្យល់មូសុង គឺបាននាំនាំមកនូវចំនួនទឹកភ្លៀងយ៉ាងច្រើនមកជាមួយ ដែលអំណោយផលទៅដល់ការធ្វើកសិកម្មនានា និងដាំដំណាំផ្សេងៗទៀត ។

បើយោងទៅតាម ប្រភពទិន្នន័យពីមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ធំ ប្រចាំនៅស្រុកស្ទោងក្នុងឆ្នាំ ២០១៧ បានបង្ហាញឱ្យឃើញថា នៅក្នុងស្រុកស្ទោងទាំងមូលមានភ្លៀងធ្លាក់ចំនួន៨៩ដង និងមានបរិមាណទឹកភ្លៀងប្រចាំឆ្នាំចំនួន ១ ៤២០ម.ម ។

អំពីអាកាសធាតុ៖

- រដូវរងារ៖ ខែ វិច្ឆិកា ដល់ ខែ មីនា (២០ ទៅ ២៨ អង្សា)
- រដូវក្តៅ៖ ខែ មីនា ដល់ ខែ ឧសភា (៣០ ទៅ ៣៥ អង្សា)
- រដូវភ្លៀង៖ ខែ ឧសភា ដល់ ខែ តុលា (២៣ ទៅ ៣០ អង្សា ជាមួយនិងការឡើងសំណើមទៅដល់ ៩០ ភាគរយ)នៅរដូវនេះជារៀងរាល់ឆ្នាំ គឺមានភ្លៀងធ្លាក់ខ្លាំង នៅពេលរសៀល និងល្ងាច។

សំណើម៖ ឃុំសំព្រោជមានសំណើមជាមធ្យម៥៥ភាគរយ និងមានល្បឿនខ្យល់៣គីឡូម៉ែត្រ/១ម៉ោង។

តារាង 18៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ

ខែ	មករា	កុម្ភៈ	មីនា	មេសា	ឧសភា	មិថុនា	កក្កដា	សីហា	កញ្ញា	តុលា	វិច្ឆិកា	ធ្នូ
បរិមាណទឹកភ្លៀង	០	០	១៨,៧	១១,៦	២៩៥	១៥៣,៣	៩៩	២៣៤	៧៩,៥	២១,៨	៩៩,៩	១,៧
ចំនួនថ្ងៃមានភ្លៀងធ្លាក់	០	០	២	៦	១៣	៨	៩	៩	៣	៩	១២	២

ប្រភពទិន្នន័យ៖ *មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ធំ ឆ្នាំ២០១៧*

ដ្យាក្រាម 3៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ



ប្រភពទិន្នន័យ៖ *មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ធំ ឆ្នាំ២០១៧*

១.២.៣.ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន

ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍រួមមាន ផ្លូវគោក ផ្លូវដែក ផ្លូវទឹក និងផ្លូវអាកាស ។ បច្ចុប្បន្នឃុំសំព្រោជមានតែប្រព័ន្ធគមនាគមន៍ផ្លូវគោក ហើយបានដើរតួយ៉ាងសំខាន់ក្នុងការសម្រួលដល់ការដឹកជញ្ជូន និងការធ្វើដំណើររបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ដែលក្នុងនោះមានផ្លូវជាតិលេខ៦ឆ្លងកាត់ ដែលមានប្រវែង ៤ ៣៣៦,៩៤ម៉ែត្រពីព្រំប្រទល់ចំណាក្រោម ឆ្ពោះទៅឃុំកំពង់ចិនត្បូងនិងឃុំទ្រា និងផ្លូវគ្រួសក្រហមចំនួន១ខ្សែទៀត ប្រវែង ២ ៤៧៨,៩៥ ម៉ែត្រ ចេញពីផ្លូវជាតិលេខ៦ កាត់វត្តល្វារួចឆ្ពោះទៅភូមិសំព្រោជ និងមកទល់វត្តជុនល្អ ផ្លូវទាំង២នេះគឺជាច្រកចេញ-ចូលសំខាន់របស់ឃុំ និងមានផ្លូវក្នុងឃុំផ្សេងៗគ្រប់គ្រាន់អាចតភ្ជាប់ទំនាក់ទំនងពីភូមិមួយទៅភូមិមួយ រួមទាំងអាចទំនាក់ទំនងទៅក្រៅឃុំបានយ៉ាងងាយស្រួល ។

នៅក្នុងឃុំសំព្រោជ មានផ្លូវចំនួន ៩៤ខ្សែ មានប្រវែងផ្លូវសរុប ចំនួន ១១១ ០០៧ម៉ែត្រ ដែលនៅក្នុងនោះផ្លូវក្រាលកៅស៊ូមានចំនួន១ខ្សែ ប្រវែង ៤ ៣៣៧ម៉ែត្រ ផ្លូវក្រាលគ្រួសក្រហម១៨ខ្សែ មានប្រវែង ១៨ ៤៥៨ម៉ែត្រ និងផ្លូវលំដីសមាន៧៥ខ្សែ ប្រវែង ៨៨ ២១២ម៉ែត្រ ។

តារាង 19៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន

ល.រ	ប្រភេទផ្លូវ	ចំនួនខ្សែផ្លូវ	ប្រវែង (ម៉ែត្រ)
១	ផ្លូវចាក់កៅស៊ូ	១	៤ ៣៣៦,៩៤
២	ផ្លូវគ្រួសក្រហម ឬក្រាលថ្ម	១៨	១៨ ៤៥៨,១៦
៣	ផ្លូវដីស ឬផ្លូវរទេះ	៧៥	៨៨ ២១២,៣៦

ប្រភពទិន្នន័យ៖ *ក្រុមការងារបច្ចេកទេស GIS អេស ប៊ី ខេ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨*

រូបភាព 4៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន

ផ្លូវកៅស៊ូ

ផ្លូវលំ

ផ្លូវគ្រួសក្រហម

ផែនទី ៦៖ ផែនទីហេដ្ឋារចនាសម្ព័ន្ធ ឃុំសំព្រោជ



១.២.៤.បរិក្ខាសាធារណៈ

ក. ស្ថានភាពប្រើប្រាស់អគ្គិសនី

បេសកកម្មរបស់មន្ទីររ៉ែ និងថាមពលខេត្តកំពង់ធំ គឺដឹកនាំជំរុញការគ្រប់គ្រង និងសមាហរណកម្មលើវិស័យរ៉ែ និងថាមពលរួមទាំងប្រេងកាត ឧស្ម័ន និងអគ្គិសនី ក្នុងសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ចសង្គម នៅមូលដ្ឋាន និងក្នុងខេត្តកំពង់ធំ ក្នុងនាមជាសេធិការឱ្យក្រសួងរ៉ែ និងថាមពល ។

យោងទៅតាមទិន្នន័យពីមន្ទីរផែនការខេត្តកំពង់ធំនៅក្នុងឆ្នាំ២០១៧ បានបង្ហាញឱ្យឃើញថា នៅក្នុងឃុំសំព្រោជ ប្រជាពលរដ្ឋប្រើប្រាស់បណ្តាញអគ្គិសនីមានចំនួន ១ ៧០៧ខ្នងផ្ទះ ស្មើនឹង៦៦,២ភាគរយ ផ្ទះបំភ្លឺដោយអាគុយមានចំនួន៤០២ខ្នងផ្ទះ ស្មើនឹង១៥,៦ភាគរយ ផ្ទះបន្ទះសូឡាមានចំនួន៤២ខ្នងផ្ទះ ស្មើនឹង១,៦ភាគរយ ។យោងទៅតាមទិន្នន័យខាងក្រោមបានបង្ហាញថា ប្រជាពលរដ្ឋភាគច្រើនមានបណ្តាញអគ្គិសនីប្រើប្រាស់។

តារាង 20៖ ស្ថិតិអ្នកប្រើប្រាស់អគ្គិសនី

បរិយាយ	**២០១៦(%)**	**២០១៧**	
		ភាគរយ(%)	**ចំនួនផ្ទះ**
ផ្ទះបំភ្លឺដោយបណ្តាញអគ្គិសនី	២១,៥	៦៦,២	១ ៧០៧
ផ្ទះបំភ្លឺដោយអាគុយ	៦៣,១	១៥,៦	៤០២
ផ្ទះបំភ្លឺដោយបន្ទះសូឡា	១,៥	១,៦	៤២

ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨

ខ. ប្រព័ន្ធទឹកស្អាត

អាជ្ញាធរខេត្តកំពង់ធំ បានអំពាវនាវឲ្យប្រជាពលរដ្ឋ ដែលធ្លាប់ប្រើប្រាស់ទឹកស្ទឹង ត្រពាំង ឬអណ្តូងដៃ ងាកមកបរិភោគទឹកស្អាតវិញ ដើម្បីជួយលើកកម្ពស់សុខភាព និងលើកស្ទួយអនាម័យនៅជនបទ។ នៅក្នុងឃុំសំព្រោជ បានចំណាយថវិកាមូលនិធិឃុំ ក៏បានគៀរគរធនធានពីខាងក្រៅក្នុងការសាងសង់ដូចជា៖ អណ្តូងស្នប់ឬអណ្តូងចម្រុះមានចំនួន៨៧អណ្តូង អណ្តូងជីកមានការពារចំនួន៣៦អណ្តូង និងអណ្តូងជីកគ្មានការពារមានចំនួន១២០អណ្តូង ចំនួនស្រះទឹកដែលប្រើប្រាស់ មានចំនួន៥១៩គ្រួសារ ហើយនៅក្នុងនោះចំនួនស្រះទឹកដែលប្រើប្រាស់មានចំនួនច្រើនជាគេ និងអណ្តូងជីកមានការពារមានចំនួនតិចជាងគេ ។

តារាង 21៖ ស្ថិតិប្រភពទឹកប្រើប្រាស់

ល.រ	**បរិយាយ**	**២០១៦**	**២០១៧**
១	ចំនួនអណ្តូងស្នប់ឬអណ្តូងចម្រុះ	៥	៨៧អណ្តូង
២	ចំនួនអណ្តូងជីកមានការពារ	៤៩	៣៦អណ្តូង
៣	ចំនួនអណ្តូងជីកគ្មានការពារ	៣៥	១២០អណ្តូង
៤	ចំនួនស្រះទឹកដែលប្រើប្រាស់	៤០៨	៥១៩នាក់

ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨

១.៣. ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

១.៣.១. ស្ថានភាពការកាន់កាប់ និងគ្រប់គ្រង

ផែនទី 7៖ ផែនទីប្រើប្រាស់ដីសាមញ្ញ ឃុំសំព្រោជ



ផែនទី ៨៖ ផែនទីប្រើប្រាស់ដីលម្អិត ឃុំសំព្រោជ



តារាង 22៖ តារាងរាយលម្អិតតាមប្រភេទនៃការប្រើប្រាស់ដីបច្ចុប្បន្ន ឃុំសំព្រោជ

ប្រភេទប្រើប្រាស់ដី	បរិយាយ	ផ្ទៃដី (ហិកតា)	ភាគរយ(%)
ក,ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ		**២៥១,០១**	**១,១២%**
-ដីលំនៅដ្ឋានភូមិក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប	កន្លែងសង់លំនៅឋាន	៨០	០,៣៦%
-ដីលំនៅដ្ឋានភូមិតំបន់១ជុំវិញបឹងទន្លេសាប	កន្លែងសង់លំនៅឋាន	១៧០	០,៧៦%
ខ.ដីកសិកម្ម		**៩ ៧៣៨,០១**	**៤៤%**
ខ.១.ដីស្រែវស្សា		**២ ៩០១,០១**	**១៣%**
-ដីស្រែវស្សាក្រៅតំបន់ជុំវិញបឹងទន្លេសាប	កន្លែងធ្វើស្រែវស្សា	៥៤០,៣	២,៤១%
-ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប	កន្លែងធ្វើស្រែវស្សា	២ ៣០០	១០,២៨%
-ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប	កន្លែងធ្វើស្រែវស្សា	៦០,៧១	០,២៧%
ខ.២.ដីស្រែប្រាំង		**៤ ៨៥០**	**២១,៦៨%**
-ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប	កន្លែងធ្វើស្រែប្រាំង	៤ ៥០០	២០,១១%
-ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប	កន្លែងធ្វើស្រែប្រាំង	៣៥០	១,៥៦%
ខ.៣.ដីស្រែប្រាំង និងស្រែវស្សា		**១ ៩៨៧**	**៩%**
-ដីស្រែប្រាំង និងស្រែវស្សាតំបន់១ជុំវិញបឹងទន្លេសាប	ធ្វើស្រែប្រាំងនិងវស្សា	៨៧,១២	០,៣៩%
-ដីស្រែប្រាំង និងស្រែវស្សាតំបន់២ជុំវិញបឹងទន្លេសាប	ធ្វើស្រែប្រាំងនិងវស្សា	១ ៩០០	៨,៤៩%
គ.ដីព្រៃ/គម្របព្រៃ		**៩ ០១៨,៥៣**	**៤០,៣១%**
-ព្រៃគុម្ពោត	ព្រៃដុះរប៉ាត់រប៉ាយ	៧,១	០,០៣%
-ព្រៃលិចទឹក	កន្លែងព្រៃលិចទឹក	៩ ០១១,៤៣	៤០,២៨%
ឃ.ផ្ទៃទឹកនិងខ្សែទឹក		**៣ ៣៦៧**	**១៥,០៥%**
-ទន្លេមានទឹកជាអចិន្ត្រៃយ៍	ប្រភពទឹកស្រោចស្រព	២៤០	១,០៧%
-ស្ទឹងមានទឹកតាមរដូវ	កន្លែងផ្គត់ផ្គង់ទឹកប្រើប្រាស់	៥,០១	០,០២%
-ស្រះ	កន្លែងផ្គត់ផ្គង់ទឹកប្រើប្រាស់	១៩,៨៨	០,០៩%
-បឹង	កន្លែងផ្គត់ផ្គង់ទឹកប្រើប្រាស់	១ ០០២,៣២	៤,៤៨%
-អាងស្តុកទឹក	រក្សាទុកទឹកនៅរដូវវស្សា	២ ១០០	៩,៣៩%
ផ្ទៃដីឃុំសរុប		**២២ ៣៧៤**	**១០០%**

ក. ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ

-ដីលំនៅឋាន ភូមិ៖

ដីលំនៅឋាន ភូមិ គឺជាដីត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានមានលាយសួនដំណាំ និងឈើហូបផ្លែ នៅជុំវិញ។ នៅពេលបច្ចុប្បន្នដីលំនៅឋាន ភូមិនៅក្នុងឃុំសំព្រោជមានទំហំផ្ទៃដីសរុបចំនួន ២៥០ហិកតា ភាគច្រើនស្ថិតនៅភាគខាងត្បូងផ្លូវជាតិលេខ៦និងមានចំនួនតិចតួចស្ថិតនៅភាគខាងជើងផ្លូវជាតិ ដែលនៅក្នុងបច្ចុប្បន្ននេះបាននិងកំពុងប្រើប្រាស់ជាដីលំនៅឋាន ភូមិ ហើយស្ថិតនៅតាម០២ផ្សេងគ្នា គឺក្រៅតំបន់ការពារ និងតំបន់១ជុំវិញបឹងទន្លេសាប ដូចមានរៀបរាប់ខាងក្រោម៖

-ដីលំនៅឋាន ភូមិក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប

ដីលំនៅឋាន ភូមិក្រៅតំបន់ការពារជុំវិញបឹងទន្លេសាបមាន មានទំហំផ្ទៃដីសរុបចំនួន ៨០ ហិកតា ស្ថិតនៅខាងជើងផ្លូវជាតិលេខ៦ ក្នុងនោះមានចំនួន៤ភូមិ គឺភូមិស្លាក់ក្រាញ់ ភូមិប្រឌិត ភូមិអំពិល និងភូមិមឈាយ ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំសំព្រោជនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីលំនៅឋាន ភូមិទាំងអស់ ជាតំបន់ទំនាបមធ្យម ដីល្បាយខ្សាច់ពណ៌ក្រហម និងក្រម៉ៅ(ដីប្រទះឡាង បាកាន) ជាដីដែលកាន់កាប់ដោយប្រជាពលរដ្ឋ (ដីកម្មសិទ្ធិឯកជន) ត្រូវបានចុះបញ្ជីជាលក្ខណៈប្រព័ន្ធបានចំនួន ៣០ ភាគរយហើយ ។

-ដីលំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប

ដីលំនៅឋាន ភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាបមាន មានទំហំផ្ទៃដីសរុបចំនួន ១៧០ហិកតា ស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៦ ក្នុងនោះមានចំនួន១២ភូមិ គឺភូមិត្រាចជ្រុំ ភូមិចំបក់ខ្ពស់ ភូមិអំពៅពៃ ភូមិស្រះពត្លុក ភូមិល្វា ភូមិត្នោតគម ភូមិអូររំចេក ភូមិដូនល្អ ភូមិគោកស្នាយ ភូមិសំព្រោជ ភូមិក្រសាំងជ្រុំជើង និងភូមិក្រសាំងជ្រុំត្បូង។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំសំព្រោជ នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីលំនៅឋាន ភូមិទាំងអស់ ជាតំបន់ទំនាបមធ្យម ដីល្បាយខ្សាច់ពណ៌ក្រហម និងក្រម៉ៅ(ដីប្រទះឡាង បាកាន)ជាដីដែលកាន់កាប់ដោយប្រជាពលរដ្ឋ (ដីកម្មសិទ្ធិឯកជន) ត្រូវបានចុះបញ្ជីជាលក្ខណៈប្រព័ន្ធបានចំនួន ៣០ ភាគរយហើយ ។

រូបភាព 5៖ លំនៅឋានភូមិ

លំនៅឋានភូមិ	លំនៅឋានភូមិ

ខ. ដីកសិកម្ម

ខ.១. ដីស្រែវស្សា៖

នៅពេលបច្ចុប្បន្ននេះដីស្រែវស្សា នៅក្នុងឃុំសំព្រោជមានទំហំផ្ទៃដីសរុបចំនួន ២ ៩០១,០១ ហិកតា ភាគច្រើនស្ថិតនៅភាគខាងលិចផ្លូវជាតិលេខ៦និងមានចំនួនតិចតួចស្ថិតនៅភាគខាងកើតផ្លូវជាតិ ដែលនៅក្នុង

បច្ចុប្បន្ននេះបាននិងកំពុងប្រើប្រាស់ជាដីស្រែវស្សា ហើយស្ថិតនៅ៣តំបន់ផ្សេងគ្នា គឺនៅក្រៅតំបន់ការពារ តំបន់១ និងតំបន់២ ដូចមានរៀបរាប់ខាងក្រោម៖

-ដីស្រែវស្សាក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប

ដីស្រែវស្សាក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីសរុបចំនួន ៥៤០,៣ ហិកតា ក្នុងនោះមានដីកប់ខ្មោចចំនួនពីរកន្លែង ដែលមានទំហំ១,០១ហិកតា ស្ថិតនៅភាគខាងកើតផ្លូវជាតិលេខ៦ ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំសំព្រោជនៃរបាយការណ៍វិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានសង្កាត់នេះដីស្រែវស្សាទាំងនេះ ជាតំបន់វាលទំនាបទាប មានដីជាប្រភេទដីល្បាយខ្សាច់ពណ៌ក្រហម និងក្រម៉ៅ(ដីប្រទះឡាង បាកាន) ប្រផេះ ជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់ដោយប្រជាពលរដ្ឋ ហើយកំពុងតែដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធបានចំនួន៣០ភាគរយ ។ ដីស្រែវស្សាទាំងនេះមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង អាង៣០កញ្ញា ទឹកជំនន់ ទឹកទន្លេសាប បឹង និងអាងស្តុក ។

-ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប

ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានទំហំផ្ទៃដីសរុបចំនួន ២ ៣០០ ហិកតា ដែលស្ថិតនៅភាគខាងលិចផ្លូវជាតិលេខ៦ ហើយក្នុងនោះមានដីទួលបុរាណឬទួលអ្នកតា ចំនួន៨ទួល ដែលស្ថិតនៅក្នុងតំបន់ដីស្រែវស្សាតំបន់១នេះផងដែរ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំសំព្រោជនៃរបាយការណ៍វិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានសង្កាត់នេះដីស្រែវស្សាទាំងនេះ ជាតំបន់វាលទំនាបទាប មានដីជាប្រភេទដីល្បាយខ្សាច់ពណ៌ក្រហម និងក្រម៉ៅ(ដីប្រទះឡាង បាកាន)ប្រផេះ ជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់ដោយប្រជាពលរដ្ឋ ហើយកំពុងតែដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធបានចំនួន ៣០ភាគរយ លើកលែងតែដីទួលបុរាណឬទួលអ្នកតា ដែលជាដីកម្មសិទ្ធិរបស់រដ្ឋ ។ ដីស្រែវស្សាទាំងនេះមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង អាង៣០កញ្ញា ទឹកជំនន់ ទឹកទន្លេសាប បឹង និងអាងស្តុក ។

-ដីស្រែវស្សាក្នុងតំបន់២ ជុំវិញបឹងទន្លេសាប

ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានទំហំផ្ទៃដីសរុបចំនួន ៦០,៧១ ហិកតា ស្ថិតនៅភាគខាងត្បូងនៃឃុំបន្តពីដីស្រែវស្សាតំបន់១ជុំវិញបឹងទន្លេសាប ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំសំព្រោជនៃរបាយការណ៍វិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានសង្កាត់នេះដីស្រែវស្សាទាំងនេះ ជាតំបន់វាលទំនាបទាប មានដីជាប្រភេទដីល្បាយខ្សាច់ពណ៌ក្រហម និងក្រម៉ៅ(ដីប្រទះឡាង បាកាន)ប្រផេះ ជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់ដោយប្រជាពលរដ្ឋ ហើយកំពុងតែដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធបានចំនួន ៣០% ។ ដីស្រែវស្សាទាំងនេះមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង អាង៣០កញ្ញា ទឹកជំនន់ ទឹកទន្លេសាប បឹង និងអាងស្តុក។

រូបភាព 6៖ ដីស្រែវស្សា

ខ.២. ដីស្រែប្រាំង៖

នៅពេលបច្ចុប្បន្ននេះដីស្រែប្រាំង ក្នុងឃុំសំព្រោជមានទំហំផ្ទៃដីសរុបចំនួន ៤ ៨៥០ ហិកតា ស្ថិតនៅភាគខាងលិចផ្លូវជាតិលេខ៦បន្តពីដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប ដែលនៅក្នុងបច្ចុប្បន្ននេះបាននិងកំពុងប្រើប្រាស់ជាដីស្រែប្រាំង ហើយស្ថិតនៅតាម២ផ្សេងគ្នា គឺតំបន់២ និងតំបន់៣ជុំវិញបឹងទន្លេសាបដូចមានរៀបរាប់ខាងក្រោម៖

-ដីស្រែប្រាំងក្នុងតំបន់២ ជុំវិញបឹងទន្លេសាប

ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប ដែលមានទំហំផ្ទៃដីសរុប៤ ៥០០ ហិកតា ស្ថិតនៅភាគខាងលិចផ្លូវជាតិលេខ៦ ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំសំព្រោជ នៃរបាយការណ៍វិភាគប្រព័ន្ធកេ្សត្រ- បរិស្ថាន ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាតំបន់វាលទំនាបទាប ប្រភេទដីកណ្តេងពណ៌ខ្មៅ ក្រហមប្រផេះ (បាកាន.ក្បាលពោធិ៍ ក្រគរ) ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ ។ ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាបនេះ មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ទឹកប្រឡាយ៣០កញ្ញា បឹង អាងទឹក និងទឹកទន្លេសាប។

-ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប

ដីស្រែប្រាំងនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ស្ថិតក្នុងតំបន់កាពារព្រៃលិចទឹក នៅភាគខាងត្បូងនៃឃុំមានផ្ទៃដីសរុបចំនួន ៣៥០ហិកតា ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំសំព្រោជនៃរបាយការណ៍វិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប គឺជាតំបន់វាលទំនាបទាប ប្រភេទដីកណ្តេងពណ៌ខ្មៅ ក្រហមប្រផេះ(បាកាន.ក្បាលពោធិ៍ ក្រគរ) ជាដីសាធារណៈរបស់រដ្ឋ ស្ថិតក្នុងតំបន់ដែនព្រៃលិចទឹក ដែលហាមការកាប់រានដី ការដុតបំផ្លាញ ការរំលោភកាន់កាប់ដីព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប និងការសាងសង់សំណង់ថ្មីៗគ្រប់ប្រភេទបន្ថែមទៀត ។ នៅក្នុងករណីដីស្រែប្រាំងនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាបនេះ ជាដីអាស្រ័យផលពិតប្រាកដរបស់ប្រជាពលរដ្ឋ ដែលរស់ក្នុងឃុំសំព្រោជមែន ត្រូវស្នើសុំធ្វើការដោះស្រាយក្នុងការផ្តល់ដីស្រែក្នុងតំបន់នេះ ពីរាជរដ្ឋាភិបាល ដោយឈរលើឯកសារលិខិត បទដ្ឋានគតិយុត្តិ និងបទបញ្ជានានារបស់រាជរដ្ឋាភិបាល ហើយប្រសិនបើមានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យធ្វៀលដីនេះជូនមែន ក៏ដីទាំងនេះមិនមែនជាកម្មសិទ្ធិរបស់ប្រជាជនដែរ ប្រជាជនគ្រាន់តែអាចមានសិទ្ធិកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ ។ ដីស្រែប្រាំងនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាប មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង បឹង អាងទឹក និងទឹកទន្លេសាប ។

រូបភាព 7៖ ស្រែប្រាំង

ទិដ្ឋភាពស្រែប្រាំងតំបន់២	ទិដ្ឋភាពស្រែប្រាំងតំបន់៣

ខ.៣. ដីស្រែប្រាំង និងស្រែវស្សា៖

ដីស្រែប្រាំងស្ថិតនៅកណ្តាលឃុំ ចន្លោះតំបន់ស្រែវស្សា និងស្រែប្រាំង ជាតំបន់វាលទំនាបទាបជម្រាលស្មើ ប្រភេទដីកណ្តោងពណ៌ខ្មៅ ក្រហមប្រផេះ(បាកាន ក្បាលពោធិ៍ ក្រគរ) ត្រូវបានប្រើប្រាស់សម្រាប់ដំណាំស្រូវប្រាំង និងវស្សា ដោយពឹងផ្អែកលើទឹកភ្លៀងទទួលការស្រោចស្រពហើយទឹកប្រឡាយ៣០កញ្ញា បឹង ត្រពាំង និងអាងទឹក ដីស្រែវស្សាមានទំហំផ្ទៃដី ២ ៩០១,៥៣ហិកតា ត្រូវបានកាន់កាប់ដោយប្រពលរដ្ឋ (ដីកម្មសិទ្ធិឯកជន) ហើយត្រូវបានចុះបញ្ជីកាន់កាប់រួចរាល់៣០ភាគរយ ។

បច្ចុប្បន្ននេះ ដីស្រែប្រាំងនិងស្រែវស្សាក្នុងឃុំសំព្រោជមានពីរកន្លែង ដែលមានទំហំផ្ទៃដីសរុបចំនួន ១ ៩៨៧,១២ហិកតា ស្ថិតនៅភាគខាងត្បូងផ្លូវជាតិលេខ៦ដូចគ្នា ដែលនៅក្នុងបច្ចុប្បន្ននេះបាននិងកំពុងប្រើប្រាស់ជាដីស្រែប្រាំងនិងស្រែវស្សា ហើយស្ថិតនៅតាម ០២ តំបន់ផ្សេងគ្នា គឺតំបន់១ និងតំបន់២ ជុំវិញបឹងទន្លេសាប ដូចមានរៀបរាប់ខាងក្រោម៖

-ដីស្រែប្រាំងនិង ស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប

ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានទំហំផ្ទៃដីសរុបចំនួន ៨៧,១២ ហិកតា ស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៦ ហើយក្នុងនោះ មានក៏មានដីទួលបុរាណឬទួលអ្នកតាចំនួន២ ដែលស្ថិតក្នុងតំបន់ស្រែប្រាំងនិងវស្សា ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំសំព្រោជ នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែប្រាំងនិងស្រែវស្សាទាំងនេះ ជាតំបន់ទំនាបទាប ដែលមានប្រភេទដីកណ្តោងពណ៌ខ្មៅ ក្រហមប្រផេះ (បាកាន ក្បាលពោធិ៍ ក្រគរ) ជាដីកម្មសិទ្ធិឯកជន ដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ និងត្រូវបានកំពុងដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធបានចំនួន៣០ភាគរយ លើកលែងតែដីទួលបុរាណឬដីទួលអ្នកតា ដែលជាដីកម្មសិទ្ធិរបស់រដ្ឋ ។ ដីស្រែប្រាំងនិងស្រែវស្សាទាំងនេះ មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ទឹកទន្លេសាប អាងស្តុកទឹក និងទឹកបឹង ។

-ដីស្រែប្រាំងនិង ស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប

ដីស្រែប្រាំង និងស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានទំហំផ្ទៃដីសរុបចំនួន ១ ៩០០ ហិកតា ស្ថិតនៅខាងត្បូងដីតំបន់១ជុំវិញបឹងទន្លេសាប ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងសំព្រោជនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាតំបន់ទំនាបទាប ដែលមានប្រភេទដីកណ្តោងពណ៌ខ្មៅ ក្រហមប្រផេះ(បាកាន ក្បាលពោធិ៍ ក្រគរ) ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធចាត់ចែងនោះឡើយ ។ ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ទឹកទន្លេសាប អាងស្តុកទឹក និងទឹកបឹង ។

រូបភាព ៨៖ ស្រូវប្រាំង និងស្រូវវស្សា

ទិដ្ឋភាពស្រូវកំពុងចេញផ្កា	ទិដ្ឋភាពស្រូវកំពុងផ្លែ

គ. ព្រៃលិចទឹក៖

-ព្រៃគុម្ពោត៖

ដីព្រៃគុម្ពោត គឺជាដីទួលមានទំហំតូចៗនៅតាមក្បាលដីស្រែ ដែលបច្ចុប្បន្នត្រូវបាននិងកំពុងប្រើប្រាស់សម្រាប់ដីព្រៃគម្ពោតរេចរិល ដើម្បីទុកជាកន្លែងផ្តល់ស្មៅ និងស្លឹកឈើចំណីសត្វ និងជាកន្លែងផ្តល់ឧសដុតចម្អិនអាហារ ដែលមានសំបូរភាគច្រើនទៅដោយដើមខ្ទុង ត្បែងនិងដើមឈើមួយចំនួនទៀត ។ ដីព្រៃគុម្ពោត គឺជាដីដែលកាន់កាប់ដោយប្រជាពលរដ្ឋ(កម្មសិទ្ធិឯកជន) មានទំហំផ្ទៃដីចំនួន ៧,១ហិកតា ជាដីទួលបុរាណចំនួន១៤ទួល   ដីព្រៃគម្ពោតនេះភាគច្រើនស្ថិតលើទីតាំងដីក្នុងតំបន់ស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប និងមានតិចតួចនៅក្រៅតំបន់ជុំវិញបឹងទន្លេសាប ជាប្រភេទដីកណ្តេងពណ៌ខ្មៅ ក្រហមប្រផេះ(បាកាន ក្បាលពោធិ៍ ក្រគរ)។

រូបភាព 9៖ ព្រៃគុម្ពោត

-ព្រៃលិចទឹក

នៅក្នុងឃុំសំព្រោជ ព្រៃលិចទឹកមានផ្ទៃដីសរុបទំហំ ៩ ០១១,៤៣ហិកតា   ស្ថិតនៅភាគចុងត្បូងនៃឃុំជាប់បឹងទន្លេសាប ជាតំបន់ការពារព្រៃលិចទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ដែលសម្បូរទៅដោយដើមឈើចម្រុះដុះលាយឡំគ្នាដូចជា៖ ដើមភ្នំភ្លើង ត្រស់ កប្បាសព្រៃ ស្មាច់ និងដើមរាំងជាដើម ។ ដីព្រៃលិចទឹកនេះ គឺ

ជាដីសាធារណៈរបស់រដ្ឋ ដែលហាមដាច់ខាតការកាប់រាន ការដុតបំផ្លាញ ការរំលោភកាន់កាប់ដីព្រៃលិចទឹក និងការសាងសង់សំណង់គ្រប់ប្រភេទ ។

រូបភាព 10៖ ព្រៃលិចទឹក

ឃ. ផ្ទៃទឹក និងខ្សែទឹក

-ទន្លេមានទឹកជាអចិន្ត្រៃយ៍

នៅក្នុងឃុំសំព្រោជ មានបឹងទន្លេសាប បានហូរកាត់ឃុំសំព្រោជនៅភាគខាងត្បូង ឆៀងខាងលិចត្រង់ព្រំប្រទល់ឃុំ ដែលមានផ្ទៃដីចំនួន ២៤០ហិកតា នៅពេលរដូវវស្សាបឹងទន្លេសាបបាននាំទឹកជំនន់ធ្វើឱ្យលិចតំបន់ខាងត្បូងនៃឃុំនិងរហូតដល់ភាគកណ្តាលឃុំ ហើយបឹងទន្លេសាបនេះជាប្រភពទឹកស្រោចស្រព និងប្រភពជលផលយ៉ាងសំខាន់ក្នុងជីវភាពរស់នៅរបស់ប្រជាជននៅក្នុងឃុំសំព្រោជ ។

រូបភាព 11៖ ទន្លេមានទឹកជាអចិន្ត្រៃយ៍

-ស្ទឹងមានទឹកតាមរដូវ

ឃុំសំព្រោជ មានស្ទឹងមួយខ្សែគឺស្ទឹងស្ទោង មានទំហំ៥,០១ហិកតា ដែលហូរកាត់ឃុំនៅភាគខាងជើងត្រង់ព្រំប្រទល់ឃុំ ហើយមានទឹកតែនៅរដូវវស្សា និងរដូវប្រាំងវិញមានទឹកតិចតួចប៉ុណ្ណោះ មិនអាចផ្គត់ផ្គង់សម្រាប់ការស្រោចស្រពបានគ្រប់គ្រាន់នោះទេ។ ស្ទឹងនេះ គឺជាដីសាធារណៈរបស់រដ្ឋ និងជាប្រភពទឹកដ៏សំខាន់សម្រាប់ស្រោចស្រពដំណាំស្រូវ និងដំណាំផ្សេងៗទៀតរបស់ប្រជាពលរដ្ឋក្នុងឃុំ ព្រមទាំងជាប្រភពធនធានជលផលដ៏សំខាន់ក្នុងឃុំសំព្រោជនេះផងដែរ ។

រូបភាព 12 ៖ ស្ទឹងមានទឹកតាមរដូវ

-ស្រះទឹក

នៅក្នុងឃុំសំព្រោជ មានស្រះទឹកច្រើនគួរសម ដែលស្ថិតនៅក្នុងតាមដីលំនៅឋានមួយចំនួន និងតំបន់ស្រែប្រាំង និងស្រែវស្សាក្នុងតំបន់១និង២ជុំវិញបឹងទន្លេសាបមួយចំនួនទៀត មានផ្ទៃដីទំហំសរុបចំនួន ១៩,៨៨ ហិកតា ។ បច្ចុប្បន្នស្រះទាំងនេះ ត្រូវបានប្រើប្រាស់សម្រាប់ជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់ផ្សេងៗទៀតតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ។

រូបភាព 13៖ ស្រះទឹក

-បឹង៖

ឃុំសំព្រោជ សម្បូរទៅដោយបឹងជាច្រើន ដែលមានភាគច្រើននៅក្នុងតំបន់ស្រែប្រាំង និងតំបន់ព្រៃលិចទឹក ដែលមានផ្ទៃបឹងទំហំសរុបចំនួន ១ ០០២,៣២ហិកតា ។ បឹងធម្មជាតិទាំងអស់នេះ ជាដីសាធារណៈរបស់រដ្ឋ បច្ចុប្បន្នត្រូវបានប្រើប្រាស់សម្រាប់ការស្រោចស្រពដំណាំកសិកម្ម ជាពិសេសស្រែប្រាំង និងប្រើប្រាស់ផ្សេងៗទៀត ទៅតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ។

រូបភាព 14៖ បឹង

-អាងស្តុកទឹក

ឃុំសំព្រោជ មានអាងស្តុកទឹកជាច្រើនកន្លែង ដែលមានទំហំ ២ ១០០ហិកតា ស្ថិតនៅតំបន់ស្រែប្រាំង និងស្រែវស្សា និងតំបន់ស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប អាងទាំងនោះត្រូវបានប្រជាពលរដ្ឋលើកជាទំនប់ព័ទ្ធជុំវិញស្រែរបស់ពួកគាត់ សម្រាប់ស្តុកទឹកនៅពេលដែលទឹកបឹងទន្លេសាបជនលិចទឹកតំបន់នោះ ក្រោយពេលពេលទឹកបឹងទន្លេសាបស្រកទៅវិញ ប្រជាពលរដ្ឋអាចប្រើប្រាស់ទឹកអាងទាំងនោះសម្រាប់ស្រោចស្រពដំណាំស្រូវប្រាំងបាន ។ ដីអាងនេះ គឺជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែកាន់កាប់អាស្រ័យផលប៉ុណ្ណោះដោយមិនមានសិទ្ធិក្នុងការចាត់ចែងឡើយ ហើយក្នុងបច្ចុប្បន្ននេះត្រូវបានប្រើប្រាស់សម្រាប់ការស្រោចស្រព ព្រមទាំងជាប្រភពធនធានមច្ឆាជាតិផងដែរ ។

រូបភាព 15៖ អាងស្តុកទឹក

អាងស្តុកទឹក	អាងស្តុកទឹក

ពាក់ព័ន្ធបញ្ហាផ្សេងៗក្នុងការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជ តាមរយៈការសម្ភាសន៍លោកមេឃុំបានឱ្យដឹងថា មានប្រជាពលរដ្ឋក្នុងឃុំចំនួន ៥១គ្រួសារមិនមានដីសម្រាប់សាងសង់លំនៅឋាន និង ៤៣១គ្រួសារមិនមានដីធ្វើរបរកសិកម្មឡើយ។ ក្នុងចំណោមប្រជាពលរដ្ឋទាំងនេះ មានមួយចំនួនរស់នៅលើដីចិញ្ចើមផ្លូវ រស់នៅលើដីកម្មសិទ្ធិរបស់គេផ្សេង ។ ចំណែកបញ្ហាទំនាស់ក្នុងការការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជវិញ ពុំមានចេញជារូបភាពធំដុំគួរឱ្យកត់សម្គាល់ឡើយដោយសារដីក្នុងឃុំឡើយ ទោះបីមិនទាន់ត្រូវបានចុះបញ្ជីកាន់កាប់ដីរួចរាល់ក៏ដោយ តែបញ្ហាដែលកើតឡើងមានទំនាស់តិចតួច ក្រុមប្រឹក្សាឃុំអាចសម្របសម្រួល និងដោះស្រាយបាន ។

១.៣.២ .ផលិតកម្មកសិកម្ម

ក. ផលិតកម្មដំណាំស្បៀង

ផលិតកម្មដំណាំស្បៀងនៅក្នុងឃុំសំព្រោជ បានផ្តោតសំខាន់ទៅលើផលិតកម្មដំណាំស្រូវ ហើយដំណាំនេះបានដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ឃុំដោយសារផលិតផលស្រូវ ក្រៅពីប្រជាពលរដ្ឋបានទុកផ្គត់ផ្គង់សម្រាប់ការហូបចុក និងមាននៅសល់បានទុកលក់សម្រាប់បំពេញតម្រូវការចាយវាយចាំបាច់ក្នុងជីវភាពរស់នៅផងដែរ ។ ដំណាំស្រូវបានផលិតនៅលើផ្ទៃដីស្រែទំហំ ៩ ៧៣៧,១២ហិកតា ដែលជាប្រភេទដីល្បាយខ្សាច់ពណ៌ក្រហម និងក្រម៉ៅ(ដីប្រទះឡាង បាកាន) នៅប៉ែកខាងជើងឆៀងខាងកើត ដែលបច្ចុប្បន្នធ្វើស្រែបានតែម្តងគត់ក្នុងរដូវវស្សា ហើយនិយមប្រើពូជស្រូវ ផ្ការំដួល ស្រូវម្លិះ ស្រូវខា១១ ស្រូវនាងគង់ខ្សាច់ ស្រូវដំណើប ស្រូវខា៣ ស្រូវរាំងជ័យ ស្រូវម្លិះក្រហម ស្រូវខា១៥ ស្រូវប្រាំង៨៥ ស្រូវ៧៥ ស្រូវ៥១៥៤ ស្រូវសែនក្រអូប ស្រូវក្រមួន ។ ព្រមទាំងប្រភេទដីកណ្តោងពណ៌ខ្មៅ ក្រហមប្រផេះ(បាកាន.ក្បាលពោធិ៍ ក្រគរ) នៅកណ្តាលឃុំ ធ្វើបានតែម្តងក្នុងមួយឆ្នាំដោយសាជាតំបន់លិចទឹករយៈពេលយូរ ហើយនិយមប្រើពូជស្រូវ៨៥ ស្រូវ៧៥ ស្រូវ៥១៥៤ ៤៩និងស្រូវក្រមួនជាប្រភេទពូជនាំចូលពីវៀតណាម ។ ក្នុងការស្រោចស្រពសម្រាប់ដំណាំស្រូវនៅក្នុងឃុំសំព្រោជត្រូវបានប្រើប្រាស់ទឹកពីប្រភពទឹកភ្លៀង ទឹកប្រឡាយ៣០កញ្ញា បឹង ត្រពាំង និងអាងទឹក ទឹកទន្លេសាប ដោយមានប្រើប្រាស់ប្រព័ន្ធប្រឡាយមួយចំនួនដែលបច្ចុប្បន្ននៅមានការខ្វះខាតនៅឡើយ ។ ជាទូទៅនៅក្នុងឃុំសំព្រោជប្រជាពលរដ្ឋបានទទួលផលស្រូវវស្សាជាមធ្យម ១,៨តោន/ហ.ត ស្រូវប្រាំងជាមធ្យម៥តោន/ហ.ត ហើយបានពិនិត្យឃើញថាក្នុងឆ្នាំ២០១៧នេះ ក្នុងឃុំទទួលបានផលស្រូវសរុបចំនួន ១៣ ៣៨៧,២តោន ក្នុងនោះផលស្រូវវស្សាសរុប ៩ ០៩៧,២តោន និងផលស្រូវប្រាំងសរុបចំនួន ៤ ២៩០តោន ដោយក្នុងនោះទុកហូបចុក៣០ភាគរយ ទុកពូជ១០ភាគរយ និងសល់ពីនេះបានលក់ចេញចំនួន ៨ ០៣២,៣២តោន នៅក្នុងតម្លៃ៨៤៧រៀល/គ.ក្រ ដែលទទួលបានចំណូលសរុបប្រមាណ ៦ ៨០៣ ៣៧៥ រៀល ។

តារាង 23៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

ឧបសគ្គ	ឱកាស
- ភាពរាំងស្ងួត - សត្វល្អិតបំផ្លាញ និងជម្ងឺលើដំណាំស្រូវ - ប្រើប្រាស់ពូជស្រូវតាមទម្លាប់ - ខ្វះបច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំកសិកម្ម - ខ្វះបច្ចេកទេសដាំ និងថែទាំដំណាំស្រូវ	- មានដីស្រែធំទូលាយ រហូតដល់ ៧៥%នៃផ្ទៃដីសរុប - ស្ថានភាពដីស្រែជាវាលទំនាប អាចមានលទ្ធភាពនាំទឹកពីប្រភពទឹកស្ទឹងស្មោង ប្រឡាយ៣០កញ្ញា

- ពុំទាន់មានប្រភពទឹកសម្រាប់ផ្គត់ផ្គង់ការស្រោចស្រព - ប្រព័ន្ធប្រឡាយមានស្រាប់រងការខូចខាត (រាក់) - ខ្វះខាតប្រព័ន្ធប្រឡាយនាំទឹកស្រចស្រព - ខ្វះកម្លាំងពលកម្ម(ចំណាកស្រុកច្រើន)	បឹងទន្លេសាប មកផ្គត់ផ្គង់ការស្រោចស្រព ដើម្បីធ្វើស្រែបង្កើនរដូវ២-៣ដងក្នុងមួយឆ្នាំបាន - មានប្រព័ន្ធប្រឡាយស្រាប់ - មានកម្លាំងពលកម្មច្រើន - មានគោលការណ៍ជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុង ការពង្រឹងតួនាទីលើវិស័យកសិកម្ម - មានគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ របស់រាជរដ្ឋាភិបាល។

ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨

ខ. ផលិតកម្មដំណាំរួមផ្សំ

ផលិតកម្មដំណាំរួមផ្សំនៅក្នុងឃុំសំព្រោជបច្ចុប្បន្ន ប្រជាពលរដ្ឋបានដាំដំណាំរួមផ្សំមានដូចជា៖ បន្លែ ពោត ស្ពៃ ត្រកួន ត្រសក់ សណ្តែក ននោង ល្ពៅ ដែលពួកគាត់ធ្វើការដាំដុះលក្ខណៈគ្រួសារនៅជុំវិញដីលំនៅឋានជុំវិញត្រពាំងបឹងបួរ និងកន្លែងដែលមានប្រភពទឹក ដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ និងលក់ដូរបន្តិចបន្តួចដើម្បីបានកម្រៃខ្លះក្នុងការជួយបំពេញការខ្វះខាតក្នុងជីវភាពគ្រួសារតែប៉ុណ្ណោះ ។

តារាង 24៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

ឧបសគ្គ	ឱកាស
- ការយល់ដឹងពីបច្ចេកទេសដាំដំណាំរបស់ប្រជាពលរដ្ឋនៅមានកម្រិត។ - សត្វល្អិតបំផ្លាញ - ដំណាំកើតមានជម្ងឺ - ខ្វះខាតទឹកស្រោចស្រពនៅរដូវប្រាំ	- មានដីនៅជុំវិញលំនៅឋាន - មានប្រភពទឹកស្ទឹង ស្រះ និងទឹកក្រោមដី សម្រាប់ការស្រោចស្រព - ប្រជាពលរដ្ឋមានការយល់ដឹងពីសារៈប្រយោជន៍នៃដំណាំរួមផ្សំដែលអាចជួយផ្គត់ផ្គង់ដល់ការហូបចុក កាត់បន្ថយបានលើការចំណាយ ហើយបានលក់ខ្លះដោះស្រាយដល់ជីវភាពរស់នៅប្រចាំថ្ងៃ។

ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨

គ. ផលិតកម្មឧស្សាហកម្ម

នៅក្នុងឃុំសំព្រោជ មិនមានប្រជាពលរដ្ឋធ្វើការដាំដុះដំណាំឧស្សាហកម្មនោះទេ ដោយសារនៅតំបន់នេះជាតំបន់ទំនាបលិចទឹក ។ ដីមិនសមស្របសម្រាប់ដំណាំឧស្សាហកម្មនោះទេ ។

១.៣.៣. ធនធានធម្មជាតិ

ក. ធនធានព្រៃឈើ

បច្ចុប្បន្ននៅក្នុងឃុំសំព្រោជ មានធនធានព្រៃឈើគ្របដណ្តប់នៅលើផ្ទៃដីប្រមាណ ៧,១ហិកតា ដែលដុះរាយប៉ាយតាមក្បាលស្រែស្មើនឹង ០,០៣ភាគរយ ជាប្រភេទព្រៃគុម្ពោត ស្ថិតនៅរាយប៉ាយដែលមានដីទួលបុរាណ

នៅតាមព្រៃគម្ពោតនោះសរុបចំនួន១៤កន្លែង ដែលជាដីសាធារណៈរបស់រដ្ឋផង និងជាដីក្បាលស្រែរបស់ប្រជាពល-រដ្ឋផង មានមុខងារជាជម្រកសត្វព្រៃ ជួយរក្សាលំនឹងអាកាសធាតុ (ភ្លៀងធ្លាក់ទៀងទាត់) ផ្ដល់ខ្យល់អាកាសបរិសុទ្ធ ជួយទប់ទល់ខ្យល់ព្យុះនិងទឹកជំនន់ ជួយការពារការហូរច្រោះដី ធ្វើឲ្យដីមានជីជាតិ ជួយទាក់ទាញទឹកភ្លៀង ជួយស្រូកយកឧស្ម័នអុកស៊ីសែនដល់មនុស្ស និងបានផ្ដល់ផលធនធានដូចជា ឃ្មុំ ផ្សិត វល្លិ ឧសសម្រាប់ សត្វតាដក ននាល ក្អែក ខ្វែក ទាព្រៃ កុក ក្រសា ដែលមានប្រយោជន៍ដល់សង្គមនិងបរិស្ថាន ។

តារាង 25៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

ឧបសគ្គ	ឱកាស
- មានការកាប់បំផ្លាញឈើសម្រាប់ធ្វើឧសដុត និងប្រើប្រាស់ផ្សេងៗ - មានការកាប់បំផ្លាញឈើដើម្បីយកដីកាន់កាប់ - ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីផលប្រយោជន៍នៃដើមឈើនៅមានកម្រិត - ការអនុវត្តច្បាប់ព្រៃឈើនូវទាន់បានពេញលេញ - ការផ្សព្វផ្សាយច្បាប់ពុំទាន់បានទូលំទូលាយនៅឡើយ	- មានច្បាប់ស្ដីពីព្រៃឈើ - មានសហគមន៍ព្រៃឈើ........ - មានដីព្រៃឈើធម្មជាតិ - មានរដ្ឋបាលព្រៃឈើជាសមត្ថកិច្ចគ្រប់គ្រងព្រៃឈើ

ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨

ខ. ធនធានជលផល

បច្ចុប្បន្ននៅឃុំសំព្រោជ មានធនធានជលផលនៅក្នុងទន្លេមានទឹកជាអចិន្ត្រៃយ៍ ស្ទឹងមានទឹកតាមរដូវ បឹង អាងស្តុកទឹក ស្រះ មានទំហំផ្ទៃដី ៣ ៣៦៧ហិកតា ដែលមានចាប់ពីភាគកណ្ដាលឃុំទៅភាគខាងត្បូងនៃឃុំ ហើយមានធនធានផលផលដូចជា ត្រីក្រាយ កាម៉ម រស់ ផ្ទក់ ដៀប កញ្ចុះ ត្រីទីឡាបស្យា អន្ទង់ ក្ដាម ខ្យង កង្កែប អណ្ដើក និងពស់ជាដើម។ល។ ហើយត្រូវបានធ្វើការនេសាទដោយប្រជាជននៅក្នុងឃុំ ដែលជាលក្ខណៈគ្រួសារតាមរយៈការប្រើប្រាស់ឧបករណ៍ដូចជា សំណាញ់ មង ទ្រូ អួន សន្ទូច ជាលក្ខណៈប្រពៃណី ដែលផលនេសាទទាំងនេះបានសម្រាប់តែការហូបចុក និងលក់ដូរតិចតួចប៉ុណ្ណោះ ។ ការនេសាទដោយប្រើឧបករណ៍សំណាញ់ទទួលបានបរិមាណពី២ទៅ៥គីឡូក្នុងមួយថ្ងៃសម្រាប់លក់មួយចំនួន និងមួយចំនួនទៀតសម្រាប់ហូប ។

តារាង 26៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

ឧបសគ្គ	ឱកាស
- មានការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិតមិនសមស្របលើដំណាំកសិកម្ម នាំឱ្យមានការថយចុះបរិមាណធនធានជលផល - ការប្រើឧបករណ៍នេសាទខុសច្បាប់។	- មានស្ទឹង បឹង អាងស្តុកទឹក ស្រះ និងស្រែ ដែលអំណោយផលដល់ធនធានជលផល - មានច្បាប់ជលផល។

ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨

រូបភាព 16៖ ផលនេសាទ

១.៣.៤. ធនធានរ៉ែ

បច្ចុប្បន្ននៅក្នុងឃុំសំព្រោជ មានធនធានរ៉ែ ជាប្រភេទរ៉ែខ្សាច់មួយមុខគត់សម្រាប់ប្រើប្រាស់លើវិស័យសំណង់ដែលស្ថិតនៅជាប់បឹងទន្លេសាប ភាគខាងលិចព្រែកបាទ័ល ប៉ុន្តែធនធានរ៉ែខ្សាច់នេះមិនទាន់មានប្រជាពលរដ្ឋឬក្រុមហ៊ុនណាធ្វើអាជីវកម្មនូវឡើយទេ ព្រោះទីនោះជាតំបន់លិចទឹក ផ្លូវពិបាកធ្វើដំណើរ ។

១.៤. ទីផ្សារ និងខ្សែសង្វាក់ផលិតផល

១.៤.១. ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ

បច្ចុប្បន្ននៅក្នុងឃុំសំព្រោជ មានតែផលិតផលស្រូវតែមួយគត់ ដែលអាចនាំចេញទៅរកទីផ្សារ ហើយផលិតផលស្រូវដែលសល់ពីការហូបចុកអាចនាំទៅរកទីផ្សារមានប្រភេទស្រូវ(ពូជ៥០៤/៨៥)និងស្រូវផ្ការំដួល ។ បើយោងតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធកៀ្សត្រ-បរិស្ថានឃុំសំព្រោជ ឆ្នាំ២០១៧ បានឱ្យដឹងថាប្រភេទស្រូវផ្ការំដួលមានទីផ្សារនៅក្នុងប្រទេស និងទីផ្សារប្រទេសវៀតណាមដែលប្រជាពលរដ្ឋតែងតែលក់ស្រូវសើម១០០ភាគរយ តាមរយៈឈ្មួញមកទទួលទិញដល់ក្នុងឃុំមានតម្លៃត្រឹម១០០- ១ ០៥០រៀលក្នុងមួយគីឡូក្រាម ចំណែកស្រូវ(៥០៤/៨៥) មានទីផ្សារនៅក្នុងប្រទេស និងទីផ្សារនៅប្រទេសប្រទេសវៀតណាមដូចគ្នា ប្រជាពលរដ្ឋតែងលក់ស្រូវសើម១០០ភាគរយ តាមរយៈឈ្មួញមកទទួលទិញដល់ក្នុងឃុំដែរ មានតម្លៃ ៨០០រៀល ក្នុងមួយគីឡូក្រាម ។

តារាង 27៖ ស្ថិតិផលិតផលស្រូវ និងតម្លៃ

ល.រ	ប្រភេទផលិតផលស្រូវ	ឯកតា	តម្លៃជារៀល	តម្លៃជារៀលទីផ្សារ	
				ក្នុងស្រុក	ក្រៅប្រទេស
១	ស្រូវផ្ការំដួល	១ គ.ក្រ	១០០-១ ០៥០		វៀតណាម
២	ស្រូវប្រដេញទឹក(ពូជ៥០៤/៨៥)	១ គ.ក្រ	៨០០		វៀតណាម

១.៨.២. ខ្សែសង្វាក់ និងចរាចរផលិតផល

តាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធកេក្សត្រ-បរិស្ថានឃុំសំព្រោជ ឆ្នាំ២០១៧ បានឱ្យដឹងថា បច្ចុប្បន្ននៅក្នុងឃុំសំព្រោជ ការផលិតដំណាំស្រូវរហូតដល់បានផលលក់ចេញគឺ ត្រូវដំណើរការតាមខ្សែសង្វាក់ជាបន្តបន្ទាប់ ដូចជាការ ផលិតដំណាំស្រូវផ្ការំដួល ដោយចាប់ផ្តើមពីការត្រៀមពូជស្រូវដែលភាគច្រើនបានរក្សាទុកដោយខ្លួនឯង ៥០ភាគរយ និងមានការទិញចូល ១០ភាគរយ ហើយមានការរៀបចំដី រួមទាំងការថែទាំ មានការដាក់ជីនិងបាញ់ថ្នាំសម្លាប់សត្វល្អិត រហូតដល់ច្រូតកាត់ដែលប្រើដោយគ្រឿងយន្តរហូតដល់៩៥ភាគរយ និងច្រូតកាត់ដោយដៃតែ ៥ភាគរយប៉ុណ្ណោះ ។ ផលស្រូវដែលទទួលបានត្រូវហាលសម្ងួតទុកពូជ ២០ភាគរយ និងទុកផ្គត់ផ្គង់ការហូបចុកប្រមាណ៣០ភាគរយ ចំណែកផលស្រូវនៅសើមដែលសល់ប្រមាណ៥០ភាគរយ យកទៅលក់ឱ្យឈ្មួញនៅតាមដងផ្លូវក្នុងឃុំបានតម្លៃ ១ ០០០-១ ០៥០រៀល ក្នុងមួយគីឡូក្រាម ហើយឈ្មួញបន្តលក់ឱ្យរោងម៉ាស៊ីនកិនស្រូវយកទៅកិនកែច្នៃជាអង្ករនាំទៅទីផ្សារក្នុងប្រទេស និងទីផ្សារក្រៅប្រទេស។ តែចំពោះស្រូវប្រដេញទឹក(ពូជ៥០៤/៨៥)វិញ ពូជត្រូវបានទិញពីគ្នាឯងក្នុងឃុំ ហើយមានការរៀបចំដី រួមទាំងការថែទាំ មានការដាក់ជី និងបាញ់ថ្នាំសម្លាប់សត្វល្អិត រហូតដល់ច្រូតកាត់ដែលប្រើដោយគ្រឿងយន្តទាំងអស់១០០ភាគរយ ចំណែកផលស្រូវដែលទទួលបានត្រូវបានហាលសម្ងួតទុកពូជ៣០ភាគរយ ចំណែកផលស្រូវនៅសើមដែលសល់ប្រមាណ ៧០ភាគរយ យកទៅលក់ ឱ្យឈ្មួញនៅតាមដងផ្លូវក្នុងឃុំបានតម្លៃត្រឹមតែ ៨០០រៀលក្នុងមួយគីឡូក្រាម ហើយឈ្មួញបន្តយកទៅលក់ឱ្យទីផ្សារប្រទេសវៀតណាម ។

រូបភាព 17៖ ផលិតផលកសិកម្ម

ការលក់ផលិតផលស្រូវរបស់កសិករអោយឈ្មួញ

ដ្យាក្រាម 4៖ គំនូសតាងនៃការលំហូផលិតផលកសិកម្ម នៅក្នុងភូមិ និង ការប្រើប្រាស់





១.៤.៣. ឧបសគ្គ និងឱកាស

តារាង 28៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ទីផ្សារនិងខ្សែសង្វាក់ផលិតផល

ឧបសគ្គ	ឱកាស
- ឈ្មួញជាអ្នកកំណត់តម្លៃស្រូវ - ឈ្មួញកណ្តាលយកជី ថ្នាំ និងប្រេងមកបណ្តាក់ដោយគិតការប្រាក់ខ្ពស់រហូតដល់២%ក្នុងមួយខែ ហើយទូទាត់នៅពេលប្រមូលផល - កសិករប្រើពូជទុកខ្លួនឯងច្រើនជំនាន់ - ធាតុចូលកសិកម្មថ្លៃខ្ពស់ - តម្លៃស្រូវមិនទៀងទាត់(អាស្រ័យលើឈ្មួញ) - ប្រើប្រាស់ពូជស្រូវវៀតណាម។	- មានឈ្មួញមកទិញដល់កន្លែង - មានភាពងាយស្រួលក្នុងការដឹកជញ្ជូនផលិតផលស្រូវ - អាចប្រកួតប្រជែងតម្លៃជាមួយប្រទេសជិតខាង - គុណភាពស្រូវស្របតាមស្តង់ដាសម្រាប់ការនាំចេញ - តម្លៃអង្ករកើនឡើង និងទៀងទាត់ - ពូជស្រូវមានទិន្នផលខ្ពស់ និងតម្លៃខ្ពស់ - កែច្នៃចេញជាផលិតផលសម្រេច។

ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែមិថុនា ឆ្នាំ២០១៨

ជំពូក ២៖ ការវិភាគ តម្រូវការ សក្ដានុពល និងឧបសគ្គសម្រាប់អនាគត

២.១. តម្រូវការសម្រាប់អនាគត

២.១.១.ផែនការអភិវឌ្ឍន៍ឃុំ

ក. ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ(២០១៨-២០២២)

ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ គឺជាមធ្យោបាយយ៉ាងសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហា តម្រូវការជាអាទិភាពយ៉ាងពិតប្រាកដរបស់មូលដ្ឋាន និងយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ សំដៅឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងឃុំយ៉ាងមានប្រសិទ្ធភាពតាមរយៈការរៀបចំឱ្យមានតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំមួយ មានរយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិក្រុមប្រឹក្សាឃុំ ។ តារាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំនេះ បានរំលេចនូវចក្ខុវិស័យអភិវឌ្ឍន៍ ដែលជាទស្សនៈរបស់ក្រុមប្រឹក្សាចង់បាន ការប្រែប្រួលជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្លួនឱ្យបាន ស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ហើយដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ក៏បានរំលេចឱ្យឃើញពីគោលបំណងអភិវឌ្ឍន៍ ដែលជាលទ្ធផលរួមរបស់ក្រុមប្រឹក្សាចង់បាន ព្រមទាំងគោលដៅអភិវឌ្ឍន៍ដែលជាលទ្ធផលនានារបស់ក្រុមប្រឹក្សាចង់បានតាមវិស័យនីមួយៗ ។ ទន្ទឹមនេះក៏បានរំលេចឱ្យឃើញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដែលជាការកំណត់នូវវិធីសាស្ត្រ ឬសកម្មភាពត្រូវអនុវត្ត ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍នីមួយៗខាងលើ ។

ចំណែកឃុំសំព្រោជ ក្រុមប្រឹក្សាឃុំក្នុងអាណត្តិ ២០១៨-២០២២ ក៏បានរៀបចំឱ្យមានផែនការអភិវឌ្ឍន៍ឃុំរយៈពេលប្រាំឆ្នាំរបស់ខ្លួន ដែលក្នុងនោះបានលើកឡើងពីគម្រោងវិនិយោគរយៈពេលប្រាំឆ្នាំទៅក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំ ដូចមានខ្លឹមសារដែលក្រុមការងារបានដកស្រង់បញ្ចូលក្នុងតារាងខាងក្រោម៖

តារាង 29៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ និងជម្រើសនៃការប្រាស់ដីធ្លីអនាគត

កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និង យុទ្ធសាស្ត្រ					
តម្រូវការនៃការអភិវឌ្ឍន៍	ប្រភពឯកសារ	គោលដៅនៃ ការអភិវឌ្ឍន៍	យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍	សកម្មភាពជា អាទិភាព	លេខរៀងនៅលើផែនទី
១	២	៣	៤	៥	៦
១.ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូនល្អប្រសើរ	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២	-ប្រជាពលរដ្ឋក្នុងឃុំមានផ្លូវធ្វើដំណើរស្រួលចាប់ពីឆ្នាំ ២០១៨	-កែលម្អរជួសជុលផ្លូវ និងដាក់លូបង្ហូរទឹក -សាងសង់ផ្លូវថ្មីបន្ថែម	-កសាងផ្លូវកៅស៊ូ -ជួសជុលផ្លូវក្រាលគ្រួសក្រហម -កសាងផ្លូវគ្រួសក្រហម -ជួសជុលផ្លូវលំដីស -ដាក់លូកាត់ផ្លូវ -ចាក់ដីបំពេញទីធ្លាមណ្ឌលសុខភាព	
២.មានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២	-ប្រជាពលរដ្ឋមានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់	-ស្តារនិងជួសជុលប្រព័ន្ធធារាសាស្ត្រចាស់ៗឡើងវិញ -សាងសង់ប្រព័ន្ធធារាសាស្ត្រថ្មីបន្ថែមទៀត	-ជីកប្រឡាយស្រោចស្រព -លើកទំនប់ទឹក -ស្តារប្រឡាយស្រោចស្រព -សាសង់ទ្វារទឹក -ជួសជុលទ្វារទឹក -ពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹក	

				-ផ្តល់ម៉ាស៊ីនបូមទឹក -ពង្រឹងគណៈកម្មការគ្រប់គ្រងធារាសាស្ត្រ	
៣.កម្រិតអប់រំមានគ្រប់កម្រិត និងសិស្សបានចូលរៀនគ្រប់គ្នានៅក្នុងឃុំ	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២	-បង្កើនការចូលរៀនកុមារអាយុ ៣-៤ ឆ្នាំឲ្យបាន ៩០% នៅឆ្នាំ ២០១៨ -កុមារអាយុ ៦-១៤ ឆ្នាំបានរៀនបញ្ចប់នូវកម្រិតមូលដ្ឋាន ០៩ ឆ្នាំ -ចំនួនអនក្ខរជននឹងថយនៅត្រឹម២%	-ពង្រឹងនិងពង្រីកផ្នែកមត្តេយ្យសាលាឲ្យបានគ្រប់មូលដ្ឋានភូមិ -ជម្រុញការយល់ដឹងដល់ឪពុកម្តាយកុមារពីតម្លៃសិក្សា -ពង្រឹងកិច្ចសហការជាមួយមន្ទីរជំនាញ និងអង្គការនានាដើម្បីកាត់បន្ថយអនក្ខរកម្មរបស់ប្រជាពលរដ្ឋ	-ចាក់ដីទីធ្លាសាលាបឋមសិក្សា -សាងសង់អគារបឋមសិក្សា -បង្កើតថ្នាក់មត្តេយ្យ -ផ្តល់សម្ភារៈល្បែងលេងកុមារតាមសាលាបឋមសិក្សា -ផ្តល់មធ្យោបាយចម្រោះទឹក -ផ្តល់គ្រូមត្តេយ្យ -ផ្សព្វផ្សាយឲ្យឪពុកម្តាយនាំកូនចូលរៀន -ផ្តល់សម្ភារសិក្សាដល់សិស្សក្រីក្រ -ផ្តល់អាហាររូបករណ៍ដល់សិស្សក្រីក្រ -អប់រំកុមារឲ្យយល់ដឹងពីតម្លៃនៃការសិក្សា -បើកថ្នាក់អក្ខរកម្មឲ្យបានគ្រប់ភូមិ	
៤.កាត់បន្ថយមរណៈមាតា និងទារកក្រោយសំរាល	សាលាឃុំ	-បង្កើនការលុបបំបាត់អត្រាស្លាប់មាតា និងទារកក្រោយសម្រាល	-ពង្រឹងនិងពង្រីកការផ្តល់សេវាគាំពារសុខភាពមាតា និងទារក	-ផ្តល់វ៉ាក់សាំងដល់ស្ត្រីនិងកុមារ -បណ្តុះបណ្តាលពង្រឹងសមត្ថភាពឆ្មបបុរាណ -ចាក់ដីបំពេញទីធ្លាមណ្ឌលសុខភាព -ឧបត្ថម្ភគ្រួសារស្ត្រីមេម៉ាយ -ឧបត្ថម្ភគ្រួសារជនរងគ្រោះ -ឧបត្ថម្ភគាំទ្រជនពិការនិងកុមារកំព្រា និងចាស់ជរាគ្មានទីពឹង -ពង្រឹងសមត្ថភាពភ្នាក់ងារសុខភាពស្ម័គ្រចិត្តភូមិ -កម្មវិធីពន្យាកំណើត -ផ្សព្វផ្សាយដល់ស្ត្រីមានផ្ទៃពោះឲ្យទៅសម្រាលកូនដោយពេទ្យឆ្មប -អប់រំឲ្យស្ត្រីចេះរបៀបការពារជម្ងឺឆ្លងកាមរោគ និងជម្ងឺអេដស៍ -មិនរើសអើង និងគាំទ្រដល់អ្នកកើតមេរោគអេដស៍ -ជម្រុញឲ្យស្ត្រីមានផ្ទៃពោះទៅពិនិត្យពោះនៅមណ្ឌលសុខភាព -ជម្រុញឪពុកម្តាយយកកុមារទៅចាក់ថ្នាំការពារជម្ងឺ៧មុខ	
៥.ឃុំមានបរិស្ថាន និង ធនធានធម្មជាតិស្រស់បំព្រង	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២	-ធ្វើឲ្យប្រសើរឡើងនូវធនធានធម្មជាតិ	-បង្កើនសេវាលើការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន	-អប់រំពីផលប្រយោជន៍ព្រៃឈើនិងព្រៃលិចទឹក -អប់រំផ្សព្វផ្សាយពីច្បាប់ជលផល -អប់រំពីចំណេះដឹងបរិស្ថាន -អប់រំពីកាកសំណល់រឹងរាវតាមផ្ទះ -បណ្តុះបណ្តាលច្បាប់រុក្ខាប្រមាញ់ និងនេសាទត្រីខុសច្បាប់ -ដាំកូនឈើតាមទីសាធារណៈ	

				-ស្តារបឹងចាស់ៗ ឡើងវិញ	
៦.ធ្វើឲ្យប្រជាពលរដ្ឋរស់នៅប្រកបដោយភាពសុខសាន្ត និងសុវត្ថិភាព	សាលាឃុំ	-ភូមិឃុំមានសន្តិសុខ និងសណ្តាប់ធ្នាប់ និងមានសុវត្ថិភាពល្អ	-ជម្រុញពង្រីកការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព -ប្រជាពលរដ្ឋចូលរួមនិងបង្កើតក្រុមការពារភូមិ ដើម្បីរក្សាសន្តិសុខសណ្តាប់ធ្នាប់ភូមិ-ឃុំ	-បង្កើតប៉ុស្តិ៍ស្ម័យការពារតាមភូមិ -ពង្រឹងប្រជាជនការពារតាមភូមិឃុំ -ផ្សព្វផ្សាយច្បាប់ភូមិបាលនិងច្បាប់ផ្សេងៗទៀត -ចុះបញ្ជីអគ្រានុកូលដ្ឋានបានគ្រប់ៗគ្នា -ផ្សព្វផ្សាយអប់រំក្រុមក្រុមក្មេងទំនើង -អប់រំពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន -បង្ក្រាបល្បែងស៊ីសងគ្រប់ប្រភេទ -ផ្សព្វផ្សាយច្បាប់រដ្ឋប្រពៃណីនិងព្រហ្មទណ្ឌ -ផ្សព្វផ្សាយច្បាប់ចរាចរនិងសណ្តាប់ធ្នាប់សាធារណៈដល់ប្រជាជន -ចាក់ដីបំពេញសាលាឃុំ -ពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ -បំផុសឲ្យចូលរួមសហការណ៍ជាមួយសមត្ថកិច្ច	
៧.លុបបំបាត់កាត់បន្ថយទំនាស់ដីធ្លី	សាលាឃុំ	-មានប័ណ្ណកម្មសិទ្ធិគ្រប់គ្រងដីធ្លីនិងយល់ច្បាស់ពីសិទ្ធិក្នុងការគ្រប់គ្រង	-ជម្រុញឲ្យប្រជាពរដ្ឋបានយល់ដឹងពីច្បាប់ និងមានកម្មសិទ្ធិដីធ្លីដោយស្របច្បាប់ -បង្កើនការគ្រប់គ្រងដីធ្លីស្របតាមគោលនយោបាយរបស់រដ្ឋ	-ផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ប្រជាពលរដ្ឋ -ផ្សព្វផ្សាយពីច្បាប់ភូមិបាល និងច្បាប់ផ្សេងៗ -ជម្រុញឲ្យប្រជាពលរដ្ឋធ្វើរបង និងព្រំដីឲ្យបានច្បាស់លាស់	
៨.ទិន្នផលកសិកម្មកើនឡើង	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២	-ធានាស្បៀងហូបគ្រប់គ្រាន់	-បង្កើនផលិតកសិកម្ម	-លើកទំនប់និងភ្លឺស្រែ -ជីកប្រឡាយ -លូស្ពាក់ទឹក ទ្វារទឹក -ពូជស្រូវល្អ -ធ្វើជីកំប៉ុស្តិ៍ -បច្ចេកទេសជីគីមី -ចិញ្ចឹមសត្វ -ដាំដំណាំ	
៩.មានទឹកស្អាតសម្រាប់គ្រួសារប្រើប្រាស់	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២	-ការរស់នៅមានអនាម័យតាមរយៈមានទឹកស្អាតប្រើប្រាស់	-ពង្រីក និងកែលំអប្រភពផ្គត់ផ្គង់ទឹក	-ជីកអណ្តូងលូ ស្នប់ ស្រះសហគមន៍ -ជួសជុលអណ្តូង -បច្ចេកទេសចម្រោះទឹក	
១០.សមភាព និងសមធម៌ក្នុងការរស់នៅ	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២	-ធ្វើឲ្យប្រសើរឡើងដល់ប្រជាជនគ្រប់របរស់នៅប្រកបដោយសមភាព សមធម៌ គោរពគ្នាទៅវិញទៅមក	-បង្កើនការផ្សព្វផ្សាយច្បាប់ និងលើកកម្ពស់មុខរបរ	-ផ្សព្វផ្សាយច្បាប់សិទ្ធិមនុស្ស -ផ្សព្វផ្សាយច្បាប់អំពើហិង្សាក្នុងគ្រួសារ -ផ្សព្វផ្សាយច្បាប់ជួញដូរស្ត្រី និងកុមារ -ផ្សព្វផ្សាយច្បាប់កេងប្រវ័ញដល់កម្លាំងពលកម្មស្ត្រីនិងកុមារ	

				-បណ្តុះបណ្តាលពីតួនាទី យេនឌ័រ -ពង្រឹងសមត្ថភាពជនបង្គោលទទួលបន្ទុកស្ត្រីនិងកុមារ -បណ្តុះបណ្តាលយេនឌ័រ -លើកកម្ពស់ស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍ -ផ្សព្វផ្សាយពីសិទ្ធិស្ត្រីនិងកុមារនិងតួនាទីបុរសនិងកុមារ	
១១.ទិន្នផលត្រីកើនឡើង	សាលាឃុំ	-បង្កើនធនធានជលផល	-ជម្រុញការបង្កើតវារីវប្បកម្ម	-បណ្តោះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី -ជ្រើសរើសទីតាំង -ផ្តល់ពូជត្រី -ផ្តល់ឥណទាន -ផ្សព្វផ្សាយច្បាប់ជលផល -បង្កើនការចិញ្ចឹមត្រីតាមគ្រួសារ -អប់រំ និងផ្សព្វផ្សាយបំរាមនេសាទនៅរដូវត្រីពង	
១២.គ្រួសារចិញ្ចឹមសត្វកើនឡើង	សាលាឃុំ	-បង្កើនការចិញ្ចឹមសត្វបន្ថែមទៀត	-ជម្រុញការផ្តល់បច្ចេកទេសជំនាញកសិកម្ម -ជម្រុញការផ្តល់បច្ចេកទេសចិញ្ចឹមថែទាំសុខភាពសត្វនិងជ្រើសរើសពូជ	-ចាក់វ៉ាក់សាំងការពារជម្ងឺគោក្របីឲ្យបានទៀងទាត់ -ផ្តល់ឥណទានគោក្របី -ផ្តល់ឥណទានមានការប្រាក់ទាប -បណ្តុះបណ្តាលការចិញ្ចឹមសត្វ -ផ្តល់ពូជសត្វ	
១៣.ឲ្យមានថាមពលអគ្គិសនីប្រើប្រាស់គ្រប់ផ្ទះ	សាលាឃុំ	-ទូទាំងឃុំឃុំមានអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់	-ពង្រឹងកិច្ចសហការជាមួយអង្គភាពជំនាញដើម្បីជម្រុញការផ្គត់ផ្គង់ថាមពលអគ្គិសនី	-រៀបចំបណ្តាញអគ្គិសនីតាមភូមិ	

ប្រភពទិន្នន័យៈ *របាយការណ៍ក្បេត្រ-បរិស្ថា CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសំព្រោជ ឆ្នាំ២០១៨*

ខ. គម្រោងអភិវឌ្ឍន៍ផ្សេងៗទៀត ដែលបានអនុម័តរួច

នៅក្នុងឃុំសំព្រោជ បច្ចុប្បន្នមិនមានគម្រោងអភិវឌ្ឍន៍ណាមួយ ដែលត្រូវបានអនុម័តរួចដើម្បីដំណើរការជួយជំរុញក្នុងការអភិវឌ្ឍន៍ឃុំឡើយ ។

ផែនទី ១៖ ផែនទីគម្រោងជាអាទិភាព ឃុំសំព្រោជ



២.១.២.ចំណោលប្រជាសាស្ត្រគិតទៅដល់ឆ្នាំ២០៣២

ការព្យាករណ៍ពីកំណើនប្រជាជន ជាចំណុចសំខាន់ណាស់សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជ ដែលអាចឱ្យយើងដឹងមុននូវចំនួនប្រជាជនក្នុងឃុំក្នុងរយៈពេល១៥ឆ្នាំខាងមុខដ៏វែងអត្រាកំណើនជាមធ្យមរបស់ប្រជាពលរដ្ឋនៅក្នុងឃុំដែលបានបង្ហាញក្នុងជំពូកទី១បានឱ្យដឹងគឺ០,៦ភាគរយដូច្នេះប្រជាពលរដ្ឋក្នុងឃុំនឹងមានការកើនឡើងរហូតដល់ឆ្នាំ ២០៣២ ត្រូវបានធ្វើចំណោលតាមរយៈការគណនាដូចខាងក្រោម៖

-ចំនួនប្រជាពលរដ្ឋសរុបក្នុងឆ្នាំ ២០១៧ គឺ ១៣ ៦២៩នាក់

-អត្រាកំណើនមធ្យមប្រចាំឆ្នាំៈ ០,៦%

-ចំនួនប្រជាជនកើនឡើងក្នុងរយៈពេល១ឆ្នាំៈ១៣ ៦២៩នាក់ x ០,៦% = ៨២នាក់/ឆ្នាំ

-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាពលរដ្ឋកើនឡើងបានៈ ៨២នាក់/ឆ្នាំx១៥ ឆ្នាំ = ១ ២៣០នាក់

-ដូច្នេះប្រជាជនសរុបក្នុងរយៈពេល១៥ខាងមុខមានៈ ១៣ ៦២៩នាក់ +១ ២៣០នាក់ = ១៤ ៨៥៩នាក់

ចំណែកចំនួនគ្រួសារក្នុងឃុំ នឹងមានការកើនឡើងនៅក្នុងឆ្នាំ ២០៣២ ត្រូវបានធ្វើចំណោលតាមរយៈការគណនាដូចខាងក្រោម៖

-ចំនួនប្រជាជនសរុបក្នុងឆ្នាំ២០១៧ គឺ ១ ៣៦២៩នាក់

-ចំនួនគ្រួសារសរុបក្នុងឆ្នាំ២០១៧ គឺ ២ ៨០៨គ្រួសារ

-ចំនួនសមាជិកមធ្យមក្នុងមួយគ្រួសារក្នុងឆ្នាំ២០១៧ គឺៈ

១៣ ៦២៩នាក់ /២ ៨០៨គ្រួសារ = ៤,៨៥នាក់/គ្រួសារ=៥នាក់

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខចំនួនគ្រួសារកើនឡើងបានៈ

១ ២៣០នាក់/ ៤,៨៥នាក់/គ្រួសារ = ២៥៤គ្រួសារ

-ដូច្នេះចំនួនគ្រួសារសរុបក្នុងរយៈពេល១៥ឆ្នាំខាងមុខទៀតមានៈ

២ ៨០៨គ្រួសារ + ២៥៤គ្រួសារ = ៣ ០៦២គ្រួសារ

តារាង 30៖ ចំណោលប្រជាសាស្ត្រនៃចំនួនគ្រួសារ និងប្រជាជនសរុប (០៥ឆ្នាំ)

ឆ្នាំ	ចំនួនគ្រួសារ	ចំនួនប្រជាជន(នាក់)	
		សរុប	ស្រី
២០១៧	២ ៨០៨	១៣ ៦២៩	៦ ៨៦៥
២០២២	២ ៨៩៣	១៤ ០៣៦	៧ ០៧១
២០២៧	២ ៩៧៨	១៤ ៤៤៩	៧ ២៧៧
២០៣២	៣ ០៦២	១៤ ៨៥៩	៧ ៤៨៣

ប្រភពទិន្នន័យ៖ *CDB ឆ្នាំ២០១៧ ក្រុមការងារបច្ចេកទេស អេស ប៊ី ខេ ឆ្នាំ២០១៨*

☞ចំណាំ៖

- ចំណោលប្រជាសាស្ត្រសម្រាប់១៥ឆ្នាំខាងមុខ៖ អត្រាកំណើនមធ្យមប្រចាំឆ្នាំ x ចំនួនប្រជាជនឆ្នាំបច្ចុប្បន្ន/១០០
- ដូច្នេះក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើន៖ អត្រាកំណើនប្រជាជនប្រចាំឆ្នាំ x ១៥
- ដូច្នេះប្រជាជនសរុបក្នុងរយៈពេល១៥ទៀតមាន៖ ចំនួនអត្រាកំណើនប្រជាជន១៥ខាងមុខ + ចំនួនប្រជាជនឆ្នាំបច្ចុប្បន្ន

តារាង 31៖ ចំណោលប្រជាសាស្ត្រតាមក្រុមអាយុ (០៥ឆ្នាំ)

ស្ថិតិតាមក្រុមអាយុ	២០១៧		២០២២		២០២៧		២០៣២	
	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
អាយុពី០-២ឆ្នាំ	៧៦០	៣៤៦	៨៥៦	៣៩០	៩៥២	៤៣៤	១០៤៨	៤៧៧
អាយុពី៣-៤ឆ្នាំ	៧០០	៣៣៦	៧៩៦	៣៨០	៧៩៦	៤២៤	៧៩៦	៤៦៧
អាយុ៥ឆ្នាំ	៥៥៩	២៨៦	៥៧៦	២៩៥	៥៩៣	៣០៣	៦០៩	៣១២
អាយុ៦-១១ឆ្នាំ	១ ៨០៦	៩១០	១ ៨៦០	៩៣៧	១ ៩១៤	៩៦៥	១ ៩៦៩	៩៩២
អាយុ១២-១៤ឆ្នាំ	៩៨១	៥២៧	១ ០១០	៥៤៣	១ ០៤០	៥៥៩	១ ០៦៩	៥៧៤
អាយុ១៥-១៧ឆ្នាំ	១ ០៥២	៥២២	១ ០៨៤	៥៣៨	១ ១១៥	៥៥៣	១ ១៤៧	៥៦៩
អាយុ១៨-២៤ឆ្នាំ	១ ៦៨២	៨៥៧	១ ៧៣២	៨៨៣	១ ៧៨៣	៩០៨	១ ៨៣៣	៩៣៤
អាយុ២៥-៦០ឆ្នាំ	៤ ៧២៩	២ ៣៩២	៤ ៨៧១	២ ៤៦៤	៥ ០១៣	២ ៥៣៦	៥ ១៥៥	២ ៦០៧
អាយុ៦១ឆ្នាំ	១ ៣៦០	៦៨៩	១ ៤០១	៧១០	១ ៤៤២	៧៣០	១ ៤៨២	៧៥១
ប្រជាជនសរុប	១ ៣៦២៩	៦ ៨៦៥	១៤ ១៨៦	៧ ១៤០	១៤ ៦៤៨	៧ ៤១១	១៥ ១០៩	៧ ៦៨៤
ចំនួនគ្រួសារ	២ ៨០៨		២ ៨៩៣		២ ៩៧៨		៣ ០៦២	

ប្រភពទិន្នន័យ៖ *CDB ឆ្នាំ២០១៧ ក្រុមការងារបច្ចេកទេស អេស ប៊ី ខេ និងក្រុមប្រឹក្សាឃុំសំព្រោជ ខែកញ្ញា ឆ្នាំ២០១៨*

២.១.៣. តម្រូវការដីធ្លីជាមូលដ្ឋាន

ក. ដីលំនៅឋាន

ចំពោះដីលំនៅឋានភូមិសំដៅទៅលើដីសម្រាប់សង់ផ្ទះ និងសម្រាប់សួនដំណាំជុំវិញផ្ទះតាមគ្រួសារ។ នៅក្នុងឆ្នាំ២០១៧ ដែលជាឆ្នាំគោលយើងបានដឹងថា ដីលំនៅឋានមានទំហំ ២៥០ហិកតា និងមានគ្រួសារសរុបចំនួន ២ ៨០៨គ្រួសារ គឺជាស្ថានភាពរស់នៅរបស់ប្រជាជនមានភាពសមស្របមិនមានបញ្ហាពីការខ្វះដីសម្រាប់លំនៅឋានឡើយ លើកលែងតែគ្រួសារមួយចំនួនតូចគឺស្មើចំនួន៥១គ្រួសារប៉ុណ្ណោះ ដែលមិនមានដីសម្រាប់សាងសង់លំនៅឋាន ហើយបច្ចុប្បន្នគ្រួសារទាំងនោះកំពុងរស់នៅលើដីចំណីប្រឡាយជាដីសាធារណៈនិងគ្រួសារមួយចំនួនទៀតកំពុងរស់នៅលើដីកម្មសិទ្ធិរបស់អ្នកដទៃ (យោងតាមទិន្នន័យក្នុងជំពូកទី១ ត្រង់ចំណុច ១.៣.១ អំពីការកាន់កាប់ និងគ្រប់គ្រងការប្រើប្រាស់ដី) ដែលត្រូវយកចិត្តទុកដាក់ដោះស្រាយជូនតាមរយៈដី សម្បទានដីសង្គមកិច្ចមាននៅទីតាំងក្រៅឃុំតាមការសម្រេចចរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ច ក្នុងឆ្នាំ២០១៧ ផ្ទៃដីលំនៅឋានជាមធ្យមសម្រាប់មួយគ្រួសារមានចំនួន៖

២៥០ហិកតា/ ២ ៨០៨គ្រួសារ = 0,០៩ហិកតា/ គ្រួសារ

តែបើយោងតាមអនុក្រឹត្យលេខ ១៩ ស្ដីពីសម្បទានដីសង្គមកិច្ច ចែងតម្រូវឱ្យមានដីលំនៅឋានយ៉ាងច្រើន 0,២៥ហិកតាក្នុងមួយគ្រួសារ ដែលអាចប្រើប្រាស់សម្រាប់ដោះស្រាយជូន៥១គ្រួសារ ដែលគ្មានដីពិតប្រាកដសម្រាប់លំនៅឋាន ដើម្បីអាចទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋ ដែលមាននៅទីតាំងផ្សេងពីឃុំសំព្រោជនេះ។

ដូច្នេះដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ន ចំពោះប្រជាជនដែលមានកំណើនក្នុងរយៈពេល ១៥ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់ធ្វើកសិកម្ម ក្នុងចំនួនតាមការគណនាដូចខាងក្រោម៖

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើនឡើងចំនួនៈ ១ ២៣០នាក់

-ចំនួនសមាជិកមធ្យមក្នុងមួយគ្រួសារមានៈ ៤,៨៥នាក់/គ្រួសារ

-តម្រូវការដីលំនៅឋានក្នុង១គ្រួសារមានចំនួន០,០៩ហិកតា/ គ្រួសារ

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខចំនួនគ្រួសារកើនឡើងបានៈ

១ ២៣០នាក់/ ៤,៨៥នាក់/គ្រួសារ = ២៥៤គ្រួសារ

-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ(២០១៧-២០៣២) ដីលំនៅឋានត្រូវកើនឡើងៈ

២៥៤គ្រួសារ x ០,០៩ហិកតា/គ្រួសារ = ២២,៨៦ហិកតា

-ដូច្នេះរហូតដល់ឆ្នាំ ២០៣២ ដីលំនៅឋាននៅក្នុងឃុំសំព្រោជត្រូវកើនឡើងដល់ៈ

២៥០ហិកតា + ២២,៨៦ហិកតា = ២៧២,៨៦ហិកតា

-ចំណែកការដោះស្រាយដីលំនៅឋានជូនគ្រួសារដែលគ្មានដីពិតប្រាកដចំនួន៥១គ្រួសារតាមរយៈ

សម្បទានសង្គមកិច្ចមានចំនួនៈ **៥១គ្រួសារ x ០,២៥ ហិកតា/គ្រួសារ = ១២,៧៥ហិកតា**

តារាង 32៖ តម្រូវការដីសម្រាប់លំនៅឋានក្នុងឆ្នាំ២០៣២

បរិយាយ	២០១៧ បច្ចុប្បន្ន	អនាគត ២០៣២	បម្រែបម្រួលតម្រូវការដី
គ្រួសារ	២ ៨០៨គ្រួសារ	៣ ០៦២គ្រួសារ	២៥៤គ្រួសារ
តម្រូវការដីលំនៅឋាន	២៥០ហិកតា	២៧២,៨៦ហិកតា	២២,៨៦ហិកតា

ប្រភពទិន្នន័យ៖ *ក្រុមការងារបច្ចេកទេស អេស ប៊ី ខេ*

ខ. ដីកសិកម្ម

ចំពោះដីកសិកម្មសំដៅទៅលើដីសម្រាប់ធ្វើស្រែ និងដីចម្ការដំណាំ។នៅពេលវិស័យកសិកម្មកំពុងមានការវិវឌ្ឍពីកសិកម្មបែបបុរាណ ទៅជាកសិឧស្សាហកម្មនោះ តម្រូវការដីថ្មីសម្រាប់អភិវឌ្ឍវិស័យកសិកម្ម និងកសិឧស្សាហកម្ម ក៏មានកំណើនខ្ពស់លើសពីការរំពឹងទុកផងដែរ។ នៅក្នុងឆ្នាំ២០១៧ ដែលជាឆ្នាំគោលយើងបានដឹងថា ដីកសិកម្មមានផ្ទៃដីទំហំ ៩ ៧៣៧ហិកតា និងមានគ្រួសារសរុបចំនួន ២ ៨០៨គ្រួសារ អាចធ្វើស្រែផលិតស្រូវបានសល់ពីការហូបចុកខ្លះសម្រាប់ការនាំចេញទៅទីផ្សារដោះស្រាយជីវភាព គឺជាស្ថានភាពដែលប្រជាពលរដ្ឋអាចរស់នៅក្នុងជីវភាពសមរម្យបានលើកលែងតែគ្រួសារចំនួន៤៣១គ្រួសារប៉ុណ្ណោះ ដែលមិនមានដីសម្រាប់ធ្វើកសិកម្មផ្ទាល់ខ្លួន និងមួយចំនួនស៊ីឈ្នួលគេ ។

ដូច្នេះបច្ចុប្បន្នទំហំដីកសិកម្មសម្រាប់មួយគ្រួសារមានចំនួន៖

៩ ៧៣៧ហិកតា / ២ ៨០៨គ្រួសារ = ៣,៤៧ហិកតា/គ្រួសារ

តែបើតាមអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច ចែងតម្រូវឱ្យមានដីកសិកម្មយ៉ាងច្រើន២ហិកតាក្នុង១គ្រួសារ ដែលអាចប្រើប្រាស់សម្រាប់ដោះស្រាយជូន៤៣១គ្រួសារដែលគ្មានដីពិតប្រាកដសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ដើម្បីអាចទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋ ដែលមាននៅទីតាំងផ្សេងពីឃុំសំព្រោជ ។

ដូច្នេះដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ន ចំពោះប្រជាជនដែលមានកំណើនក្នុងរយៈពេល១៥ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់ធ្វើកសិកម្មចំនួនតាមការគណនាដូចខាងក្រោម៖

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ គ្រួសារកើនឡើងចំនួនៈ ២៥៤គ្រួសារ

-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ (២០១៧-២០៣២) ដីកសិកម្មត្រូវកើនឡើង:

២៥៤គ្រួសារ x ៣,៤៧ហិកតា/គ្រួសារ = ៨៨១,៣៨ហិកតា

-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ(២០១៧-២០៣២) ដីកសិកម្មសរុបមានចំនួន:

៩ ៧៣៧ហិកតា + ៨៨១,៣៨ហិកតា = ១០ ៦១៨,៣៨ហិកតា

ចំណែកការដោះស្រាយដីកសិកម្មជូនគ្រួសារដែលគ្មានដីពិតប្រាកដចំនួន៤៣១គ្រួសារ (ដកចេញគ្រួសារដែលរស់នៅជាមួយឪពុកម្តាយ) តាមរយៈសម្បទានសង្គមកិច្ចមានទំហំដីចំនួន៨២៦ហិកតា ។

៤៣១គ្រួសារ x ២ហិកតា/គ្រួសារ = ៨២៦ហិកតា

តារាង 33៖ តម្រូវការដីសម្រាប់កសិកម្មក្នុងឆ្នាំ២០៣២

បរិយាយ	២០១៧ បច្ចុប្បន្ន	អនាគត ២០៣២	បម្រែបម្រួលតម្រូវការដី
គ្រួសារ	២ ៨០៨គ្រួសារ	៣ ០៦២គ្រួសារ	២៥៤គ្រួសារ
តម្រូវការដីស្រែ	៩ ៧៣៧ហិកតា	១០ ៦១៨,៣៨ហិកតា	៨៨១,៣៨ហិកតា

គ. ដីព្រៃឈើ

ព្រៃឈើផ្តល់នូវផលិតផលនានា ដូចជា ឈើហ៊ុប ឈើគ្រឿងសង្ហារឹម ឈើបង្គោល ឧស និងអនុផលនានា មានជ័រ វល្លិ ឱសថ ដែលគាំទ្រដល់ការចិញ្ចឹមជីវិតរបស់ប្រជាជននៅជនបទ តាមរយៈការប្រើប្រាស់ដោយផ្ទាល់ ឬតាមរយៈការលក់ដូរ ។ ទន្ទឹមនេះ ព្រៃឈើក៏បានដើរតួយ៉ាងសំខាន់ក្នុងចំណោមតួនាទីដទៃទៀត ដូចជាទាក់ទាញទឹកភ្លៀង បញ្ចុះសីតុណ្ហភាព មានអាកាសធាតុបរិសុទ្ធ (ផ្តល់ខ្យល់អាកាសបរិសុទ្ធ) បញ្ចេញឧស្ម័នអុកស៊ីសែន (ជួយស្រូបយកឧស្ម័នកាបូននិច និងបញ្ចេញឧស្ម័នអុកស៊ីសែនដល់មនុស្ស) ការពារគ្រោះធម្មជាតិ (ជួយទប់ទល់ខ្យល់ព្យុះទឹកជំនន់ជួយការពារការហូរច្រោះដី និងបាក់ដី) ធ្វើឱ្យដីមានជីជាតិ ជាតំបន់ទេសចរធម្មជាតិ។ ចំណែកព្រៃលិចទឹកសាបជា ជម្រកត្រីពង ផ្តល់ជីជាតិដី សម្រាប់ធ្វើកសិកម្ម រក្សាជីវសាស្ត្រចម្រុះ ។

ចំពោះឃុំសំព្រោជមានដីព្រៃព្រៃគុម្ពោត ៧,១ហិកតា ស្មើនឹង០,០៣ភាគរយនៃផ្ទៃដីឃុំទាំងមូល ដែលនៅពេលអនាគតក្នុងឃុំសំព្រោជ មិនមានលទ្ធភាពពង្រីកដីបន្ថែមសម្រាប់ព្រៃឈើនោះទេ តែនៅក្នុងឃុំមានលទ្ធភាពក្នុងការដាំដើមឈើបន្ថែមលើដីសាធារណៈផ្សេងៗ ដូចជាតាមដងផ្លូវ ប្រឡាយ អាងស្តុកទឹក សាលាឃុំ សាលារៀន មណ្ឌលសុខភាព និងតាមវត្តអារាមជាដើម សម្រាប់ផ្តល់ផលជាម្លប់ ពណ៌បៃតង ធ្វើឱ្យដីមានជីជាតិ ផ្តល់អុកស៊ីសែន ស្រូបឧស្ម័នកាបូនិកជួយដល់សុខភាពប្រជាពលរដ្ឋ។ល។

ឃ. ធនធានទឹក

ឃុំសំព្រោជ ជាឃុំមានសក្តានុពលទៅលើផ្នែកសិកម្មដំណាំស្រូវ ដែលនាំឱ្យឃុំសំព្រោជមានគោលដៅអភិវឌ្ឍន៍រយៈពេលវែងរបស់ខ្លួនផ្តោតសំខាន់ទៅលើកសិកម្មដំណាំស្រូវមិនអាចគេចចេញបានឡើយ ។ ដូច្នេះដើម្បីជំរុញវិស័យកសិកម្មដំណាំស្រូវ កត្តាចាំបាច់មួយក្នុងចំណោមកត្តាជាច្រើន គឺមានកត្តាទឹកជាកត្តាសំខាន់ដែរដែលត្រូវយកចិត្តទុកដាក់ដោយ ត្រូវធ្វើយ៉ាងណាឱ្យមានទឹកគ្រប់គ្រាន់សម្រាប់ការស្រោចស្រពបានគ្រប់រដូវកាលទៅលើដីស្រែ ដែលឃុំមាន ដើម្បីដោះស្រាយទឹកពេលមានគ្រោះរាំងស្ងួត និងធ្វើស្រែបង្កើនរដូវឱ្យទទួលបានផលិតភាពខ្ពស់ជួយផ្គត់ផ្គង់ដល់ការហូបចុក និងជំរុញការនាំចេញបង្កើនសេដ្ឋកិច្ចគ្រួសារក៏ដូចសេដ្ឋកិច្ចជាតិ ដើម្បីឆ្លើយតបបានទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ។

ចំពោះឃុំសំព្រោជ បច្ចុប្បន្នមានទន្លេ ស្ទឹង បឹង អាងស្តុកទឹក និងស្រះ ដែលមានផ្ទៃដីសរុប ៣ ៣៦៧,២១ហិកតាស្មើនឹង១៥,០៥ភាគរយនៃផ្ទៃដីឃុំទាំងមូល ។ ដូច្នេះនៅពេលអនាគត ឃុំសំព្រោជត្រូវការប្រើប្រាស់ដីបន្ថែមក្នុងតំបន់ដីស្រែ សម្រាប់ការរៀបចំស្តារប្រព័ន្ធប្រឡាយបង្ហូរទឹកចំនួន៩ខ្សែ ប្រវែង២ ៥៥១៣ ម៉ែត្រ ដែលនៅក្នុងនោះមានប្រឡាយមេចំនួន២ខ្សែ ប្រវែង ៥ ៥១៨ម៉ែត្រ និងប្រឡាយតូចចំនួន៧ខ្សែ ប្រវែង ១៩ ០១៣ម៉ែត្រ ទ្វារទឹកចំនួន៣កន្លែង និងលូកាត់ផ្លូវចំនួន១៦កន្លែង បន្ថែមទៅលើប្រព័ន្ធស្រោចស្រពដែលមានស្រាប់ សម្រាប់ការនាំទឹកមកស្រោចស្រពដំណាំស្រូវនៅរដូវប្រាំង និងនៅពេលមានគ្រោះរាំងស្ងួត ហើយក៏អាចជាជម្រកត្រី នាំឱ្យកើនឡើងបរិមាណត្រីបូកផ្សំជាមួយការយកចិត្តទុកដាក់ក្នុងការចិញ្ចឹមត្រីតាមបែបចិញ្ចឹមក្នុងស្រះខ្នាតតូច ស្រះចិញ្ចឹមត្រីតាមគ្រួសារលាយឡំជាមួយបន្លែចម្រុះ និងកសិដ្ឋានចិញ្ចឹមត្រីក្នុងស្រែ ដែលជាទម្រង់មួយនៃវារីវប្បកម្ម ដែលជាបច្ចេកទេសមួយជួយដើម្បីបង្កើនបរិមាណត្រី ដោយអាចបង្កើនផលិតភាពជលផលតាមវាលស្រែ ហើយមានប្រយោជន៍ក្នុងការប្រើត្រីសម្រាប់ទប់ទល់សត្វល្អិត និងដង្កូវហ្វូងក្នុងស្រែដែលបំផ្លាញផលស្រូវផង ដែលអាចផ្តល់ជាប្រភពប្រូតេអ៊ីនសាច់ដ៏សំខាន់បំផុតសម្រាប់ប្រជាពលរដ្ឋក្នុងឃុំគួរទទួលបាននូវអាហារ សម្រាប់ទ្រទ្រង់សុខភាពនិងជីវិតរស់នៅអោយមានភាពល្អប្រសើរ ។

ង. ហេដ្ឋារចនាសម្ព័ន្ធ និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត

ង.១. វិស័យអប់រំ

កុមារគ្រប់រូបមានសិទ្ធិរៀនសូត្រ មិនថាពួកគេស្ថិតនៅក្នុងកាលៈទេសៈបែបណានោះឡើយ ។ ការផ្តល់ការគាំទ្រគ្រប់គ្រាន់ដល់ការរៀនសូត្ររបស់កុមារ មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីឱ្យពួកគេអាចអភិវឌ្ឍខ្លួនឈានទៅសម្រេចបានសក្តានុពលរបស់ពួកគេ ។ យ៉ាងណាមិញនៅក្នុងឃុំសំព្រោជទៅថ្ងៃអនាគត ក្នុងរយៈពេល១៥ឆ្នាំទៅមុខនឹងមានការកើនឡើងនូវចំនួនកុមារ និងមនុស្សវ័យជំទង់ក្នុងវ័យសិក្សា ដូចមានការគណនាក្នុងចំណុច ២.១.២ ស្តីពីចំណោលប្រជាសាស្ត្រខាងលើដែលចាំបាច់ត្រូវគិតគូរដោះស្រាយបន្ទប់រៀនបន្ថែមគ្រប់កម្រិតនៅតាមទីតាំងសាលារៀនដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ន ។

- **មត្តេយ្យសិក្សាៈ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ កុមារមានអាយុពី៣-៥ឆ្នាំ នឹងកើនឡើងចំនួនៈ ១ ៤០៥នាក់

-តាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ បានឱ្យដឹងពីការកំណត់សម្រាប់សាលាមត្តេយ្យ ក្នុងមួយថ្នាក់មានចំណុះកុមារសិក្សារៀនសូត្រ ៥០នាក់

-ដូច្នេះក្នុងរយៈពេល ១៥ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់មត្តេយ្យត្រូវការបន្ថែមចំនួនៈ

១ ៤០៥ នាក់ /៥០ នាក់/បន្ទប់= ២៨បន្ទប់

-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ

២៨ បន្ទប់ / ៥ បន្ទប់/អគារ= ៦ អគារ

- **បឋមសិក្សា**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ៦-១១ ឆ្នាំនឹងកើនឡើងចំនួនៈ ១ ៩៦៩ នាក់

-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់បឋមសិក្សាត្រូវការបន្ថែមចំនួនៈ

១ ៩៦៩នាក់ ៖ ៤៥នាក់/បន្ទប់ = ៤៤បន្ទប់

-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៦ បន្ទប់បន្ថែមចំនួនៈ

៤៤ បន្ទប់ ៖ ៦ បន្ទប់/អគារ = ៧ អគារ

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាតែចំនួនៈ

៧អគារ/វេន ៖ ២ វេន = ៣,៥អគារ=៤អគារ

❖ **អនុវិទ្យាល័យ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ១២-១៤ ឆ្នាំនឹងកើនឡើងចំនួនៈ ១ ០៦៩នាក់

-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់អនុវិទ្យាល័យសិក្សាត្រូវការបន្ថែមចំនួនៈ

១ ០៦៩នាក់ ៖ ៤៥នាក់/បន្ទប់ =២៤បន្ទប់

-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ

២៤បន្ទប់ ៖ ១២បន្ទប់/អគារ = ២អគារ

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាតែចំនួនៈ

២ អគារ / វេន ៖ ២ វេន = ១អគារ

❖ **វិទ្យាល័យ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ១៥-១៧ឆ្នាំនឹងកើនឡើងចំនួនៈ ១ ១៤៧នាក់

-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់អនុវិទ្យាល័យសិក្សាត្រូវការបន្ថែមចំនួនៈ

១ ១៤៧នាក់ ៖ ៤៥នាក់/បន្ទប់ =២៥បន្ទប់

-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ

២៥បន្ទប់ ៖ ១២បន្ទប់/អគារ = ២អគារ

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សារតែចំនួនៈ

២ អគារ / វេន ៖ ២ វេន = ១អគារ

តារាង 34៖ កំណើនកុមារ តម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១៨ ដល់ឆ្នាំ ២០៣២

បរិយាយ	បច្ចុប្បន្ន២០១៧	អនាគត ២០៣២	បម្រែបម្រួល
សាលាមត្តេយ្យ			
សិស្ស	២២២ នាក់	១ ៤០៥នាក់	១ ១៨៣ នាក់
បន្ទប់	៤ បន្ទប់	២៨ បន្ទប់	២២ បន្ទប់
អគារ	៣ អគារ	៦ អគារ	៣ អគារ
សាលាបឋមសិក្សា			
សិស្ស	១ ៨០៨នាក់	១ ៩៦៩នាក់	១៦១នាក់
បន្ទប់	៥៧ បន្ទប់	៤៤ បន្ទប់	-១៣បន្ទប់
អគារ	៨ អគារ	៧ អគារ	-១អគារ
អនុវិទ្យាល័យ			

សិស្ស	៥២៣ នាក់	១ ០៦៩ នាក់	៥៤៦ នាក់
បន្ទប់	១៦ បន្ទប់	២៥ បន្ទប់	៩ បន្ទប់
អគារ	១ អគារ	២ អគារ	១ អគារ
វិទ្យាល័យ			
សិស្ស	0	១ ១៤៧ នាក់	១ ១៤៧ នាក់
បន្ទប់	0	២៥ បន្ទប់	២៥ បន្ទប់
អគារ	0	២ អគារ	២ អគារ

ង.២. វិស័យសុខាភិបាល

នៅក្នុងឃុំសំព្រោជ មានមណ្ឌលសុខភាព១កន្លែង ដែលស្ថិតនៅក្នុងភូមិគោកស្នាយ ហើយបើផ្អែកទៅតាមកំណើនប្រជាជនដែលមានការកើនឡើង និងស្ថានភាពភូមិសាស្ត្ររបស់ឃុំទាំងមូល យើងឃើញថាភូមិដែលនៅឆ្ងាយពីមណ្ឌលសុខភាពមានចំនួន៩ភូមិ (ភូមិមឈាយ ភូមិអំពិល ភូមិប្រឌិត ភូមិស្លាក់ក្រាញ់ ភូមិត្រាចជ្រុំ ភូមិពៃ ភូមិចំបក់ខ្ពស់ ភូមិដូនល្អ និងភូមិអូររំចេក)។ ជាយុទ្ធសាស្ត្រក្រុមប្រឹក្សាឃុំអាណត្តិទី៤ ក៏ដូចជាមេភូមិ បានរៀបចំផែនការបង្កើតឱ្យមានមណ្ឌលសុខភាព១កន្លែងទៀត ក្នុងភូមិស្លាក់ក្រាញ់ សម្រាប់ភូមិមឈាយ ភូមិអំពិល ភូមិប្រដិត ភូមិអំពៅព្រៃ ភូមិចំបក់ខ្ពស់ ភូមិត្រាចជ្រុំ បន្ថែមទៀតរយៈពេល១៥ឆ្នាំខាងមុខដើម្បីងាយស្រួល ផ្តល់ការគាំទ្រសេវាថែទាំ និងព្យាបាលសុខភាពផ្សេងៗរបស់ប្រជាពលរដ្ឋបានរហ័សទាន់ចិត្ត និងកាត់បន្ថយការចំណាយរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានមកមណ្ឌលសុខភាព ឬពេទ្យបង្អែកស្រុក ដែលមានទីតាំងឆ្ងាយ ។

ង.៣. អគ្គិសនី

អគ្គិសនីមានសារៈសំខាន់ណាស់សម្រាប់ជីវិតរស់នៅរបស់មនុស្សយើង ។ អគ្គិសនីផ្តល់ឱ្យយើងនូវសន្តិសុខ សុវត្ថិភាព សុខភាព និងភាពសម្បូររុងរឿង ដូចជាជួយដោះស្រាយបញ្ហា និងធ្វើឱ្យកាន់តែប្រសើរឡើងនូវសន្តិសុខ សុវត្ថិភាព ការប្រែប្រួលអាកាសធាតុ ផលិតកម្មស្បៀងអាហារ និងការពង្រឹងសេដ្ឋកិច្ចដោយរួមទាំងការអប់រំ និងកម្សាន្តផងដែរ ។

ចំពោះស្ថានភាពការប្រើប្រាស់អគ្គិសនីនៅក្នុងឃុំសំព្រោជ ដូចបានរៀបរាប់ក្នុងជំពូកទី១ បច្ចុប្បន្នមានប្រជាពលរដ្ឋប្រើប្រាស់បណ្តាញអគ្គិសនីមានចំនួន៦៦,២ភាគរយប៉ុណ្ណោះ បានតភ្ជាប់បណ្តាញអគ្គិសនីរដ្ឋប្រើប្រាស់ ហើយនៅសល់គ្រួសារប្រមាណ២៤ភាគរយដែលមិនទាន់បានទទួលសេវាកម្មនេះនៅឡើយ។ ដូច្នេះនៅពេលអនាគត១៥ឆ្នាំទៅមុខនឹងមានការកើនឡើងចំនួនគ្រួសារថែមទៀត អាជ្ញាធរពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ជាពិសេសក្រុមប្រឹក្សាឃុំកំពង់ស្វាយត្រូវខិតខំយកចិត្តទុកដាក់ក្នុងការដោះស្រាយពង្រីកបណ្តាញអគ្គិសនី តភ្ជាប់ផ្គត់ផ្គង់ឱ្យដល់គ្រប់គ្រួសារបានប្រើប្រាស់ ។

ង.៤. ទីលានចាក់សំរាម

សំរាម គឺជាកាកសំណល់ដែលគេបានបោះបង់ចោល វាមានពីរបែប គឺកាកសំណល់រឹង និងរាវ។ ដូច្នេះ សំរាមគឺជាអ្វីដែលបំបែកចេញពីបរិស្ថានយើង និងជាការបង្កើតកន្លែងគរមួយផ្សេងទៀតប្រសិនបើយើងមិនប្រុងប្រយ័ត្ន។ មានគំនរសំរាមដូចជា កាកសំណល់ផ្ទះបាយដាក់លាយឡំចូលគ្នាជាមួយនឹង អំបែងកែវ អំបែងចាន

និងអំបែងដបជាដើម។ នៅពេលមានភ្លៀងធ្លាក់ចុះមក គឺដូចជាការចម្រោះជាតិពុល គ្រប់បែបយ៉ាង ឱ្យហូរជ្រាបទៅបំពុលដី បំពុលទឹក និងបំពុលដល់ប្រភពទឹកនៅក្នុងស្រទាប់ដីខាងក្រោម ជាហេតុធ្វើឱ្យទឹកស្អាតក្លាយជាទឹកមិនស្អាត មានលោហៈធ្ងន់ និងជួនកាលមានបាក់តេរីកាចៗ ដែលនៅពេលនោះ មានលេចឡើងនូវជម្ងឺរាតត្បាតផ្សេងៗដោយសារតែការទទួលទានទឹកមិនស្អាត ។

ចំពោះសំរាមនៅក្នុងឃុំសំព្រោជ បច្ចុប្បន្នប្រជាពលរដ្ឋភាគច្រើនបោះចោលសំរាមនៅក្បែរផ្ទះ ខ្លះចោលរាយប៉ាយនៅតាមផ្លូវ ខ្លះដុតចោល ដែលធ្វើឱ្យរងការបំពុលពីផ្សែងដុត និងបាត់បង់សោភ័ណភាពក្នុងភូមិ ឃុំ។ ដើម្បីអាចគ្រប់គ្រងសំរាមបាន ឃុំត្រូវរកដីដែលមានទីតាំងសមស្របនៅក្នុងឃុំដែលនៅដាច់ដោយឡែកឆ្ងាយពីភូមិធ្វើទីលានចាក់សំរាមមួយកន្លែង ក៏គួរបង្កើតឱ្យមានឡដុតសំរាមនៅក្នុងឃុំនេះផងដែរ ដើម្បីប្រមូលសំរាមដែលមាននៅក្នុងឃុំទៅរក្សាទុកឱ្យបានគត់មត់ ឬត្រូវប្រមូលសំរាមប្លាស្ទីក យកទៅកែច្នៃផលិតឡើងវិញចំណែកសំរាមពីផ្ទះបាយនិងស្លឹកឈើផ្សេងពីប្លាស្ទីកអាចកែច្នៃធ្វើជីដូចជាជីកំប៉ុស្តជាដើម ដើម្បីប្រើប្រាស់ក្នុងការបង្កើនគុណភាពដីដាំដុះ ។ ជារួមសំខាន់ជាងគេបំផុត គឺត្រូវលុបបំបាត់សំរាមប្លាស្ទិកឱ្យអស់ពីភូមិ ឃុំ ។

ង.៥. ដីកប់ខ្មោច

ជាទូទៅពិធីបូជាសព មានពីរបែបគឺពិធីដុតសព និងកប់សពរក្សាក្នុងដី ដែលពិធីទាំងពីរនេះពីធីកប់សពត្រូវការប្រើប្រាស់ដី ដែលធ្វើឱ្យមានការបាត់បង់ដីសម្រាប់ប្រើប្រាស់បម្រើឱ្យការអភិវឌ្ឍន៍ក្នុងសហគមន៍ដែលមនុស្សរស់នៅ។ នៅក្នុងឃុំសំព្រោជបច្ចុប្បន្នក៏មានប្រើពិធីទាំងពីរនេះដែរ ហើយការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជ ក៏មានតម្រូវការកាន់តែច្រើនឡើងស្របទៅនឹងអត្រាមរណៈរបស់ប្រជាជនទៅថ្ងៃអនាគត ដែលចាំបាច់អាជ្ញាធរដែនដីពាក់ព័ន្ធជាពិសេសក្រុមប្រឹក្សាឃុំសំព្រោជត្រូវខិតខំយកចិត្តទុកដាក់គិតគូរអំពីពិធីបូជាសពនេះដែលនឹងកើតឡើងជាបន្តបន្ទាប់ ដោយគួរខិតខំលប់បំបាត់ការបញ្ចុះសពដោយកប់ក្នុងដី ហើយជំនួសមកវិញដោយការរៀបចំឱ្យមានកន្លែងបូជាសពនៅតាមវត្តអារាម ឬកន្លែងណាផ្សេងដាច់ឆ្ងាយពីភូមិដែលជាជម្រើសល្អបំផុត ។

ង.៦. ស្រះ និងអណ្តូងទឹក

ទឹក គឺជាផ្នែកមួយនៃធាតុដ៏សំខាន់បំផុតសម្រាប់រាងកាយមនុស្ស ជាពិសេសសម្រាប់សុខភាពដើម្បីធានាបាននូវការរស់រានមានជីវិតរបស់មនុស្ស ។ ទឹកអាចនឹងមាននៅគ្រប់ទីកន្លែង ប៉ុន្តែមិនត្រូវបានយកមកសម្រាប់ការទទួលទានបានទាំងអស់នោះទេគឺត្រូវការទឹកដែលស្អាត។ នៅក្នុងឃុំសំព្រោជ បច្ចុប្បន្នមានការប្រើប្រាស់ទឹកស្អាតសម្រាប់ទទួលទានតាមរយៈការប្រើទឹកស្រះ និងអណ្តូងដូចបានរៀបរាប់ក្នុងជំពូកទី១នៃរបាយការណ៍នេះ ប៉ុន្តែបានរកឃើញថា ចំនួនស្រះទឹកនិងអណ្តូងទាំងអស់នេះមិនមានបរិមាណគ្រប់គ្រាន់សម្រាប់បំពេញតម្រូវរបស់មនុស្ស និងសត្វចិញ្ចឹមគ្រប់គ្រាន់នារដូវប្រាំងបានឡើយ ។

ដូច្នេះដើម្បីឆ្លើយតបទៅនឹងការខ្វះខាតនាពេលបច្ចុប្បន្ន ក៏ដូចជាឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋក្នុងរយៈពេល១៥ឆ្នាំខាងមុខបាន អាជ្ញាធរដែនដីពាក់ព័ន្ធជាពិសេសក្រុមប្រឹក្សាឃុំសំព្រោជ ត្រូវយកចិត្តទុកដាក់លើកទឹកចិត្តឱ្យប្រជាពលរដ្ឋក្នុងឃុំត្រងទឹកភ្លៀងនៅរដូវវស្សា រក្សាទុកក្នុងអាងស្តុកតាមផ្ទះរៀងៗខ្លួនសម្រាប់ទុកដោះស្រាយការប្រើប្រាស់នៅរដូវប្រាំងដែលខ្សត់ទឹក ហើយថែមពីលើនេះទៀត ក៏ត្រូវបំផុសឱ្យមានការរៀបចំជីកស្រះសហគមន៍ផងដែរ ព្រមទាំងជំរុញលើកទឹកចិត្តដល់វិស័យឯកជនឱ្យផលិតទឹកស្អាតតបណ្តាញឱ្យដល់គ្រប់ខ្នងផ្ទះប្រជាពលរដ្ឋបានប្រើប្រាស់គ្រប់ក្រុមគ្រួសារដែលជាជម្រើសដ៏ល្អបំផុត ។

២.២. តំបន់រសើប

តំបន់រសើប ជាតំបន់ដែលទាមទារនូវការការពារបន្ថែម និងជាពិសេសដោយផ្អែកលើសារៈសំខាន់ ឬជីវចម្រុះនៃបរិស្ថាន បេតិកភ័ណ្ឌវប្បធម៌ តម្លៃខាងផ្លូវចិត្តដែលមានលក្ខណៈដូចជា៖ តំបន់ប្រពៃណីសម្រាប់ជនជាតិដើមភាគតិច ឬក៏មូលហេតុសំខាន់ៗផ្សេងទៀត។ តំបន់បង្ហាញបញ្ហាចោទ ចាំបាច់ត្រូវតែកំណត់ ដើម្បីធានាថាឃុំ/សង្កាត់ត្រូវការដឹងឮនូវតម្រូវការ និងប្រធានបទពិសេសទាំងនេះ។ តំបន់រសើបដែលមានក្នុងឃុំ នៅភាគខាងជើងដែលជាតំបន់លំនៅឋាន មានដីសង្ស័យថាមានគ្រាប់មិនទាន់ផ្ទុះចំនួន០២កន្លែង ដែលស្ថិតនៅក្នុងភូមិមឈាយ និងតំបន់ស្រែប្រាំងនិងស្រែវស្សា និងតំបន់ស្រែប្រាំង ដែលស្ថិតនៅផ្នែកកណ្តាលរបស់ឃុំសំព្រោជស្ថិតនៅក្នុងតំបន់២ជុំវិញបឹងទន្លេសាប ដែលត្រូវទាមទារនូវកិច្ចការពារបន្ថែមពិសេស ដើម្បីធ្វើការហាមឃាត់ប្រជាពលរដ្ឋចូលទៅកាន់កាប់ និងប្រើប្រាស់ដីតំបន់នេះ ដែលនឹងនាំឱ្យពួកគាត់មានគ្រោះថ្នាក់ពីគ្រាប់មីន ដែលមិនទាន់ផ្ទុះទាំងនោះ និងតំបន់៣ជុំវិញបឹងទន្លេសាប តំបន់សហគមន៍នេសាទ តំបន់ប្រើប្រាស់ច្រើនយ៉ាង ទីទួលបុរាណ ប្រាសាទ និងស្ថានីយបុរាណ ក្នុងការការពារ និងថែរក្សា ។ តំបន់រសើបដែលមាននៅក្នុងឃុំសំព្រោជ ដូចបានរៀបរាប់ខាងលើមានបង្ហាញនៅក្នុងផែនទីតំបន់រសើបខាងក្រោម ។

ផែនទី 10៖ ផែនទីតំបន់រសើប ឃុំសំព្រោជ



២.៣.ការប្រឈម

២.៣.១.ការប្រឈមដោយធម្មជាតិ

ក. កំណើនប្រជាជន

បច្ចុប្បន្នក្នុងឃុំសំព្រោជ បានរកឃើញថា ប្រជាពលរដ្ឋបានកើនឡើងតាមធម្មជាតិជារៀងរាល់ឆ្នាំគិតជាមធ្យមប្រមាណ០,៦ភាគរយ ហើយទៅថ្ងៃអនាគតត្រឹមឆ្នាំ២០៣២ បញ្ហាកំណើនប្រជាជនត្រូវបានគិតគូរដោះស្រាយដោយពុំមានបញ្ហាប្រឈមធ្ងន់ធ្ងរឡើយ តែបន្តពីនេះទៅមុខវែងឆ្ងាយនឹងអាចកើតមានបញ្ហាប្រឈមដែលត្រូវបន្តដោះស្រាយមួយចំនួនដូចខាងក្រោម៖

-មានការខ្វះខាតដីលំនៅឋាន ដែលនាំឱ្យមានការដោះស្រាយផលប៉ះពាល់ទៅដល់ដីស្រែ។

-មានការខ្វះខាតដីស្រែ ដែលនាំឱ្យពិបាកដោះស្រាយ ដោយនៅក្នុងឃុំពុំមានដីសល់ទំនេរសម្រាប់បំពេញការខ្វះខាតនេះ។

-មានការខ្វះខាតដល់ការផ្តល់សេវាអប់រំ ដែលត្រូវដោះស្រាយការសាងសង់សាលារៀន គ្រូបង្រៀននិងសម្ភារៈសិក្សាបន្ថែម។

-មានការខ្វះខាតសេវាសុខាភិបាល ដែលត្រូវដោះស្រាយគ្រូពេទ្យ ឧបករណ៍ និងសម្ភារៈបរិក្ខាពេទ្យ និងថ្នាំសង្កូវបន្ថែម។

-មានការខ្វះខាតទឹកស្អាត អគ្គិសនី ដែលត្រូវដោះស្រាយ សម្រាប់ការផ្គត់ផ្គង់បន្ថែម។

ខ. គ្រោះធម្មជាតិ ការរេចរឹល នៃធម្មជាតិ

បច្ចុប្បន្ននៅក្នុងឃុំសំព្រោជ គេបានកត់សម្គាល់ថា មានជួបប្រទះនូវគ្រោះធម្មជាតិកើតឡើងស្ទើរតែរៀងរាល់ឆ្នាំ ដូចជាគ្រោះរាំងស្ងួត ទឹកជំនន់ ជាដើម ។ ទន្ទឹមនេះ ដីធ្លីដែលជាធនធានធម្មជាតិកម្រនៅក្នុងឃុំសំព្រោជក៏មានភាពរេចរឹលទៅៗផងដែរដូចជាធ្វើឱ្យដីស្រែរឹង និងខ្សោះជីជាតិដោយសារការប្រើប្រាស់ជីគីមី និងថ្នាំគីមីសម្លាប់សត្វល្អិតលើដំណាំស្រូវ និងដំណាំដទៃទៀត មិនស្របតាមបទដ្ឋានបច្ចេកទេស ព្រមទាំងមានការថយចុះ និងបាត់បង់ធនធានជលផលជាពិសេសមច្ឆាជាតិ ដោយការប្រើប្រាស់ឧបករណ៍ឆក់ដែលជាឧបករណ៍នេសាទខុសច្បាប់ ។ ទៅថ្ងៃអនាគតប្រជាពលរដ្ឋនៅតែបន្ត ជួបប្រទះនូវបញ្ហាប្រឈមទាំងអស់នេះជាដដែល បើមិនមានយន្តការ ឬដំណោះស្រាយទប់ទល់នឹងគ្រោះរាំងស្ងួត ព្រមទាំងមានការកែប្រែឥរិយាបថក្នុងការប្រើប្រាស់ដីធ្លីសម្រាប់កសិកម្មឱ្យបានសមស្របទេនោះ ។

២.៣.២. ការប្រឈមដោយ ការអភិវឌ្ឍន៍ដែលពុំមាននិរន្តរភាព

ជាការពិតណាស់រាល់គម្រោងអភិវឌ្ឍនានា ពាក់ព័ន្ធការប្រើប្រាស់ធនធានធម្មជាតិ ជាពិសេសការប្រើប្រាស់ដីក្នុងទីតាំងភូមិសាស្ត្រណាមួយ តែងនាំមកការរីកចម្រើនជានិច្ច តែផ្ទុយទៅវិញបើគម្រោងអភិវឌ្ឍន៍ទាំងនោះពុំទាន់បានគិតគូរគ្រប់ជ្រុងជ្រោយទៅដល់ទីតាំងភូមិសាស្ត្រនីមួយៗ និងសក្តានុពលនៃធនធានដែលមាន វានឹងនាំមកនូវផលប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ច សង្គម និងបរិស្ថាននាពេលអនាគត ដោយមិនអាចធានាចីរភាពនៃគម្រោងទាំងនោះដល់កូនចៅជំនាន់ក្រោយក្នុងតំបន់នោះបានឡើយ ដូចជាស្ថានភាពនៅក្នុងឃុំសំព្រោជ ដែលជាឃុំគោលដៅសិក្សារៀបចំផែនការប្រើប្រាស់ដីដូចបានរៀបរាប់ក្នុងជំពូកទី១ នៃរបាយការណ៍នេះបានឱ្យដឹងថា ឃុំសំព្រោជ មានស្ថានភាពភូមិសាស្ត្រជាវាលទំនាបមានធនធានដីអំណោយផលដល់ដំណាំស្រូវ ដែលជា

សក្តានុពលដល់ការអភិវឌ្ឍដល់ឃុំនេះ ដោយមិនមានការអះអាងណាផ្សេងក្រៅពីនេះនៅឡើយ ។ ដូចនេះឃុំសំព្រោជ គួរជៀសវាងដាច់ខាតនៅគម្រោងអភិវឌ្ឍន៍ទាំងឡាយណាដែលនាំឱ្យមានផលប៉ះពាល់ដល់ការបាត់បង់ដីស្រែនិងដីចំការដំណាំដែលខ្លួនមាន ធ្វើឱ្យឃុំសំព្រោជមានការថយចុះឱកាសអភិវឌ្ឍ ដូចជាគម្រោងចាក់លុបដីស្រែ ដីចំការបង្កកទុកលក់ ឬពុះដីឡូត៍លក់ ដើម្បីកេងផលចំណេញពីឈ្មួញ និងគម្រោងជីកយកអាចម៍ដីយកលក់ជាដើម ។ លើកលែងតែគម្រោងណាដែលពាក់ព័ន្ធដែលធ្វើឱ្យប្រសើរឡើងដល់ប្រព័ន្ធកសិកម្មដូចជាកសិដ្ឋានផលិតពូជស្រូវ ពូជដំណាំ ស្រែគម្រូផលិតជីធម្មជាតិ ទុកដាក់គ្រឿងយន្តកសិកម្ម ទន្ទឹមនិងនេះក៏នៅមានគម្រោងអភិវឌ្ឍដល់ការរស់នៅនិងបរិស្ថាន ដែលគួរ ចៀសវាងផងដែរ ដូចជាគម្រោងបង្កើតសិប្បកម្ម ឧស្សាហកម្ម ដែលធ្វើឱ្យមានការបង្ហូរទឹកស្អុយកខ្វក់ជាដើម។ល។ ទន្ទឹមនឹងការប្រឈមដោយការអភិវឌ្ឍខាងលើដែលត្រូវ ចៀសវាង ក៏នៅមានការប្រឈមទៅ និងអំពើអនាធិបតេយ្យដែលកើតឡើងពីការដោះស្រាយការខ្វះខាតរបស់ប្រជាពលរដ្ឋក្នុងឃុំផងដែរ ដូចជាការសាងសង់ផ្ទះស្នាក់លើដីនៅតាមមាត់ប្រឡាយ តាមចិញ្ចើមផ្លូវ សាធារណៈ ការទន្ទ្រានដីទួលសាធារណៈ ធ្វើស្រែបំពានលើប្រឡាយ និងបឹង ព្រមទាំងការនេសាទខុសច្បាប់ជាដើម ។

២.៤. ឱកាស

២.៤.១.ដោយអំណោយផលពីធម្មជាតិ

នៅលើលោកយើងនេះ ធម្មជាតិបានផ្តល់នូវធនធានដ៏មានសារសំខាន់សម្រាប់ធ្វើអ្វីៗគ្រប់យ៉ាង ដែលមនុស្សចង់ធ្វើ ដូចជាមនុស្សប្រើប្រាស់ដីនឹងទឹកសម្រាប់ការដាំដំណាំ ឈើធ្វើឧសអុសដុតសម្រាប់ផ្តល់កំដៅ ឬសាងសង់ទីជម្រក ខ្យល់អាកាស ធ្យូងថ្ម ប្រេង ឧស្ម័នធម្មជាតិ និងរ៉ែជាវត្ថុធាតុដើមជាច្រើនទៀត ដូចជាដែកទង់ដែង។ល។ សម្រាប់ធ្វើឧបករណ៍ប្រើប្រាស់ផ្សេងៗ ។ ចំណែកនៅក្នុងឃុំសំព្រោជ យើងផ្តោតសំខាន់ទៅធនធានដីដែលមានសក្តានុពលលើសលប់ទៅលើការអភិវឌ្ឍន៍ឃុំ ដូចបានរកឃើញ និងរៀបរាប់នៅក្នុងជំពូកទី១នៃរបាយការណ៍នេះ ។ នៅក្នុងឃុំសំព្រោជមានស្ថានភាពអំណោយផលពីធម្មជាតិដូចខាងក្រោម៖

- ស្ថានភាពដីជាវាលទំនាប អំណោយផលដល់ការដាំដុះដំណាំស្រូវ
- នៅជិតប្រភពស្ទឹង បឹង អូរ អាចមានលទ្ធភាពនាំទឹកមកស្រោចស្រពដំណាំស្រូវ នៅពេលជួបប្រទះគ្រោះរាំងស្ងួត និងមានលទ្ធភាពនាំទឹកមកស្រោចស្រពបង្កើនរដូវធ្វើស្រែបានច្រើនដង ។
- នៅរដូវវស្សាមានភ្លៀងធ្លាក់ច្រើនអាចស្រោចស្រពដំណាំស្រូវ ។
- អាកាសធាតុ ក្តៅ ហើយសើម ជាអំណោយផលដល់ការលូតលាស់របស់រុក្ខជាតិ និងដំណាំគ្រប់ប្រភេទ ។

២.៤.២.ដោយបច្ចេកវិទ្យាថ្មីៗ

ជីវិតរស់នៅ ដែលយើងកំពុងទទួលបានប្រសើរឡើងនាពេលបច្ចុប្បន្ននេះ គឺដោយសារតែមានការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា ។ បច្ចេកវិទ្យាថ្មីៗ ធ្វើឱ្យមានការផ្លាស់ប្តូរបានយ៉ាងប្រសើរឡើងនៃជីវិតរស់នៅរបស់ពលរដ្ឋ ដែលធ្វើឱ្យអ្វីៗ ក្នុងពេលបច្ចុប្បន្នកាន់តែប្រសើរឡើង និងងាយស្រួលជាងមុន ។ បច្ចេកវិទ្យាថ្មីអាចកាត់បន្ថយបាននូវពេលវេលា គុណភាព និងការចំណាយទៅលើកម្លាំងពលកម្មក្នុងផលិតកម្មនានា ។

បច្ចុប្បន្ន ស្ថានភាពនៅក្នុងឃុំសំព្រោជ មានសក្តានុពលខ្លាំងដោយពឹងផ្អែកទៅលើផលិតកម្មដំណាំស្រូវ ហើយនាពេលអនាគតក៏នៅតែពឹងផ្អែកលើផលិតកម្មដំណាំទាំងនេះដដែលដែរនោះ ប្រជាពលរដ្ឋនឹងចាំបាច់ត្រូវការបច្ចេកវិទ្យាទំនើបទាន់សម័យសម្រាប់វិស័យកសិកម្មដំណាំស្រូវ ដើម្បីជួយជំរុញឱ្យមានការកើនឡើងទិន្ន

ផលខ្ពស់ ដោះស្រាយបាននូវសន្តិសុខស្បៀង និងប្រាក់ចំណូលកាន់តែខ្ពស់ នាំឱ្យជីវភាពរស់របស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើងក្នុងពេលដែលមានកំណើនប្រជាពលរដ្ឋកាន់តែខ្ពស់ ។ តាមរយៈបច្ចេកវិទ្យាថ្មី នឹងនាំឱ្យប្រជាពលរដ្ឋមានឱកាសអាចប្រើប្រាស់គ្រឿងយន្តកសិកម្មទំនើបទាន់សម័យសម្រាប់ការផលិតដំណាំស្រូវ ដែលរួមមានដូចជា៖ ម៉ាស៊ីនភ្ជួររាស់ដី ម៉ាស៊ីនពង្រាបដីស្រែដោយប្រើប្រព័ន្ធឡាស៊ែរ ម៉ាស៊ីនដកស្ទូង ជ្រូនបាញ់ថ្នាំសម្លាប់សត្វល្អិតនិងដាក់ជី ម៉ាស៊ីនច្រូតកាត់ និងបោកបែន ព្រមទាំងគ្រឿងយន្តដឹកជញ្ជូនជាដើម ។ល។

២.៤.៣.ដោយគម្រោងវិនិយោគ

សម្រាប់នាពេលអនាគត នៅឃុំសំព្រោជ ដែលមានសក្តានុពលខ្ពស់ទៅលើដំណាំស្រូវ នឹងនាំឱ្យមានផ្តួចផ្តើមបង្កើតគម្រោងវិនិយោគនានា ដែលភាគច្រើនផ្តោតទៅលើដំណាំស្រូវ ដូចជាគម្រោងបង្កើត កសិដ្ឋានកសិកម្មដើម្បីជំរុញផលិតកម្មដំណាំស្រូវ គម្រោងវិនិយោគទៅលើការកែច្នៃផលិតផលកសិកម្មដើម្បីនាំចេញ ដែលនឹងផ្តល់ការងារបន្ថែមដល់ប្រជាពលរដ្ឋ ដើម្បីបង្កើនប្រាក់ចំណូលអោយបានកាន់តែខ្ពស់ នាំឱ្យជីវភាពរស់នៅកាន់តែប្រសើរឡើង ព្រមទាំងកាត់បន្ថយបាននូវភាពក្រីក្រ ស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។

២.៥. បញ្ហា មូលហេតុ និងដំណោះស្រាយ

ផ្អែកតាមការរកឃើញនៅក្នុងជំពូកទី១នៃរបាយការណ៍នេះ អាចឱ្យយើងធ្វើការវិភាគ និងចងក្រងបាននូវបញ្ហាដែលកើតមាននៅក្នុងឃុំសំព្រោជ មូលហេតុដែលនាំឱ្យកើតមានបញ្ហា និងដំណោះស្រាយលើបញ្ហាទាំងអស់នេះ ដោយមានបង្ហាញអំពីទីតាំងដែលកើតមានបញ្ហានៅក្នុងតារាង ព្រមទាំងកំណត់បាននូវទីតាំងបញ្ហានៅក្នុងផែនទីទៀតផងដែរ ដូចមាននៅខាងក្រោមនេះ៖

តារាង 35៖ បញ្ហាប្រឈម និងសក្តានុពល(ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ)

បញ្ហាប្រឈម	**ទីតាំងនៃបញ្ហា**	**មូលហេតុនៃបញ្ហា**	**ដំណោះស្រាយ**
១	២	៣	៥
១.ខ្វះដីលំនៅឋានក្នុងភូមិ(៥១គ្រួសារ)	ភូមិពៃ	ក-កំណើនប្រជាជនក្នុងស្រុក (អាពាហ៍ពិពាហ៍ និង បំបែកគ្រួសារថ្មី)	ក-មន្ទីរ ឬក្រសួង ពាក់ព័ន្ធ ដោះស្រាយដីសម្បទានសង្គមកិច្ច។
២.គ្រាប់មីននៅសេសសល់	ភូមិមឈាយ ភូមិស្លាក់ក្រាញ់	ក-ជាកន្លែងសមភូមិប្រយុទ្ធ	ក.១-ដាក់សញ្ញាសម្គាល់ដីដែលមានមីន និងគ្រាប់មិនទាន់ផ្ទុះ
			ក.២-ដាក់សំណើទៅអង្គភាពកំចាត់ មីនឬអង្គការដើម្បី ជួយអន្តរាគមន៍
៣.កង្វះខាតទីលានទុកដាក់សំរាម ក្នុងឃុំ	របស់ឃុំរួម	ក-គ្មានសណ្តាប់ធ្នាប់ មិនមានទីតាំងសមរម្យ	ក.១-មន្ទីរ ឬក្រសួង ពាក់ព័ន្ធ ដោះស្រាយដីសម្បទានសង្គមកិច្ច។
		ខ-កង្វះខាតទីលានចាក់សំរាម(អត់មានដី) គ-ចោលសម្រាមលើដីសារធារណៈរបស់រដ្ឋ	ខ.គ.១-យល់ដឹងពីការបែងចែកសំរាម (ប្រភេទសម្រាមនីមូល) ខ.គ.២-ជម្រុញឱ្យក្រុមហ៊ុនវិនិយោគ ក្នុងការប្រមូលសំរាមកែច្នៃ

៤.ផ្លូវពិបាកធ្វើដំណើរ ចំពោះ ផ្លូវគ្រួសក្រហម	១.ភូមិត្រាចជ្រុំ ២.ភូមិចំបក់ខ្ពស់ ៣.ភូមិពគ្លក	ក-ផ្លូវខូច	ក.១-ជួសជុលផ្លូវលំក្រាលគ្រួសក្រហម ក.២-ក្រាលបេតុង ឬ កៅស៊ូ
		ខ-ផ្លូវត្រូវទឹកហូរដាច់ (ទឹកភ្លៀង)	ខ.១-ដាក់លូអមផ្លូវ
		គ-គ្មានស្ពានឆ្លង	គ.១-ធ្វើស្ពានឆ្លង
៥.ខ្វះដីកសិកម្ម (៤៣១គ្រួសារ)	១.ភូមិត្រាចជ្រុំ ២.ភូមិចំបក់ខ្ពស់ ៣.ភូមិពគ្លក	ក-លក់សងបំណុល ខ-កំណើនគ្រួសារក្នុងភូមិ គ-គ្មានដីកសិកម្មបម្រុងទុក	ក.ខ.គ.១-ស្នើសុំដីសម្បទានសង្គមកិច្ច
		ឃ-ដីកសិកម្មតិច	ឃ.១-ផ្តល់បច្ចេកទេសកសិកម្មទំនើបៗ
៦.ខ្វះប្រព័ន្ធស្រោចស្រពសំខាន់ៗ (ប្រឡាយមេ. ប្រឡាយរង. ទ្វារទឹក. អាងស្តុកទឹក. ព្រែក. បឹង. ព្រែក. អូរ....)	គ្រប់ភូមិ	ក-ខ្វះទឹកនៅរដូវប្រាំង ខ-ខ្វះប្រព័ន្ធប្រឡាយ(មិនគ្រប់តាមតម្រូវការ) គ-ខ្វះខាត់ទឹកសិកម្មទាំងស្រុងនៅរដូវប្រាំង	ក.ខ.គ.១-សាងសង់ប្រព័ន្ធធារាសាស្ត្របន្ថែម
		ឃ-ខ្វះអាងស្តុកទឹកនៅរដូវប្រាំង	ឃ.១-ជួសជុលហេដ្ឋារចនាសម្ព័ន្ធធន់ធានទឹក
		ង-ខ្វះអាងស្តុកទឹកសហគមន៍	ង.១-ធ្វើអាងស្តុកទឹកឱ្យសហគមន៍
៧.ទិន្នផលស្រូវទាប	គ្រប់ភូមិ	ក-ដីអត់រៀបស្មើ	ក.១-កៀរដីឱ្យស្មើ
		ខ-ដីខ្សោះជីជាតិ គ-កណ្តុល ខ្យងក្រហម សត្វបំផ្លាញ ឃ-ខ្វះជី	ខ.គ.ឃ.១-បណ្តុះបណ្តាលការប្រើប្រាស់ជីធម្មជាតិ និងថ្នាំសម្លាប់សត្វល្អិត
		ង-ខ្វះពូជស្រូវល្អ	ង.១-ផ្តល់ពូជស្រូវដែលមានទិន្នផលខ្ពស់
		ច-ខ្វះប្រឡាយបញ្ចេញ បញ្ចូលទឹក	ច.១-ស្តារប្រឡាយនិងធ្វើទ្វារទឹក ច.២-ធ្វើទ្វារទឹក និងប្រឡាយថ្មី
		ឆ-មិនសូវថែទាំ ជ-ធ្វើស្រែតាមទម្លាប់ចាស់	ឆ.ជ.១-បណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវ
៨. បាត់បង់ព្រៃលិចទឹក	១.ភូមិចំបក់ខ្ពស់ ២.ភូមិអូររំចេក ៣. ភូមិដូនល្អ ៤. ភូមិពៃ ៥.ភូមិត្រាចជ្រុំ	ក-កាប់រានយកដីធ្វើស្រែប្រាំង	ក.១-ផ្សព្វផ្សាយច្បាប់ព្រៃលិចទឹក
		ខ-កាប់ឧសដុត	ខ.១-ដាំដើមឈើឡើងវិញ
៩. បាត់បង់ធនធានជលផល	គ្រប់ភូមិ	ក-ប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់	ក.១-ផ្សព្វផ្សាយច្បាប់ជលផល
		ខ-កំណើនអ្នកនេសាទច្រើន គ-នេសាទនៅរដូវត្រីពង	ខ.គ.១-អប់រំ និងផ្សព្វផ្សាយបម្រាមនេសាទនៅរដូវត្រីពង
		ឃ-ខ្វះជម្រកត្រីពង	ឃ.១-បង្កើនការចិញ្ចឹមត្រីតាមគ្រួសារ
		ង-ភាពក្រីក្រ (លក់ដីភូមិ ដោះបំណុល)	ង.១-រកដីថ្មីសម្រាប់សាងលំនៅឋានថ្មី

ប្រភពទិន្នន័យៈ *របាយការណ៍កម្រេត្រ-បរិស្ថាន និងក្រុមប្រឹក្សាឃុំសំព្រោជ ខែកញ្ញា ឆ្នាំ២០១៨*

ផែនទី 11៖ ផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ



ជំពូក ៣៖ ផែនការប្រើប្រាស់ដីពេលអនាគតឆ្នាំ២០១៧-២០៣២

៣.១.តម្រូវការ ស្ថានភាព និងសក្តានុពលដីជាក់ស្តែង

៣.១.១.តម្រូវការដីទៅតាមប្រភេទ

នៅពេលអនាគតរហូតដល់ឆ្នាំ២០៣២ នៅក្នុងឃុំសំព្រោជ នឹងមានការកើនឡើងចំនួនប្រជាពលរដ្ឋ ១ ២៣០នាក់ ដែលត្រូវនឹងចំនួន ២៥៤គ្រួសារ ។ ដោយសារសន្ទុះនៃកំណើនប្រជាពលរដ្ឋនេះហើយ ដែលតម្រូវឱ្យមានការគិតគូរយកចិត្តទុកដាក់ដល់ការរកដីបន្ថែមសម្រាប់លំនៅឋាន និងដីស្រែជូនដល់ប្រជាពលរដ្ឋដែលមានចំនួនកើនឡើង ដើម្បីធានាឱ្យមាននិរន្តរភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំសំព្រោជទៅថ្ងៃអនាគតបន្តពីពេលបច្ចុប្បន្ន ដូចបានរកឃើញនៅក្នុងជំពូក២ខាងលើនៃរបាយការណ៍នេះ ។ តែដោយសារទំហំផ្ទៃដីដែលត្រូវបានប្រើប្រាស់បច្ចុប្បន្នក្នុងឃុំ ពុំមានប្រែប្រួលកើនឡើងស្របគ្នាទៅនឹងកំណើនប្រជាពលរដ្ឋនាពេលអនាគត ដើម្បីដោះស្រាយបានតាមតម្រូវការដីសម្រាប់លំនៅឋាន និងដីស្រែចំការបន្ថែមនោះ គឺជាដំណោះស្រាយសមស្របដីសម្រាប់លំនៅឋានត្រូវប្រើប្រាស់ដីភូមិលំនៅឋានដែលមានស្រាប់ ពីព្រោះស្ថានភាពការតាំងលំនៅឋានបច្ចុប្បន្នមិនទាន់មានភាពចង្អៀត ដែលអាចមានលទ្ធភាពទ្រទ្រង់ដល់ការសាងសង់លំនៅឋានបន្ថែមទៀតបានសម្រាប់រយៈពេល១៥ឆ្នាំទៅមុខ ហើយម្យ៉ាងទៀតការតាំងលំនៅឋានមានលក្ខណៈប្រមូលផ្តុំវានឹងផ្តល់ភាពងាយស្រួលដល់ការផ្គត់ផ្គង់ទឹកស្អាត ភ្លើង និងសេវាសង្គមផ្សេងៗទៀតដូចជាសេវាអប់រំ សេវាសុខភាពជាដើម ។ល។

ចំពោះដីស្រែ មិនត្រឹមតែមិនបានពង្រីកបន្ថែមតាមការគិតគូរខាងលើនោះទេ តែត្រូវទទួលរងការបាត់បង់ខ្លះថែមទៀត ប្រសិនបើដីស្រែប្រាំងនៅក្នុងតំបន់៣ ដែលជាដីការពារជុំវិញបឹងទន្លេសាបមិនត្រូវបានការអនុញ្ញាតពីរាជរដ្ឋាភិបាល ឱ្យប្រជាពលរដ្ឋកាន់កាប់អាស្រ័យផល ដោយមានការស្នើសុំពីអាជ្ញាធរដែនដីទេនោះ ។ ជាដំណោះស្រាយ គឺត្រូវតែគិតគូរពិចារណាដោយធ្វើការយកចិត្តទុកដាក់ តាមរយៈការបង្កើនផលិតភាព គុណភាព និងពិពិធកម្មកសិកម្មដំណាំស្រូវ ដោយត្រូវធ្វើស្រែបង្កើនរដូវឱ្យបានពី២ទៅ៣ដងក្នុងមួយឆ្នាំ និងធ្វើស្រែតាមបែបប្រពលវប្បកម្ម ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា ។

៣.១.២.ស្ថានភាពនៃដីធ្លី និងសក្តានុពល

នៅពេលអនាគត ធនធានដីនៅក្នុងឃុំសំព្រោជនៅតែរក្សាទំហំក្រឡាផ្ទៃសរុប ២២ ៣៧៤ហិកតាដដែលដោយពុំមានការប្រែប្រួលឡើយ ហើយដីធ្លីទាំងនេះនឹងមានការប្រើប្រាស់សម្រាប់សាងសង់លំនៅឋាន (រួមទាំងហេដ្ឋារចនាសម្ព័ន្ធមួយចំនួននិងដំណាំជុំវិញលំនៅឋាន) ដីស្រែ (រួមទាំងប្រព័ន្ធធារាសាស្ត្រនឹងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន) ដីព្រៃឈើ ដីស្ទឹង បឹង អាងស្តុកទឹក និងស្រះ ដូចការប្រើប្រាស់ដីធ្លីបច្ចុប្បន្នដដែល ដោយពុំមានការប្រែប្រួលឡើយ ពីព្រោះដីធ្លីដែលបានប្រើប្រាស់ក្នុងពេលបច្ចុប្បន្ននេះបានសមស្របនិងចំសក្តា នុពលនៃដីតួចហើយ ។ ចំណែកទំហំផ្ទៃដីតំបន់ប្រើប្រាស់នីមួយៗ ដូចមានរៀបរាប់ក្នុងសេចក្តីអត្ថាធិប្បាយអំពីការបែងចែកដីតាមតម្រូវការប្រើប្រាស់ខាងក្រោមនេះ ។ ជាទូទៅធនធានដីនៅក្នុងឃុំសំព្រោជមាន សក្តានុពលខ្ពស់សមស្របទៅលើកសិកម្មដំណាំស្រូវ ដោយសារដីនៅក្នុងឃុំមានទីតាំងភូមិសាស្ត្រ អំណោយផលពីធម្មជាតិដូចបានរៀបរាប់ក្នុងជំពូកទី២ខាងលើ ។ ដូច្នេះការប្រើប្រាស់ដីនាពេលបច្ចុប្បន្ន និងការសម្រេចចិត្តប្រើប្រាស់ដីទៅថ្ងៃអនាគតនៅក្នុងឃុំដែលបានផ្តោតសំខាន់ទៅលើកសិកម្មដំណាំស្រូវជាចំបង គឺជាការប្រើប្រាស់បានត្រឹមត្រូវចំសក្តានុពលនៃដី

ហើយក៏ជាការគាប់ជួនដែលភាពអំណោយផលពីធនធានដី នៅក្នុងឃុំសមស្របទៅលើវិស័យកសិកម្មដំណាំស្រូវនេះ ក៏ស្របទៅនឹងគោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងតួនាទីវិស័យកសិកម្ម ក្នុងការបង្កើតការងារ ការធានាសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍជនបទដែលមានចែងក្នុងមុំទី១ ចតុកោណទី៤ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា ដែលជាការផ្តល់ឱកាសដ៏ល្អដល់អាចអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួនឱ្យឃុំមានការរីកចម្រើនបាន តាមរយៈការជំរុញធ្វើពិពិធកម្មកសិកម្មដំណាំស្រូវនៅលើ ផ្ទៃដីកសិកម្មដ៏ធំល្វឹងល្វើយស្ទើរតែពេញដែនដីឃុំទាំងមូល ដើម្បីបង្កើនទិន្នផលស្រូវដែលជាដំណាំដ៏មានសារៈសំខាន់សម្រាប់ជាស្បៀងផ្គត់ផ្គង់ការហូបចុកមិនអាចខ្វះបាននិងការនាំចេញទៅលក់នៅទីផ្សារ ដើម្បីបានចំណូលផ្គត់ផ្គង់តម្រូវការចាំបាច់ក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ឱ្យបានកាន់តែប្រសើរឡើង រួមទាំងចូលរួមក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិតាមរយៈសកម្មភាពធ្វើពាណិជ្ជកម្មនាំអង្ករចេញ របស់រាជរដ្ឋាភិបាលកម្ពុជា ។

ចំណែកដីដែលមានទំហំតិចតួច ដែលបានកំណត់ជាការប្រើប្រាស់ដីសម្រាប់សាងសង់លំនៅឋាននៅលើដីខ្ពស់ជាប់តាមដងផ្លូវសំខាន់ៗ ដែលមិនលិចទឹកនៅរដូវវស្សា បានផ្តល់ភាពងាយស្រួលក្នុងការធ្វើដំណើរចេញ-ចូល និងងាយស្រួលក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត សម្រាប់បម្រើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំបានប្រកបដោយផាសុកភាព ព្រមទាំងដីប្រើប្រាស់សម្រាប់ប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត គឺជាការប្រើប្រាស់បានត្រឹមត្រូវផងដែរ ។

៣.២.ការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់

៣.២.១.ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ

ជាទូទៅការកំណត់តំបន់ប្រើប្រាស់ដីបានផ្តោតសំខាន់លើមុខងារនៃការប្រើប្រាស់ដី សម្រាប់គោលបំណងផ្សេងៗដូចជា ផ្លូវ កសិកម្ម លំនៅឋាន ពាណិជ្ជកម្ម សួនកម្សាន្ត ព្រៃឈើ ។ល។ ទន្ទឹមនឹងនោះ ការប្រើប្រាស់ដីតែងតែមានការផ្លាស់ប្តូរមុខងាររបស់វា តែការផ្លាស់ប្តូរមុខងារប្រើប្រាស់ដីទាំងនេះត្រូវតែគិតគូរពិចារណាឱ្យបានហ្មត់ចត់ ដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវតាមស្ថានភាពច្បាប់ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ហើយត្រូវតែប្រាកដថា ដីដែលក្រោយពីបានប្តូរមុខងារប្រើប្រាស់ហើយនោះត្រូវតែមានតម្លៃសេដ្ឋកិច្ច ឬ ផលប្រយោជន៍ខ្ពស់ជាងមុខងារប្រើប្រាស់មុន តាមរយៈការរក្សាជំហរច្បាស់លាស់ក្នុងការបង្កើនធនធានប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពជាមួយនឹងផលប៉ះពាល់ដ៏តិចតួចបំផុតចំពោះមនុស្សជំនាន់ក្រោយ។ឧទាហរណ៍ដូចជាការផ្លាស់ប្តូរពីដីព្រៃឈើរេចរឹលទៅជាដីសម្រាប់កសិកម្ម វានឹងនាំឱ្យមានការបាត់បង់បរិមាណដីព្រៃឈើដែលផ្តល់ប្រយោជន៍ច្រើនយ៉ាងដល់សហគមន៍មូលដ្ឋាន តែត្រូវបានកើតឡើងជំនួសដោយវាលស្រែសម្រាប់ផលិតកម្មស្រូវដែលជាចំណីអាហារសម្រាប់ជីវិតរស់នៅមិនអាចខ្វះបាន ដែលទាំងនេះជាការបង្ហាញឱ្យឃើញអំពីអន្តរអំពើរវាងមុខងារប្រើប្រាស់ដីមួយ ជាមួយមុខងារប្រើប្រាស់ដីមួយផ្សេងទៀតនៅលើទីតាំងដីដដែល ។

យ៉ាងណាមិញក្នុងរយៈពេល១៥ឆ្នាំ ខាងមុខរហូតដល់ឆ្នាំ២០៣២ ការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជ ត្រូវបានធ្វើការគិតគូរយ៉ាងយកចិត្តទុកដាក់ ដើម្បីដោះស្រាយ និងឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋដូចបានរៀបរាប់ខាងលើ ជាពិសេសគឺការដោះស្រាយក្នុងការបែងចែកការប្រើប្រាស់ដីថ្មីដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋតាមគោលការណ៍របស់រាជរដ្ឋាភិបាល និងដោយឈរលើស្មារតីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការប្រើប្រាស់ដីថ្មីនៅក្នុងឃុំ ដែលជាក់ស្តែងនៅក្នុងឃុំសំព្រោជ មិនមានការប្រែប្រួលការប្រើប្រាស់ដីនោះទេ ។

តារាង 36៖ តារាងប្រើប្រាស់ដីនាពេលអនាគតឃុំសំព្រោជ

ប្រភេទការប្រើប្រាស់ដី	ផ្ទៃដីបច្ចុប្បន្ន (ហិកតា)	ផ្ទៃដី១៥ក្រោយ (ហិកតា)	បម្រែបម្រួល (ហិកតា)
ក.ដីលំនៅឋាន ភូមិ	**២៥០**	**២៥០**	0
-ដីលំនៅដ្ឋាន ភូមិ ក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប	៨០	៨០	0
-ដីលំនៅដ្ឋាន ភូមិ ក្នុងតំបន់១ជុំវិញបឹងទន្លេសាប	១៧០	១៧០	0
ខ.ដីស្រែវស្សា	**២ ៩០១,០១**	**២ ៩០១,០១**	0
-ដីស្រែវស្សាក្រៅតំបន់ជុំវិញបឹងទន្លេសាប	៥៤០,៣	៥៤០,៣	0
-ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប	២ ៣០០	២ ៣០០	0
-ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប	៦០,៧១	៦០,៧១	0
គ.ដីស្រែប្រាំង	**៤ ៨៥០**	**៤ ៨៥០**	0
-ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប	៤ ៥០០	៤ ៥០០	0
-ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប	៣៥០	៣៥០	0
ឃ.ដីស្រែប្រាំងនិងស្រែវស្សា	**១ ៩៨៧**	**១ ៩៨៧**	0
-ដីស្រែប្រាំង និងស្រែវស្សាតំបន់១ជុំវិញបឹងទន្លេសាប	៨៧,១២	៨៧,១២	0
-ដីស្រែប្រាំង និងស្រែវស្សាតំបន់២ជុំវិញបឹងទន្លេសាប	១៩០០	១៩០០	0
ង. ព្រៃគុម្ពោត	**៧,១**	**៧,១**	0
ច.ព្រៃលិចទឹក	**៩ ០១១,៤៣**	**៩ ០១១,៤៣**	**0**
ឆ.ទន្លេមានទឹកជាអចិន្ត្រៃយ៍	**២៤០**	**២៤០**	0
ជ.ស្ទឹងមានទឹកតាមរដូវ	**៥,០១**	**៥,០១**	0
ឈ.ស្រះ	**១៩,៨៨**	**១៩,៨៨**	0
ញ.បឹង	**១ ០០២,៣២**	**១៩២,២១**	**-៨១០,១១**
-សហគមន៍នេសាទព្រែកត្រនុងជ្រីង	0	៨១០,១១	៨១០,១១
ដ. អាងស្តុកទឹក	**២ ១០០**	**២ ១០០**	0
ផ្ទៃដីឃុំសរុប	**២២ ៣៧៤**	**២២ ៣៧៤**	**0**

តារាង 37៖ តារាងផែនការផ្នែកហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត

ប្រភេទហេដ្ឋារចនាសម្ព័ន្ធ	ប្រវែងផ្លូវឆ្នាំ២០១៧(ម៉ែត្រ)	ប្រវែងផ្លូវឆ្នាំ២០៣២(ម៉ែត្រ)	បម្រែបម្រួល(ម៉ែត្រ)
ផ្លូវក្រាលកៅស៊ូ	៤ ៣៣៦,៩៤	៤ ៣៣៦,៩៤	00
ផ្លូវក្រាលគ្រួសក្រហម	១៨ ៤៥៨,១៦	១៨ ៤៥៨,១៦	00
ផ្លូវលំដីស/ផ្លូវរទេះ	៨៨ ២១២,៣៦	៨៨ ២១២,៣៦	00
ប្រឡាយមេ	៧ ៦៧៤,២០	៧ ៦៧៤,២០	00
ប្រឡាយរង	៤ ០៨៤,៧៣	៤ ០៨៤,៧៣	00

ប្រឡាយតូច	៤១ ០១៨,១៨	៤១ ០១៨,១៨	០០

តារាង 38៖ តារាងផែនការផ្នែកសេវាកម្មនាពេលអនាគត

ហេដ្ឋារចនាសម្ព័ន្ធ	ចំនួនក្នុងឆ្នាំ២០១៧	ចំនួនសម្រាប់១៥ឆ្នាំក្រោយ	បម្រែបម្រួល
សាលាមតេយ្យ	០៣អគារ/៤បន្ទប់	០៦អគារ/២៨បន្ទប់	០៣អគារ/២២បន្ទប់
សាលាបឋមសិក្សា	០៨អគារ/៥៧បន្ទប់	០៧អគារ/៤៤បន្ទប់	-១អគារ/-១៣បន្ទប់
សាលាអនុវិទ្យាល័យ	០១អគារ/១៦បន្ទប់	០២អគារ២៥បន្ទប់	០១អគារ/៩បន្ទប់
សាលាវិទ្យាល័យ	០០អគារ/០០បន្ទប់	០២អគារ/២៥បន្ទប់	០២អគារ/២៥បន្ទប់
មណ្ឌលសុខភាព	០១ អគារ	០១ អគារ	០០ អគារ

៣.២.២.ផែនទីប្រើប្រាស់ដីអនាគត

ការកំណត់ការប្រើប្រាស់ដីនាពេលអនាគតនៅក្នុងឃុំ គឺជាការសម្រេចចិត្តមួយដ៏ត្រឹមត្រូវបំផុត ដោយពឹងផ្អែកទាំងស្រុងទៅលើការវិភាគដីដ៏សមស្របមួយ តាមរយៈការវាយតម្លៃបែបសាមញ្ញទៅលើធនធានដី រយៈកម្ពស់ ទីជម្រាល ធនធានទឹក ការកាន់កាប់ដី និងសក្តានុពលនៃការប្រើប្រាស់ដីនៅក្នុងឃុំនេះនាពេលបច្ចុប្បន្ន ដោយយកផែនទីប្រើប្រាស់ដីធ្លីបច្ចុប្បន្នធ្វើជាមូលដ្ឋានក្នុងការគិតពិចារណា ដូចមានរំលេចឱ្យឃើញនៅក្នុងតារាងទី៣៦ខាងលើនេះ ដោយមានភ្ជាប់នូវផែនទីប្រើប្រាស់ដីនាពេលអនាគតមួយដូចខាងក្រោម ដែលសមស្របអាចទទួលយកបាន និងអាចប្រើប្រាស់មានប្រសិទ្ធិភាព តាមរយៈការបង្ហាញយ៉ាងពិស្តារពីជម្រើសដ៏ល្អសម្រាប់ការប្រើប្រាស់ដីនាពេលអនាគតរបស់ឃុំនេះ។ ទន្ទឹមនឹងនោះផែនទីប្រើប្រាស់ដីនាពេលអនាគតខាងក្រោម ក៏មានការអត្ថាធិប្បាយលម្អិតទៅលើតំបន់ប្រើប្រាស់ដីនីមួយៗដែលបានកំណត់នៅលើផែនទីនេះផងដែរ ។

ផែនទី 12៖ ផែនទីប្រើប្រាស់ដីពេលអនាគតឃុំសំព្រោជ



៣.២.៣.សេចក្តីអត្ថាធិប្បាយអំពីការប្រើប្រាស់ដីនាពេលអនាគត

ផ្អែកតាមផែនទីប្រើប្រាស់ដីអនាគតខាងលើ បានបង្ហាញឱ្យឃើញពីប្រភេទនៃការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជ ដូចខាងក្រោម៖

ក. ដីលំនៅឋាន ភូមិ៖

ដីលំនៅឋាន ភូមិ គឺជាដីត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានមានលាយសួនដំណាំ និងឈើហូបផ្លែ ។ នៅក្នុងឃុំសំព្រោជ ដីលំនៅឋាន ភូមិ មាននៅតាមតំបន់ប្រមូលផ្តុំភូមិគឺ តំបន់ទី១ ស្ថិតនៅខាងជើងផ្លូវជាតិលេខ៦ ដែលមានភូមិស្លាក់ក្រាញ់ ភូមិប្រជិត ភូមិមឈាយ និងភូមិអំពិល ជាដីលំនៅឋាន ភូមិស្ថិតក្រៅតំបន់ការពារ ជុំវិញបឹងទន្លេសាប និងតំបន់ទី២ ស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៦ ជាដីលំនៅឋាន ភូមិ ស្ថិតក្នុងតំបន់១ជុំវិញបឹងទន្លេសាប ក្នុងនោះ មានភូមិអូររំចេក ភូមិត្នោតគម ភូមិក្រសាំងជ្រុំជើង ភូមិល្វា ភូមិអំពៅព្រៃ ភូមិសំព្រោជ ភូមិពត្លក ភូមិដូនល្អ ភូមិពៃ និងភូមិចំបក់ខ្ពស់ ។ ដីលំនៅឋានភូមិ គឺជាដីដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ(ដីកម្មសិទ្ធិឯកជន) មានទំហំផ្ទៃដីសរុប ២៥០ហិកតា ក្នុងនោះដីលំនៅឋាន ភូមិក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប មានទំហំ៨០ ហិកតា និងដីលំនៅឋាន ភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានទំហំ១៧០ហិកតា ដែលបច្ចុប្បន្នដីនេះត្រូវបានប្រើប្រាស់សម្រាប់ដីលំនៅឋានភូមិដែរ ដោយពុំមានការពង្រីកបន្ថែមសម្រាប់ដោះស្រាយទៅនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២នោះឡើយ ដោយសារដីលំនៅឋានភូមិនៅមានភាពទូលាយអាចដោះស្រាយសម្រាប់សាងសង់លំនៅឋានរហូតដល់ឆ្នាំ២០៣២បាន ។ ដីលំនៅឋានភូមិជាប្រភេទដីល្បាយខ្សាច់ពណ៌ក្រហម និងក្រម៉ៅ(ដីប្រទះឡាង បាកាន និងមានស្ថានភាពជាដីខ្ពស់មិនលិចទឹកស្មើនឹងកម្ពស់ផ្លូវសមស្របសម្រាប់សំណង់លំនៅឋាន ។ ដីដែលបានកំណត់ជាដីភូមិនេះពឹងផ្អែកលើប្រភពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និងស្រោចស្រពដំណាំរួមផ្សំជុំវិញលំនៅឋាន បានមកពីទឹកភ្លៀង អណ្តូងស្នប់ ត្រពាំង ស្រះ ហើយត្រូវនាំទឹកមកប្រើប្រាស់ដោយម៉ូទ័របូម និងស្នប់សប់ដៃ។ នាពេលអនាគតទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីសម្រាប់សាងសង់លំនៅឋានដដែល ដោយសារទីតាំងដីនេះមានស្ថានភាពជាដីខ្ពស់មិនលិចទឹកនៅរដូវវស្សា និងនៅជាប់ផ្លូវសំខាន់ៗក្នុងឃុំងាយស្រួលក្នុងការចេញចូលប្រកបរបររកស៊ីរបស់ប្រជាពលរដ្ឋ ដែលសមស្របសម្រាប់ការតាំងលំនៅឋាន ជាជម្រកដ៏កក់ក្តៅសម្រាប់ជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ។ ដោយបច្ចុប្បន្ននេះដីលំនៅឋាន ភូមិ នៅមានភាពទូលាយ ដែលត្រូវបានប្រើប្រាស់ទំហំដីប្រមាណ ០,០៩ហិកតា ក្នុងមួយគ្រួសារ ដែលអាចធ្វើការដោះស្រាយសម្រាប់ការសាងសង់លំនៅឋានរហូតដល់ឆ្នាំ២០៣២បាន ដោយនឹងត្រូវប្រើប្រាស់ទំហំដីថយចុះតិចតួចនៅសល់ប្រមាណ ០,០៨ហិកតា ក្នុងមួយគ្រួសារ ។

ខ. ដីស្រែវស្សា៖

ដីស្រែវស្សាក្នុងឃុំសំព្រោជ នៅពេលអនាគត ភាគច្រើនលើសលប់ ស្ថិតនៅប៉ែកខាងលិចផ្លូវជាតិលេខ៦ និងមានតិចតួចនៅប៉ែកខាងកើតផ្លូវជាតិលេខ៦ និងមានផ្ទៃដីសរុបចំនួន ២ ៩០១ ហិកតា ដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាដីស្រែវស្សានិងដីកប់ខ្មោច រួមទាំងដីទួលបុរាណចំនួន១៤ទួលផងដែរ ដោយពុំមានការពង្រីកបន្ថែមសម្រាប់ការដោះស្រាយទៅនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២នោះឡើយ ។ ដីស្រែវស្សាទាំងនេះ ជាតំបន់ទំនាបមធ្យម មានដីជាប្រភេទដីល្បាយខ្សាច់ពណ៌ក្រហម និងក្រម៉ៅ(ដីប្រទះឡាង បាកាន) ដោយទទួលការស្រោចស្រពពីទឹកភ្លៀង ទឹកស្ទឹង ប្រឡាយ៣០កញ្ញា បឹង និងអាងស្តុកទឹក ។ ដីស្រែវស្សាទាំងនេះ មានមួយផ្នែកនៅក្បែរៗជាប់នឹងដីលំនៅឋាន ភូមិ ក្រោយពីច្រូតកាត់ស្រូវរួច ប្រជាពលរដ្ឋក្នុងសង្កាត់តែងនាំគ្នាដាំដំណាំរួមផ្សំ

ថែមទៀតរួមមានដូចជា ពោត សណ្តែក ឪឡឹក និងបន្លែគ្រប់មុខជាដើម ។ល។ នាពេលអនាគតទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីស្រែ ដីកប់ខ្មោច និងដីទួលបុរាណដូចបច្ចុប្បន្នដដែល ដោយសារទីតាំងដីនេះមានស្ថានភាពជាដីទាបលិចទឹកនៅរដូវវស្សាសមស្របសម្រាប់ដំណាំស្រូវផ្តល់ផលិតផលផ្គត់ផ្គង់ដល់ការបរិភោគ សម្រាប់ជីវិតរស់របស់មនុស្ស និងនៅសល់លក់ទៅទីផ្សារក្នុងនិងក្រៅស្រុកដើម្បីបង្កើនប្រាក់ចំណូលជាតិ និងគ្រួសារ និងពិធីសាសនាផ្សេងៗនៅក្នុងឃុំ។ដីទួលបុរាណដ្ឋាន ដីស្រែវស្សាក្នុងតំបន់២ គឺជាដីសាធារណៈរបស់រដ្ឋ លើកលែងតែដីស្រែវស្សាក្នុងតំបន់១និងក្រៅតំបន់ចេញ ជាដីកម្មសិទ្ធិឯកជន ដែលកាន់កាប់និងគ្រប់គ្រងដោយប្រជាពលរដ្ឋ ។ ដីស្រែវស្សា នៅពេលអនាគតមានទីតាំងស្ថិតនៅបីតំបន់ផ្សេងគ្នាដូចខាងក្រោម៖

-ដីស្រែវស្សាក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប

ដីស្រែវស្សាក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប មានផ្ទៃដីចំនួន ៥៤០,០១ ហិកតា ក្នុងនោះមានដីកប់ខ្មោចចំនួន២កន្លែង មានទំហំ១,០១ហិកតា ស្ថិតនៅខាងកើតផ្លូវជាតិលេខ៦ ។ ដីស្រែវស្សាក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប ជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ ។

-ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប

ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានផ្ទៃដីចំនួន ២ ៣០០ហិកតា ស្ថិតនៅខាងលិចផ្លូវជាតិលេខ៦ ។ ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាបជាដីកម្មសិទ្ធិឯកជនត្រូវបានកាន់កាប់និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ លើកលែងតែដីទួលបុរាណ ជាដីកម្មសិទ្ធិរបស់រដ្ឋ ។

-ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប

ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានផ្ទៃដីចំនួន ៦០,៧១ហិកតា ដែលស្ថិតនៅខាងលិចផ្លូវជាតិលេខ៦បន្តជាប់ពីដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប ។ ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងលក់ដូរបានឡើយ ។

គ. ដីស្រែប្រាំង៖

ដីស្រែប្រាំងនៅក្នុងឃុំសំព្រោជ នាពេលអនាគត ស្ថិតនៅចុងភាគខាងត្បូងនៃឃុំ ដែលមានផ្ទៃដី សរុបចំនួន ៤ ៨៥០ ហិកតា ដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាដីស្រែប្រាំង ដោយពុំមានការពង្រីកបន្ថែមសម្រាប់ការដោះស្រាយទៅនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២នោះឡើយ។ ដីស្រែប្រាំងទាំងនេះ ជាតំបន់ទំនាបទាបមានប្រភេទដីកណ្តៀងពណ៌ខ្មៅ ក្រហមប្រផេះ(បាកាន ក្បាលពោធិ៍ ក្រគរ) និងពឹងផ្អែកលើប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ស្ទឹង បឹង និងអាងស្តុកទឹក ហើយត្រូវនាំទឹកមកប្រើប្រាស់ដោយម៉ូទ័របូម។ នាពេលអនាគតទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីស្រែប្រាំងដដែល ដោយសារតែទីតាំងដីនេះមានស្ថានភាពជាដីទាបលិចទឹកខ្លាំងនៅរដូវវស្សាមិនអាចធ្វើស្រែវស្សាបានសមស្របសម្រាប់ដំណាំស្រូវប្រាំងនៅពេលទឹកស្រកចុះវិញសម្រាប់ផ្គត់ផ្គង់ ការហូបចុកសម្រាប់ជីវិតរស់នៅរបស់មនុស្សនិងនៅសល់លក់ទៅទីផ្សារក្នុងនិងក្រៅប្រទេសបានចំណូលបង្កើនប្រាក់ចំណូលជាតិនិងគ្រួសារ។ ដីស្រែប្រាំងនៅពេលអនាគតមានទីតាំងស្ថិតនៅតាមបីតំបន់ផ្សេងគ្នាដូចខាងក្រោម៖

-ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប

ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានទំហំផ្ទៃដីសរុបចំនួន ៤ ៥០០ ហិកតា ស្ថិតនៅខាងត្បូងនៃឃុំ ដែលបន្តជាប់ពីដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប ។ ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងលក់ដូរបានឡើយ ។

-ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប

ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាបមានទំហំផ្ទៃដីចំនួន ៣៥០ហិកតា ស្ថិតនៅភាគខាងត្បូងសង នៃឃុំ បន្តជាប់ពីដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប ។ ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅក្នុងតំបន់ដែនព្រៃលិចទឹក ដែលហាមការកាប់រានដី ការដុតបំផ្លាញ ការរំលោភកាន់កាប់ដីព្រៃលិចទឹក នៅជុំវិញបឹងទន្លេសាប និងការសាងសង់សំណង់ថ្មីៗគ្រប់ប្រភេទ ។ នាពេលអនាគត ក្នុងករណីដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាបទាំងនេះ មិនមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ឱ្យផ្ទៀលចេញពីតំបន់ការពារព្រៃលិចទឹកតាមកាស្នើសុំរបស់អាជ្ញាធរដែនដីពាក់ព័ន្ធ ដោយផ្អែកលើឯកសារលិខិត បទដ្ឋានគតិយុត្តិ និងបទបញ្ជានានារបស់រាជរដ្ឋាភិបាលទេនោះ គឺដីស្រែប្រាំងទាំងនេះនឹងនៅតែកំណត់ការប្រើប្រាស់ជាដីព្រៃលិចទឹកជុំវិញបឹងទន្លេសាបដែលត្រូវការពារដដែល ។ តែទោះបីមានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យផ្ទៀលដីទាំងនេះជូនសម្រាប់ប្រើប្រាស់ជាដីស្រែក៏ដោយ ក៏ដីស្រែទាំងនេះមិនមែនជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋដែរ គឺពួកគាត់គ្រាន់តែអាចមានសិទ្ធិកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ ។

ឃ. ដីស្រែប្រាំង និងស្រែវស្សាៈ

ដីស្រែប្រាំងស្ថិតនៅកណ្តាលឃុំ ចន្លោះតំបន់ស្រែវស្សា និងស្រែប្រាំង ជាតំបន់វាលទំនាបទាបជម្រាលស្មើ ប្រភេទដីកណ្តេងពណ៌ខ្មៅ ក្រហមប្រផេះ(បាកាន.ក្បាលពោធិ៍ ក្រគរ) ត្រូវបានប្រើប្រាស់សម្រាប់ដំណាំស្រូវប្រាំង និងវស្សា ដោយពឹងផ្អែកលើទឹកភ្លៀងទទួលការស្រោចស្រពដោយហើយស្រោចស្រពដោយទឹកភ្លៀង ទឹកប្រឡាយ៣០កញ្ញា បឹង ត្រពាំង និងអាងទឹក ដីស្រែវស្សាមានទំហំផ្ទៃដី ២ ៩០១,៥៣ហិកតា ត្រូវបានកាន់កាប់ដោយប្រពលរដ្ឋ (ជាដីសាធារណៈរបស់រដ្ឋ) ពួកគាត់អាចប្រើប្រាស់ និងអាស្រ័យផលបាន ប៉ុន្តែមិនមានសិទ្ធិចាត់ចែងឬលក់ដូរនោះទេ ។ នាពេលអនាគតទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីស្រែប្រាំង និងស្រែវស្សាដដែល ដោយសារទីតាំងដីនេះមានស្ថានភាពជាដីទាបលិចទឹករយៈពេលខ្លីនៅរដូវវស្សា សមស្របសម្រាប់ដំណាំស្រូវសម្រាប់ផ្គត់ផ្គង់ការហូបចុកសម្រាប់ជិវិតរស់របស់មនុស្ស និងនៅសល់លក់ទៅទីផ្សារក្នុងនិងក្រៅប្រទេសបានចំណូលបង្កើនប្រាក់ចំណូលជាតិ និងគ្រួសារ ។

ដីស្រែប្រាំងនិងស្រែវស្សាក្នុងឃុំសំព្រោជ នៅពេលអនាគត ស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៦ និងមានផ្ទៃដីសរុបចំនួន ១ ៩៨៧ ហិកតា ដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាដីស្រែប្រាំងនិងស្រែវស្សាដោយពុំមានការពង្រីកបន្ថែមសម្រាប់ការដោះស្រាយទៅនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២នោះឡើយ ដោយឡែកដីទួលបុរាណចំនួន២កន្លែង ក៏មិនមានការពង្រីកបន្ថែមដែរ ។ ដីស្រែប្រាំងនិងស្រែវស្សាទាំងនេះ ជាតំបន់ទំនាបទាបរៀងស្មើ ជាប្រភេទដីកណ្តេងពណ៌ខ្មៅ ក្រហមប្រផេះ(បាកាន ក្បាលពោធិ៍ ក្រគរ) និងពឹងផ្អែកលើប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ទឹកស្ទឹង បឹង ស្រះ និងអាង ហើយត្រូវនាំទឹកមកប្រើប្រាស់ដោយម៉ូទ័របូម និងម៉ាស៊ីនបូមទឹក ។ នាពេលអនាគត ទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីស្រែនិងដីទួលបុរាណដូចបច្ចុប្បន្នដដែល ដោយសារទីតាំងដីនេះមានស្ថានភាពជាដីទំនាបទាបលិចរៀងរាបស្មើ សមស្របសម្រាប់ដំណាំស្រូវផ្តល់ផលិតផលផ្គត់ផ្គង់ដល់ការបរិភោគសម្រាប់ជិវិតរស់របស់មនុស្ស និងនៅសល់លក់ទៅទីផ្សារក្នុងនិងក្រៅស្រុកដើម្បីបង្កើនប្រាក់ចំណូលជាតិ និងគ្រួសារ និងការធ្វើពិធីសាសនាផ្សេងៗនៅលើទួលបុរាណទាំងនោះ។ ដីស្រែប្រាំងនិងស្រែវស្សានៅពេលអនាគតមានទីតាំងស្ថិតនៅតាមពីរតំបន់ផ្សេងគ្នាដូចខាងក្រោមៈ

-ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប

ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានផ្ទៃដីចំនួន ៨៧,១២ ហិកតា ស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៦ ។ ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប ជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់

កាប់និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ ។

-ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប

ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានផ្ទៃដីចំនួន១ ៩០០ហិកតា ស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៦បន្តជាប់ពីដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប ។ ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងលក់ដូរបានឡើយ ។

ង. ព្រៃពុម្ពោតគុ

ដីព្រៃគុម្ពោត គឺជាដីទួលមានទំហំតូចៗដែលជាទួលបុរាណ មានខ្លះជាព្រៃនៅតាមក្បាលដីស្រែ ដែលបច្ចុប្បន្នត្រូវបាននិងកំពុងប្រើប្រាស់សម្រាប់ដីព្រៃគម្ពោត ដើម្បីទុកជាកន្លែងបន់ស្រន់ និងផ្តល់ស្មៅ និងស្លឹកឈើចំណីសត្វ និងជាកន្លែងផ្តល់ឧសដុតចម្អិនអាហារ ដែលមានសំបូរភាគច្រើនទៅដោយដើមខ្លុង ត្បែងនិងដើមឈើមួយចំនួនទៀត។ ដីព្រៃគុម្ពោតដែលមានដីទួលបុរាណចំនួន១៤ទួល គឺជាដីសាធារណៈរបស់រដ្ឋ និងក្រៅពីដីនេះគឺជាដីដែលកាន់កាប់ដោយប្រជាពលរដ្ឋ(កម្មសិទ្ធិឯកជន) ព្រៃគុម្ពោតមានទំហំផ្ទៃដីចំនួន៧,១ហិកតា ដីតំបន់នេះមាននៅលើទីតាំងដីស្ថិតនៅក្នុងតំបន់ស្រែវស្សាតំបន់១ជុំវិញបឹងទន្លេសាប ។ នាពេលអនាគតទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីព្រៃគុម្ពោតដដែល ដោយសារប្រភេទដីនេះមានទំហំតូចៗនៅរាយប៉ាយដាច់ៗពីគ្នាតាមក្បាលដីស្រែមិនអាចប្រើប្រាស់សម្រាប់ការសាងសង់ ឬចំការដំណាំបាន ។ ដីព្រៃគម្ពោតនេះនៅពេលអនាគតនឹងត្រូវដាំដើមឈើបន្ថែមឱ្យមានពណ៌បៃតង ដើម្បីផ្តល់ឈើសម្រាប់ឱសដុត និងប្រើប្រាស់ផ្សេងៗ ធ្វើឱ្យដីស្រែនៅក្នុងតំបន់នោះមានជីជាតិ ជួយផ្តល់ឧស្ម័នអុកស៊ីសែនដល់មនុស្ស សត្វ និងស្រូបយកឧស្ម័នកាបូនិក ជាជម្រកសត្វព្រៃ ផ្តល់ខ្យល់អាកាសបរិសុទ្ធ ជួយទប់ទល់ខ្យល់ព្យុះនិងទឹកជំនន់ ជួយទាក់ទាញទឹកភ្លៀង ជួយរក្សាលំនឹងអាកាសធាតុ។ល។

ច. ព្រៃលិចទឹក

នៅក្នុងឃុំសំព្រោជ មានតំបន់ព្រៃលិចទឹកមួយកន្លែងស្ថិតនៅភាគខាងត្បូងឆៀងខាងលិចដែលមានផ្ទៃដីទំហំ ៩ ០១១,៤៣ហិកតា ជាព្រៃដែលមាននៅតាមទំនាបលិចទឹកទ មានដើមរាំង ដើមចាក ដើមតាអោន ដើមស្នាច់ជាដើម ហើយជាជម្រកត្រីយ៉ាងសំខាន់ និងមានប្រភេទដីជាដីកណ្តេងខ្មៅលាយល្បាប់ (ដីក្បាលពោធិ.ដីក្រគរ.ដីបាកាន) ត្រូវបានប្រើប្រាស់សម្រាប់ព្រៃលិចទឹក ដែលទទួលបានការស្រោចស្រពដោយទឹកភ្លៀង និងទឹកទន្លេសាប ព្រៃលិចទឹកនេះ ជាដីសាធារណៈរបស់រដ្ឋ ។ នាពេលអនាគតទីតាំងដីនេះនឹងត្រូវប្រែក្លាយទៅជាតំបន់ទេសចរណ៍ធម្មជាតិដែលផ្អែកតាមលក្ខណៈដើមទាំងស្រុងនៃទេសភាពព្រៃលិចទឹក ។

ឆ. ទន្លេមានទឹកជាអចិន្ត្រៃយ៍

បឹងទន្លេសាប នៅក្នុងឃុំសំព្រោជ មានហូរកាត់នៅភាគខាងត្បូង ឆៀងខាងលិចត្រង់ព្រំប្រទល់ឃុំ ដែលមានផ្ទៃដីទំហំ ២៤០ហិកតា នៅពេលរដូវវស្សាបឹងទន្លេសាបបាននាំទឹកជំនន់ធ្វើឱ្យលិចតំបន់ខាងត្បូងនៃឃុំសំព្រោជមួយភាគធំ ហើយបឹងទន្លេសាបមានទឹកនៅគ្រប់រដូវសម្រាប់ការប្រើប្រាស់ និងស្រោចស្រពផ្សេងៗ ។ នាពេលអនាគតដីទន្លេនេះនឹងនៅតែជាប្រភពទឹកស្រោចស្រព និង ប្រើប្រាស់ច្រើនយ៉ាងក្នុងជីវភាពប្រចាំថ្ងៃរបស់

ប្រជាពលរដ្ឋដដែល ព្រមទាំងជាប្រភពធនធានជលផលសម្រាប់ជាអាហារផ្គត់ផ្គង់ប្រូតេអ៊ីនជាប្រយោជន៍យ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ។

ជ. ស្ទឹងមានទឹកតាមរដូវ

ឃុំសំព្រោជ មានស្ទឹងចំនួន១ខ្សែ មានផ្ទៃដីទំហំ ៥,០១ហិកតា ដែលហូរកាត់ឃុំនៅភាគខាងជើងត្រង់ព្រំប្រទល់ឃុំ ហើយមានទឹកតែនៅរដូវវស្សា និងរដូវប្រាំងវិញមានទឹកតិចតួចឬអត់ មិនអាចផ្គត់ផ្គង់សម្រាប់ការស្រោចស្រពបានទេ ស្ទឹងនេះជាដីសាធារណៈរបស់រដ្ឋ ។ នាពេលអនាគតដីស្ទឹងនេះនឹងនៅតែជាប្រភពទឹកស្រោចស្រព និង ប្រើប្រាស់ផ្សេងៗដ៏សំខាន់ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅក្នុងឃុំដដែល ។

ឈ. ស្រះទឹក

នៅក្នុងឃុំសំព្រោជ មានស្រះទឹកជាច្រើនកន្លែងមានផ្ទៃដីទំហំសរុប ១៩,៨៨ហិកតា ដែលស្ថិតនៅដីលំនៅឋានភូមិមួយចំនួន និងតំបន់ស្រែប្រាំង និងស្រែវស្សាមួយចំនួន ដីស្រះទាំងនេះមួយចំនួនជាស្រះសហគមន៍ និងមួយចំនួនជាស្រះឯកជនដដែល ។ នាពេលអនាគតស្រះទឹកនេះនឹងនៅតែជាប្រភពទឹកស្រោចស្រព និង ប្រើប្រាស់ច្រើនយ៉ាងក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល ព្រមទាំងជាប្រភពធនធានជលផលសម្រាប់ជាអាហារផ្គត់ផ្គង់ប្រូតេអ៊ីនជាប្រយោជន៍យ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ។

ញ. បឹង

ឃុំសំព្រោជ សម្បូរទៅដោយបឹងជាច្រើន ដែលភាគច្រើនមាននៅតំបន់ស្រែប្រាំង និងតំបន់ព្រៃលិចទឹក ដែលមានផ្ទៃបឹងសរុបចំនួន ១ ០០២,៣២ហ.ត ត្រូវបានប្រើប្រាស់ជាប្រភពទឹកស្រោចស្រព និងមានសំបូរទៅដោយធនធានជលផល ដែលជាដីសាធារណៈរបស់រដ្ឋ ។ នាពេលអនាគតដីបឹងនេះនឹងត្រូវរក្សាជាប្រភពទឹកសម្រាប់ការស្រោចស្រព និងប្រើប្រាស់ច្រើនយ៉ាងនៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល ព្រមទាំងជាប្រភពធនធានជលផលសម្រាប់ជាអាហារផ្គត់ផ្គង់ប្រូតេអ៊ីនជាប្រយោជន៍យ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ និងរៀបចំជាតំបន់សហគមន៍ព្រៃកត្រនុងជ្រើង ដែលមានផ្ទៃដីទំហំ ៨១០,១១ហិកតា ដើម្បីអភិរក្សពូជត្រី និងធនធានផលនៅក្នុងឃុំ ។

ដ. អាងស្តុកទឹក

ឃុំសំព្រោជ មានអាងស្តុកទឹកជាច្រើនកន្លែង ដែលមានអាងចំនួន៨ជាអាងសហគមន៍ និងផ្សេងទៀតជាអាងរបស់ឯកជន មានផ្ទៃដីសរុបទាំងអស់មានទំហំ ២ ១០០ហិកតា ស្ថិតនៅតំបន់ស្រែប្រាំង និងស្រែវស្សា និងតំបន់ស្រែប្រាំង អាងទាំងនោះត្រូវបានប្រជាពលរដ្ឋលើកជាទំនប់ព័ទ្ធជុំវិញស្រែរបស់ពួកគាត់ សម្រាប់ស្តុកទឹកនៅពេលដែលទឹកបឹងទន្លេសាបជនលិចទឹកតំបន់ទាំងនោះ ក្រោយពេលទឹកបឹងទន្លេសាបស្រកទៅវិញ ប្រជាពលរដ្ឋអាចប្រើប្រាស់ទឹកអាងទាំងនោះសម្រាប់ស្រោចស្រពដំណាំស្រូវប្រាំងបាន ។ នាពេលអនាគតដីអាងទាំងនេះនឹងនៅតែជាប្រភពទឹកស្រោចស្រព និង ប្រើប្រាស់ច្រើនយ៉ាងនៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល ព្រមទាំងជាប្រភពធនធានជលផលសម្រាប់ជាអាហារផ្គត់ផ្គង់ប្រូតេអ៊ីនជាប្រយោជន៍យ៉ាងសំខាន់ក្នុងជិវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ។

៣.៣.ដំណោះស្រាយផ្សេងៗ ក្នុងករណីខ្វះខាតដីធ្លី

ជាការពិតក្នុងបច្ចុប្បន្នយើងបានរកឃើញនៅក្នុងឃុំសំព្រោជ មានប្រជាពលរដ្ឋក្រីក្រខ្វះខាតដីលំនៅឋានចំនួន៥១គ្រួសារ និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារពិតប្រាកដចំនួន ៤៣១គ្រួសារ ដូចបានរកឃើញនៅក្នុងជំពូកទី១នៃរបាយការណ៍នេះ ដែលបច្ចុប្បន្នមានមួយចំនួនកំពុងរស់នៅលើចិញ្ចើមផ្លូវ ស្ទឹង លើដីចំណីប្រឡាយ និងមួយចំនួនទៀតរស់នៅក្នុងខ្ទមលើដីរបស់អ្នកដទៃ ដែលពួកគាត់ត្រូវស៊ីឈ្នួលឱ្យគេដើម្បីចិញ្ចឹមជីវិត ។ ដូច្នេះដើម្បីដោះស្រាយដីសម្រាប់សាងសង់លំនៅឋាន និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ដែលអាចផ្តល់ឱកាសឱ្យពួកគាត់មានជម្រករស់នៅសមរម្យ និងបង្កើតឱកាសការងារ ដើម្បីទទួលបានប្រាក់ចំណូលជូនពួកគាត់បាន អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ត្រូវខិតខំដោះស្រាយតាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ចនៅថ្នាក់ក្រោមជាតិ ដែលត្រូវផ្តួចផ្តើមឡើងដោយក្រុមប្រឹក្សាឃុំសំព្រោជ។ ដីធ្លីដែលត្រូវដោះស្រាយជូនពួកគាត់ដូចបានធ្វើការវិភាគដោះស្រាយនៅក្នុងជំពូកទី២ ត្រង់ចំណុច ២.១.៣ខាងលើគឺ ដីសម្រាប់លំនៅឋានមានទំហំ ១២,៧៥ហិកតា និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារមានទំហំ ៨២៦ហិកតា ។

៣.៤. កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

និរន្តរភាពនៃការប្រើប្រាស់ដី គឺជាការធានាឱ្យបាននូវគោលដៅ និងអត្ថប្រយោជន៍នៃការប្រើប្រាស់ដីទាំងនោះ ហើយការធានាទាំងអស់នេះ ត្រូវតែកើតមានឡើងជាបន្តបន្ទាប់ជារៀងរហូត ដោយពុំមានឈប់ឈរ ។ និរន្តរភាព គឺជាចំណុចស្នូលសម្រាប់ការប្រើប្រាស់ដីនៅគ្រប់តំបន់គោលដៅទាំងអស់តាមរយៈការកំណត់កត្តាចាំបាច់នានា សម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធភាព និងធានាឱ្យមាននិរន្តរភាព ។

៣.៤.១.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍន៍ សេដ្ឋកិច្ច សង្គម ព្រមទាំងថែរក្សាការពារបរិស្ថាន និងធនធានធម្មជាតិប្រកបដោយចីរភាព ។ ដោយធាធានបានការផ្គត់ផ្គង់សេចក្តីត្រូវការ និងការទទួលខុសត្រូវចំពោះផលប្រយោជន៍របស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ន និងបន្តដល់កូនចៅរបស់ពួកគាត់ទៅជំនាន់ក្រោយទៀត ត្រូវតែយកចិត្តទុកដាក់ដល់ការគ្រប់គ្រងទៅលើការប្រើប្រាស់សេវាកម្ម លើវិស័យទាំងអស់នៅក្នុងឃុំដែលបានកំណត់រួច តាមរយៈការខិតខំប្រឹងប្រែងអនុវត្តឱ្យសម្រេចបានទៅលើកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

ក. ការគ្រប់គ្រងប្រព័ន្ធកសិកម្ម

បើពិនិត្យទៅលើលក្ខណៈភូមិសាស្ត្រ និងសក្តានុពលនៃធនធានដែលមាននៅក្នុងឃុំសំព្រោជ ដែលក្រុមការងារបានធ្វើការសិក្សាស្រាវជ្រាវរកឃើញ បានកំណត់ច្បាស់ថា ឃុំនេះមានគោលដៅអភិវឌ្ឍន៍ទៅថ្ងៃអនាគត ពឹងផ្អែកទៅលើវិស័យកសិកម្មជាចម្បង ដែលក្នុងនោះបានផ្តោតសំខាន់ទៅលើដំណាំស្រូវ ។ ដូចនេះ ឃុំសំព្រោជនឹងមានតួនាទីសំខាន់មួយក្នុងការធ្វើឱ្យសម្រេចបាននូវគោលនយោបាយជំរុញផលិតកម្មស្រូវ និងនាំចេញអង្ករបស់រាជរដ្ឋាភិបាល ដែលត្រូវចាំបាច់ទាមទារឱ្យមានការគ្រប់គ្រងប្រព័ន្ធកសិកម្មក្នុងសង្កាត់ឱ្យបានរឹងមាំ និងមាននិរន្តរភាពទៅថ្ងៃអនាគត ដោយត្រូវយកចិត្តទុកដាក់ជំរុញផលិតកម្មស្រូវ ដើម្បីបង្កើនទិន្នផលស្រូវឱ្យបានខ្ពស់អស់សក្តានុពល អាចមានលទ្ធភាពនាំស្រូវចេញបានច្រើនសល់ពីការហូបចុកឆ្លើយតបទៅនឹងកំណើនប្រជា-ពលរដ្ឋ ។

ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ឃុំដូចខាងលើ ត្រូវមានការគ្រប់គ្រងដីស្រែក្នុងឃុំ ឱ្យបានច្បាស់លាស់ដោយរាល់ការសម្រេចចិត្តប្តូរមុខងារប្រើប្រាស់ដីពីកសិកម្មទៅបម្រើឱ្យការសាងសង់ និងបម្រើឱ្យការប្រើប្រាស់ផ្សេងទៀតត្រូវតែមានការចូលរួមពីប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ប្រកបដោយតម្លាភាព ដោយអនុលោមតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងត្រូវមានការផ្សព្វផ្សាយជាចំហ ។ ម្យ៉ាងទៀតដីស្រែប្រាំងនៅក្នុងឃុំសំព្រោជបច្ចុប្បន្ន បានរកឃើញថាមានផ្ទៃដីទំហំ ៣៥០ ហិកតា ស្ថិតនៅក្នុងតំបន់៣ដែលជាដែនការពារព្រៃលិចទឹក ប្រសិនបើមិនមានការអនុញ្ញាតពីរដ្ឋាភិបាល ឱ្យប្រជាពលរដ្ឋបន្តកាន់កាប់អាស្រ័យផលនៅពេលអនាគតតាមរយៈការស្នើរសុំពីអាជ្ញធរដែនដីទេនោះ នឹងត្រូវរក្សាទុកជាដីព្រៃលិចទឹកវិញ នឹងនាំឱ្យទំហំផ្ទៃដីស្រែប្រាំងមានការថយចុះ ។ ទន្ទឹមនឹងការគ្រប់គ្រងដីស្រែ ត្រូវគិតគូរពីទឹកស្រោចស្រពដំណាំស្រូវ ដោយធ្វើយ៉ាងណាអាចធ្វើស្រែបង្កើនរដូវ និងស្រែប្រាំងឱ្យបានបីដងក្នុងមួយឆ្នាំ តាមរយៈការស្តារប្រព័ន្ធប្រឡាយចាស់ៗ ដែលមានស្រាប់អាចនាំទឹកទៅស្រោចស្រពដីស្រែបានគ្រប់គ្រាន់ ដើម្បីអាចផ្តល់ទឹកមកតាមប្រព័ន្ធប្រឡាយទាំងនោះផងដែរ ។ បន្ទាប់ពីកត្តាដី និងទឹកនៅមានកត្តាបច្ចេកទេសដាំដុះថែមទៀត ដោយត្រូវគិតគូរជំរុញការធ្វើស្រែបែបប្រពលវប្បកម្មទំនើបដូចមានលើកឡើងតាមការវិភាគក្នុងជំពូកទី២ ត្រង់ចំណុចការផ្តល់ឱកាសដោយបច្ចេកវិទ្យាទំនើប ដែលកត្តានេះនឹងលើកទឹកចិត្តឱ្យយុវជនចូលរួមក្នុងការងារកសិកម្មបានច្រើនផងដែរ ពីព្រោះយុវជនតែងគិតថាការធ្វើស្រែ នាំឱ្យមានការនឿយហត់ប្រឡាក់ប្រឡូកដីភក់ មិនស្អាតបាត ដែលជាការយល់ខុស គឺតាមពិតការធ្វើស្រែតាមបែបប្រពលវប្បកម្មទំនើបកសិករក៏អាចពាក់ក្រវ៉ាត់កប្រើប្រាស់កុំព្យូទ័រក្នុងបន្ទប់ម៉ាស៊ីនត្រជាក់បានដូចគ្នា ។ ក្នុងការគ្រប់គ្រងប្រព័ន្ធកសិកម្មនៅឃុំសំព្រោជមិនមែនយកចិត្តទុកដាក់ តែនៅលើការជំរុញផលិតកម្មកសិកម្មដូចខាងលើប៉ុណ្ណោះទេ តែត្រូវខិតខំពង្រឹងការប្រមូលគ្នាចងក្រងជាសហគមន៍ កសិករដើម្បីជ្រើសរើសតំណាងអាចទៅចូលរួមតស៊ូមតិក្នុងការចចារកទីផ្សារក៏ដូចជាមួយឈ្មួញ ដោយធានាការធ្វើ ស្រែបានផលស្រូវមានគុណភាពតាមស្តង់ដាតម្រូវទីផ្សារ និងធានាលំនឹងតម្លៃក្នុងទីផ្សារផងដែរ ។

តាមការគណនា ដែលផ្អែកទៅលើការការគិតគូរនៅក្នុងជំពូក២ ត្រង់ចំណុច ១.២.៣ អាចឱ្យយើងរំពឹងទុកអំពីបរិមាណផលស្រូវនាំចេញនាពេលអនាគតក្នុងអំឡុងពេល១៥ឆ្នាំខាងមុខដូចខាងក្រោមៈ

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ប្រជាពលរដ្ឋកើនឡើងដល់ ១៤ ៨៥៩នាក់

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ដីស្រែមានទំហំ ៩ ៧៣៧,១២ហិកតា

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំណត់ទិន្នផលស្រូវជាមធ្យម ៤ តោនក្នុង១ហិកតា

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំណត់ធ្វើស្រែបាន៣ដងក្នុង១ឆ្នាំ

-ដូច្នេះក្នុងអំឡុងពេល១៥ឆ្នាំ(២០១៧-២០៣១) ផលិតផលស្រូវទទួលបានក្នុង១ឆ្នាំជាមធ្យមៈ

៩ ៧៣៧,១២ហិកតា x ៤តោន/ហិតា x៣ដង/ឆ្នាំ = ១១៦ ៨៤៥,៤៤តោន/ឆ្នាំ

ប្រជាពលរដ្ឋ១នាក់ ត្រូវការអង្ករសម្រាប់ហូបក្នុងមួយឆ្នាំមានចំនួន១៤៣គីឡូក្រាម ដែលបើគិតជាស្រូវត្រូវការចំនួន២២៤ គីឡូក្រាម (ផ្អែកតាមរបាយការណ៍ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ)។

- ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខត្រូវការបរិមាណស្រូវសម្រាប់ផ្គត់ផ្គង់ការហូបចុកក្នុងមួយឆ្នាំជាមធ្យម

១៤ ៨៥៩នាក់ x២២៤ គីឡូក្រាម = ៣ ៣២៨ ៤១៦គីឡូក្រាម/ឆ្នាំ

ស្មើនឹងប្រហាក់ប្រហែល ៣ ៣២៨,៤២តោន/ឆ្នាំ

- ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខត្រូវការបរិមាណពូជស្រូវក្នុងមួយឆ្នាំជាមធ្យមៈ

៩ ៧៣៧,១២ហិតាx ៣០០គីឡូក្រាម x ៣ដង/ឆ្នាំ= ៨ ៧៦៣ ៤០៨គីឡូក្រាម/ឆ្នាំ

ស្មើនឹងប្រហាក់ប្រហែល ៨ ៧៦៣,៤១តោន/ឆ្នាំ

- ដូច្នេះក្នុងអំឡុងពេល ១៥ ឆ្នាំ ផលិតផលស្រូវទទួលបានសម្រាប់ការនាំចេញក្នុងមួយឆ្នាំជាមធ្យមៈ **១១៦ ៨៤៥,៤៤តោន/ឆ្នាំ-(៣ ៣២៨,៤២តោន/ឆ្នាំ+៨ ៧៦៣,៤១តោន/ឆ្នាំ)= ១០៤ ៧៥៣,៦១តោន/ឆ្នាំ**

- តែបើគិតជាអង្ករវិញអាចនាំចេញបានក្នុងមួយឆ្នាំជាមធ្យមៈ

១០៤ ៧៥៣,៦១តោន/ឆ្នាំ x ៦០%= ៦២ ៨៥២,១៦ តោន/ឆ្នាំ

ខ. ការគ្រប់គ្រងព្រៃឈើ ជលផល និង ធនធានសំខាន់ៗផ្សេងៗទៀត

ដោយឡែកធនធានព្រៃឈើវិញ យើងបានរកឃើញថា នៅក្នុងឃុំសំព្រោជមានតែព្រៃគម្ពោតនិងព្រៃលិចទឹកប៉ុណ្ណោះ ហើយក៏មិនមានដីសម្រាប់ដាំដើមឈើដែរ ប៉ុន្តែអាចធ្វើការដាំដើមឈើនៅតាមដងផ្លូវ នៅតាមប្រឡាយទឹក ទីធ្លាសាលាឃុំ ទីធ្លាសាលារៀន ទីធ្លាមណ្ឌលសុខភាព ទីធ្លាវត្តអារាម និងនៅតាមលំនៅឋានជាដើម ដើម្បីឱ្យមានដើមឈើពណ៌បៃតងនៅពាសពេញទូទាំងឃុំ ដើម្បីបម្រើផលប្រយោជន៍ដូចបានលើកឡើងនៅក្នុងជំពូកទី២ នៃរបាយការណ៍នេះ ហើយត្រូវបន្តថែទាំដើមឈើទាំងនោះឱ្យបាននៅគង់វង្ស និងលូតលាស់បានល្អ។

ដោយឡែកមច្ឆាជាតិដែលជាធនធានជលផល នៅក្នុងឃុំសំព្រោជបានកំណត់ ស្ទឹងស្ទោង បឹង អាងស្តុក ប្រឡាយទឹក និងក្នុងស្រែដែលអាចឱ្យប្រជាពលរដ្ឋក្នុងឃុំអាចទទួលផលជាលក្ខណៈគ្រួសារបានតិចតួចតែប៉ុណ្ណោះ។ តែទៅថ្ងៃអនាគតក៏ត្រូវខិតខំយកចិត្តទុកដាក់ក្នុងការចិញ្ចឹមត្រីថែមទៀត ដើម្បីបានផលគ្រប់គ្រាន់ផ្តល់ជាប្រភពប្រូតេអ៊ីនសាច់ដ៏សំខាន់សម្រាប់ប្រជាពលរដ្ឋក្នុងឃុំសំព្រោជ ។ ហើយចំពោះស្ថានភាពសមស្របក្នុងឃុំគួរចិញ្ចឹមត្រីតាមបែបចិញ្ចឹមក្នុងស្រះខ្នាតតូច ស្រះចិញ្ចឹមត្រីតាមគ្រួសារ និងកសិដ្ឋានចិញ្ចឹមត្រីក្នុងស្រែដែលជាទម្រង់មួយនៃការបង្កើនបរិមាណត្រី ដោយអាចបង្កើនផលិតភាពជលផលតាមប្រពលវប្បកម្ម(តាមវាលស្រែ) ហើយមានប្រយោជន៍ក្នុងការប្រើត្រីសម្រាប់ទប់ទល់សត្វល្អិតនិងដង្កូវហ្វូងក្នុងស្រែ ដែលបំផ្លាញផលដំណាំដូចដែលបានលើកឡើងជាអនុសាសន៍ក្នុងជំពូកទី២នៃរបាយការណ៍នេះផងដែរ ។ ចំណែកធនធានសំខាន់ៗផ្សេងទៀតលើសពីការរៀបរាប់ខាងលើនេះ ពុំមានឃើញគួរកត់សម្គាល់ឡើយ ។

៣.៤.២. គម្រោងគាំទ្រចាំបាច់ សម្រាប់គាំទ្រនិរន្តរភាព

ដើម្បីមានមធ្យោបាយអាចធ្វើឱ្យសម្រេចបាននូវការគ្រប់គ្រងប្រព័ន្ធកសិកម្មនិងធនធានសំខាន់ៗ សម្រាប់ការគាំទ្រដល់និរន្តរភាពនៃការអភិវឌ្ឍន៍ និងអភិរក្ស ដីធ្លីនិងធនធានធម្មជាតិក្នុងឃុំសំព្រោជចាំបាច់ត្រូវបង្កើតឱ្យមានគម្រោងគាំទ្រជាអាទិភាពមួយចំនួនដូចខាងក្រោមៈ

- ជួសជុល និងស្តារប្រព័ន្ធធារាសាស្ត្រ
- ជួសជុល និងថែទាំផ្លូវថ្នល់
- កសាងផ្លូវក្រាលកៅស៊ូ
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម
- បណ្តុះបណ្តាលផលិតជីកំប៉ុស្ត
- បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី
- បណ្តុះបណ្តាលពីការដាំដំណាំស្រូវ

- តបណ្ដាញទឹកស្អាតអោយបានដល់គ្រប់ភូមិ
- តបណ្ដាញអគ្គិសនីអោយបានដល់គ្រប់ភូមិ
- បង្កើតទីលានចាក់សំរាម
- បង្កើតសហគមន៍កសិករ ដើម្បីជំរុញការអនុវត្តន៍ភូមិ១ ផលិតផល១
- ដាក់លូបង្ហូរទឹកតាមមុខផ្ទះនៅជាប់ផ្លូវ
- ដោះស្រាយដីសម្បទានសង្គមកិច្ច
- ជំរុញធ្វើប័ណ្ណក្រីក្រឱ្យដល់ស្ត្រីគ្រប់រូប
- ផ្ដល់អាហារូបត្ថម្ភដល់ស្ត្រី និងកុមារ
- ផ្សព្វផ្សាយពីការចាក់វ៉ាក់សាំងការពារជម្ងឺដល់ស្ត្រីមានផ្ទៃពោះ និងកុមារ
- ពង្រឹងសេវាថែទាំសុខភាព និងព្យាបាលជម្ងឺជូនដល់ប្រជាពលរដ្ឋឱ្យបានល្អប្រសើរឡើង
- ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ
- ផ្សព្វផ្សាយពីច្បាប់ភូមិបាល និងច្បាប់បទដ្ឋានគតិយុត្តនានា ជូនដល់ប្រជាពលរដ្ឋ

៣.៥. សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់២០៣២)

ផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជក្នុងឆ្នាំ ២០១៧ នេះបានឱ្យដឹងថា ឃុំសំព្រោជ ជាឃុំមួយក្នុងចំណោមឃុំ ១៣ របស់ស្រុកស្ទោង ខេត្តកំពង់ធំ មានភូមិចំនួន១៧និងមានផ្ទៃដីសរុបចំនួន ២២ ៣៧៤ហិកតា។ ក្នុងឆ្នាំ២០១៧ ឃុំសំព្រោជ មាន ២ ៨០៨គ្រួសារ និងមានប្រជាជនសរុប ១៣ ៦២៩នាក់ ក្នុងនោះស្ត្រី៦ ៨៦៥នាក់ ហើយមានដង់ស៊ីតេប្រជាជន មធ្យម៦១នាក់/គ.ម^{២}។ ឃុំសំព្រោជ មានសណ្ឋានភាពដីជាវាលទំនាប ហើយជាប្រភេទដីល្បាយខ្សាច់ពណ៌ក្រហម និងក្រម៉ៅ(ដីប្រទះឡាង បាកាន) ដីកណ្ដេងពណ៌ខ្មៅ ក្រហមប្រផេះ(បាកាន ក្បាលពោធិ៍ ក្រគរ) ត្រូវបានប្រើប្រាស់ជាដីស្រែវស្សា ស្រូវប្រាំង និងដំណាំ ដែលបានផ្ដល់នូវមុខរបរសំខាន់ដល់ប្រជាពលរដ្ឋភាគច្រើនរហូតដល់ប្រមាណ៩៥,៦ភាគរយ សេវាកម្ម ១៨ភាគរយ និងសិប្បកម្ម០,២ភាគរយ ។

ទន្ទឹមនេះឃុំសំព្រោជ មានប្រភពទឹកសំខាន់ៗដូចជាៈ ទឹកពីប្រភពទឹកភ្លៀង ទឹកប្រឡាយ៣០កញ្ញា បឹង ត្រពាំង និងអាងទឹក ទឹកទន្លេសាប និងមានប្រឡាយចំនួន២៤ខ្សែ ដែលនៅក្នុងនោះប្រឡាយមេមានចំនួន ៣ខ្សែ ប្រវែង៧៦៧៤,២០ម៉ែត្រ ប្រឡាយរងចំនួន១ខ្សែ ប្រវែង៤ ០៨៤,៧៣ម៉ែត្រ ប្រឡាយតូចៗចំនួន ២០ខ្សែ ប្រវែង៤១ ០១៨,១៨ម៉ែត្រ ។ ឃុំសំព្រោជមានផ្លូវ អាចភ្ជាប់ទំនាក់ទំនងពីភូមិមួយទៅភូមិមួយក្នុងឃុំ និងអាចភ្ជាប់ទំនាក់ទំនងទៅឃុំ និងស្រុកផ្សេង រួមទាំងទីរួមស្រុកស្ទោងបានដោយងាយស្រួល ។ ចំពោះកំណើនប្រជាជនវិញ បានរកឃើញថា ក្នុងរយៈពេល១៥ឆ្នាំទៅមុខរហូតដល់ឆ្នាំ២០៣២ នឹងមានប្រជាជនកើនឡើងរហូតដល់ ១៤ ៨៥៩នាក់ ដែលនឹងត្រូវយកចិត្តទុកដាក់គិតគូររកដំណោះស្រាយអំពីការប្រើប្រាស់ដី ដើម្បីឆ្លើយតបបានទៅនឹងតម្រូវការរបស់ប្រជាជន ។ ទន្ទឹមនេះ ក៏បានរកឃើញអំពីបញ្ហាប្រឈមមួយចំនួនទៅលើសកម្មភាពនៃការអភិវឌ្ឍន៍ឃុំសំព្រោជបច្ចុប្បន្នផងដែរ ដូចជាការធ្វើស្រែដែលមានសក្ដានុពលក្នុងការអភិវឌ្ឍន៍ឃុំ មិនទាន់ទទួលបានផលស្រូវសមស្របអស់លទ្ធភាពនៅឡើយ ដោយសារដីស្រែទាំងនេះកាន់តែខ្សត់ជីជាតិ ខ្វះទឹកស្រោចស្រព សម្រាប់ផ្គត់ផ្គង់ដល់ការធ្វើស្រែបង្កើនរដូវ ខ្វះចំណេះដឹងពីបច្ចេកទេសនៃការដាំដុះ ខ្វះចំណេះដឹងពីបច្ចេកទេសការប្រើប្រាស់ជីគីមី និងថ្នាំពុលកសិកម្មប្រព័ន្ធប្រឡាយដែលមានស្រាប់បានរាក់ ខ្វះកម្លាំងពលកម្មដោយសារចំណាក

ស្រុកច្រើនគឺបាត់កម្លាំងពលកម្មជិតពាក់កណ្ដាលនៃកម្លាំងពលកម្មដែលមាន និងតម្លៃកសិផលមិនមានស្ថិរភាព ដោយឈ្មួញជាអ្នកកំណត់តម្លៃ។ល។ ទន្ទឹមការរកឃើញបញ្ហាមួយចំនួនលើសកម្មភាពអភិវឌ្ឍឃុំ ក៏បានរកឃើញថា ជាទូទៅការប្រើប្រាស់ដីនៅក្នុងឃុំបច្ចុប្បន្នបានចំទិសដៅនិងមានភាពសមស្រប ដូចជាការប្រើប្រាស់ដីសម្រាប់លំនៅឋាន កសិកម្ម ប្រព័ន្ធផ្លូវគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រជាដើម ដែលទៅថ្ងៃអនាគ ក៏នៅតែរក្សាមុខងារប្រើប្រាស់ដីទាំងនោះឱ្យនៅដដែល ។ បន្ថែមពីលើនេះ ក៏បានរកឃើញវិធីដោះស្រាយបញ្ហាផ្សេងៗទៀតផងដែរសម្រាប់អនាគត ដូចជាត្រូវសាងសង់បន្ទប់រៀនបន្ថែម ពង្រឹងការផ្ដល់សេវាសុខាភិបាលឱ្យបានប្រសើរឡើង ជំរុញឱ្យប្រជាពលរដ្ឋហូបទឹកស្អាតនិងប្រើប្រាស់បង្គន់អនាម័យ ជួសជុលផ្លូវ ស្ពានប្រឡាយទឹក ដាំដើមឈើនៅតាមទីសាធារណៈ ជំរុញការចិញ្ចឹមត្រីតាមស្រែ។ល។ ជាពិសេសការដោះស្រាយដីសម្រាប់លំនៅឋានក្នុងភូមិ ដែលមានស្រាប់ ដែលបច្ចុប្បន្ននៅទូលាយអាចផ្គត់ផ្គង់ការសាងសង់លំនៅឋានបាន ។ ដើម្បីដោះស្រាយទៅនឹងកំណើនប្រជាជន ត្រូវពង្រឹងការធ្វើស្រែឱ្យបាន ៣ដងក្នុងមួយឆ្នាំ និងធ្វើស្រែតាមបែបប្រពលវប្បកម្ម ដើម្បីបង្កើនទិន្នផលស្រូវឱ្យបានខ្ពស់អស់សក្ដានុពល សម្រាប់ផ្គត់ផ្គង់ការហូបចុក និងអាចមានលទ្ធភាពនាំស្រូវចេញបានចំនួន១០៤ ៨៥៣,៦១តោន/ឆ្នាំ ដើម្បីជួយផ្គត់ផ្គង់ដល់ជីវភាពរបស់ប្រជាពលរដ្ឋក្នុងឃុំឱ្យបានកាន់តែប្រសើរឡើង ស្របទៅនឹងកំណើនប្រជាពលរដ្ឋ ព្រមទាំងជួយជំរុញកំណើនសេដ្ឋកិច្ចក្នុងឃុំ ។ ការរកឃើញភាពសមស្រប និងជម្រើសនៃការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជនាពេលអនាគត បានមកពីការវាយតម្លៃដ៏ត្រឹមត្រូវដោយផ្អែកលើធនធានដី រយៈកម្ពស់ ទីជម្រាល ធនធានទឹក ការកាន់កាប់ដី និងសក្ដានុពលនៃការប្រើប្រាស់ដីនៅក្នុងឃុំនេះ ដើម្បីធានាថាការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជទៅអនាគតប្រកបដោយចីរភាព និងសមធម៌ ។

ដូច្នេះដើម្បីសម្រេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជ ស្របតាមស្ថានភាពដីជាក់ស្ដែងនិងសក្ដានុពលនៃធម្មជាតិ សម្រាប់ការគាំទ្រកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមប្រកបដោយចីរភាព និងសមធម៌ រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋនាពេលអនាគត ដូចបានរកឃើញមានចែងលម្អិតនៅក្នុងរបាយការណ៍បច្ចេកទេសនេះ រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធជាពិសេសក្រុមប្រឹក្សាឃុំ ដែលជាតំណាងប្រជាពលរដ្ឋនៅក្នុងឃុំសំព្រោជ ហើយមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំ ត្រូវខិតខំអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជ ដែលបានអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការរួច ដោយបញ្ជៀបទៅនិងផែនការអភិវឌ្ឍន៍ឃុំ ឱ្យបានប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត ដើម្បីធានាភាពជោគជ័យនៃផែនការនេះ ៕

លេខ:.....834/20.................

បានពិនិត្យ និង សូមគោរពជូន

លោកអភិបាលនៃគណៈអភិបាលស្រុក និង ជាប្រធានគណៈកម្មាធិការ

រៀបចំដែនដី និងនគរូបនីយកម្មស្រុកស្ពោង មេត្តាពិនិត្យ និង សម្រេច។

ថ្ងៃ.....ចន្ទ ១៤កើត.....ខែ ស្រាពណ៍ ឆ្នាំ .....ជូត ទោស័ក......ព.ស. ២៥៦៤

សំព្រោជ ថ្ងៃទី.....០៣.....ខែ......សីហា.....ឆ្នាំ២០២០

មេឃុំសំព្រោជ

ពារញ [illegible]

លេខ÷.....០២៥/២០...................

បានពិនិត្យ និង សូមគោរពជូន

ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និង ជាប្រធានគណៈកម្មាធិការ

រៀបចំដែនដី និង នគរូបនីយកម្មខេត្តកំពង់ធំ មេត្តាពិនិត្យ និង សម្រេចដ៏ខ្ពង់ខ្ពស់ ។

ថ្ងៃ.....ចន្ទ ៦រោច...........ខែ ស្រាពណ៍ ឆ្នាំ.....ជូត ទោស័ក...........ព.ស. ២៥៦៤

ស្ពោង ថ្ងៃទី.......១០...............ខែ.....សីហា.....ឆ្នាំ ២០២០

អភិបាលនៃគណៈអភិបាលស្រុក និង ជាប្រធាន

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកស្ពោង

ណែត សារី

លេខៈ ៥៤៨៧/២០២១

បានឃើញ និងឯកភាពសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ

ថ្ងៃ ព្រហស្បតិ៍ ៣ កើត ខែ ភទ្របទ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

កំពង់ធំ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០២១

អភិបាលនៃគណៈអភិបាលខេត្ត និងជា

ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ

ស៊ុខ_លុ

ឯកសារឧបសម្ព័ន្ធ

ផែនទីហេដ្ឋារចនាសម្ព័ន្ធ ឃុំសំព្រោជ



ផែនទីប្រព័ន្ធធារាសាស្ត្រ ឃុំសំព្រោជ



ផែនទីប្រើប្រាស់ដីសាមញ្ញ ឃុំសំព្រោជ



សញ្ញាសម្គាល់

ព្រំប្រទល់ និងទីតាំងរដ្ឋបាល

- សាលាឃុំ
- ភូមិ
- ព្រំប្រទល់រដ្ឋបាលឃុំ

ហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន

- មន្ទីរពេទ្យ មណ្ឌលសុខភាព
- សាលារៀន
- វត្ត
- ស្ពាន
- ទ្វារទឹក
- ផ្លូវជាតិលេខ ៦
- ផ្លូវគ្រួសក្រហម ឬក្រាលថ្ម
- ផ្លូវដីស ឬផ្លូវរទេះ
- ប្រឡាយមេ
- ប្រឡាយរង
- ប្រឡាយតូច

ប្រភេទប្រើប្រាស់ដីបច្ចុប្បន្ន

- ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ
- ដីកសិកម្ម
- ដីព្រៃ/គម្របព្រៃ
- ផ្ទៃទឹក និងខ្សែទឹក

ប្រព័ន្ធភូគោល

ចំណោលផែនទី	:	UTM
តំបន់ទី	:	48N
ទិន្នន័យយោង	:	WGS 1984
អេលីបសូអ៊ីត	:	WGS 1984

ប្រភពទិន្នន័យ

-ទីតាំងវិនិយោគ ប្រភពពីផែនការអភិវឌ្ឍឃុំរយៈពេល៥ឆ្នាំនិងអាជ្ញាធរមូលដ្ឋាន
-ទិន្នន័យទីតាំង និងព្រំប្រទល់រដ្ឋបាលប្រភពពីនាយកដ្ឋានភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគូរូបនីយកម្ម និងសំណង់ (២០១៩)
-ទិន្នន័យសំខាន់ៗផ្សេងទៀត ប្រភពពីមន្ទីរ/ស្ថាប័នពាក់ព័ន្ធជុំវិញខេត្ត

បញ្ជាក់

-ព័ត៌មានដែលបង្ហាញនៅលើផែនទីនេះ គឺផ្អែកលើទិន្នន័យដែលបានបង្កើតឡើងដោយថ្នាក់ជាតិនិងត្រូវបានកែសម្រួលដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន
-ព្រំប្រទល់រដ្ឋបាលទាំងនោះ មិនអាចចាត់ទុកជាផ្លូវការ និងខ្សែបន្ទាត់ព្រំដែននៃផែនទីនេះ ពុំមានតម្លៃជាផ្លូវការអន្តរជាតិឡើយ
-ផែនទីនេះត្រូវបានបោះពុម្ពនៅ ខែ.................................. ឆ្នាំ២០.......

ផែនទីគម្រោងវិនិយោគ ឃុំសំព្រោជ



សញ្ញាសម្គាល់

ព្រំប្រទល់ និងទីតាំងរដ្ឋបាល
- សាលាឃុំ
- ភូមិ
- ព្រំប្រទល់រដ្ឋបាលឃុំ

ហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន
- មន្ទីរពេទ្យ មណ្ឌលសុខភាព
- សាលារៀន
- វត្ត
- ស្ពាន
- ទ្វារទឹក
- ផ្លូវជាតិលេខ ៦
- ផ្លូវគ្រួសក្រហម ឬក្រាលថ្ម
- ផ្លូវដីស ឬផ្លូវរទេះ
- ប្រឡាយមេ
- ប្រឡាយរង
- ប្រឡាយតូច

ប្រភេទប្រើប្រាស់ដីបច្ចុប្បន្ន
- ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ
- ដីកសិកម្ម
- ដីព្រៃ/គម្របព្រៃ
- ផ្ទៃទឹក និងខ្សែទឹក

គម្រោងវិនិយោគ
- សាងសង់ទ្វារទឹក
- កសាងផ្លូវចាក់កៅស៊ូ
- កសាងផ្លូវគ្រួសក្រហម ឬក្រាលថ្ម
- ជួសជុលផ្លូវគ្រួសក្រហម ឬក្រាលថ្ម
- ស្ពានប្រឡាយតូច

ប្រព័ន្ធភូមិសាស្ត្រ

ចំណោលផែនទី	:	UTM
តំបន់ទី	:	48N
ទិន្នន័យយោង	:	WGS 1984
អេលីបសូអ៊ីត	:	WGS 1984

ប្រភពទិន្នន័យ

-ទីតាំងវិនិយោគ ប្រភពពីផែនការអភិវឌ្ឍឃុំរយៈពេល៥ឆ្នាំនិងអាជ្ញាធរមូលដ្ឋាន
-ទិន្នន័យទីតាំង និងព្រំប្រទល់រដ្ឋបាលប្រភពពីនាយកដ្ឋានភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (២០១៩)
-ទិន្នន័យសំខាន់ៗផ្សេងទៀត ប្រភពពីមន្ទីរ/ស្ថាប័នពាក់ព័ន្ធថ្នាក់ខេត្ត

បញ្ជាក់

-ព័ត៌មានដែលបង្ហាញនៅលើផែនទីនេះ គឺផ្អែកលើទិន្នន័យដែលបានបង្កើតឡើងដោយថ្នាក់ជាតិនិងត្រូវបានកែសម្រួលដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន
-ព្រំប្រទល់រដ្ឋបាលទាំងនោះ មិនអាចចាត់ទុកជាផ្លូវការ និងខ្សែបន្ទាត់ព្រំដែននៃផែនទីនេះ ពុំមានតម្លៃជាផ្លូវការអន្តរជាតិឡើយ
-ផែនទីនេះត្រូវបានបោះពុម្ពនៅ ខែ.................................. ឆ្នាំ២០.......

ឯកសារឧបសម្ព័ន្ធ

សកម្មភាពក្រុមការងារចូលរួមប្រជុំទទួលការណែនាំពីនីតិវិធីរៀបចំផែនការប្រើប្រាស់ដីថ្នាក់ឃុំ ពីប្រធានគ្រប់គ្រងគម្រោងរបស់ក្រុមហ៊ុន

សកម្មភាពប្រមូលទិន្នន័យនៅតាមមន្ទីរជុំវិញខេត្តរបស់ក្រុមការងារក្រុមហ៊ុន SBK

កិច្ចប្រជុំពិភាក្សាអំពីផែនទីប្រើប្រាស់ដីបច្ចុប្បន្នឃុំសំព្រោជ

សកម្មភាពក្រុមការងារចុះទីវាលស្រង់ទិន្នន័យបំពេញបន្ថែមលើ
ផែនទីប្រើប្រាស់ដីបច្ចុប្បន្នដែលមានស្រាប់នៅក្នុងឃុំសំព្រោជ

សកម្មភាពចូលរួមត្រួតពិនិត្យ ណែនាំ ការអនុវត្តគម្រោងរបស់អង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ (NIO)

កិច្ចប្រជុំក្រុមប្រឹក្សាឃុំសំព្រោជ ដើម្បីពិនិត្យ និងឯកភាពទៅលើ
សេចក្ដីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជ

កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកស្ទោង ដើម្បីពិនិត្យ និងឯកភាពទៅលើ សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជ

កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ ដើម្បីពិនិត្យ និងឯកភាពទៅលើ សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលស្រុកស្ទោង
ក្រុមប្រឹក្សាឃុំសំព្រោជ

ថ្ងៃ...........ខែ..........ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
...........ថ្ងៃទី...១៤....ខែ...តុលា....ឆ្នាំ២០២០...

សេចក្តីជូនដំណឹង

ស្តីពីការបិទផ្សាយជាសាធារណៈផែនការប្រើប្រាស់ដីអនាគតឃុំសំព្រោជ

យោង: - កិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រត្តិបត្តិការចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

- កិច្ចសន្យាលេខ CON-LUP/RICE-SDP/CLUP/MUMUPC/CS/ ០១ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៧ រវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយក្រុមហ៊ុន SBK Research & Development Co.,Ltd។
- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។
- តម្រូវការចាំបាច់នៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។

ន័យដូចបានជម្រាបជូនក្នុងសេចក្តីយោងខាងលើ និងស្របតាមការរៀបចំផែនការប្រើប្រាស់ដី និងលទ្ធផលការងារដែលសម្រេចបានទៅតាមនីតិវិធីនាពេលកន្លងមកក្រុមប្រឹក្សាឃុំសំព្រោជ ស្រុកស្ទោង ខេត្តកំពង់ធំ សូមគោរពជម្រាបជូនដល់គ្រប់ស្ថាប័ន អង្គការសង្គមស៊ីវិល ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់មេត្តាជ្រាបថា៖ នៅថ្ងៃទី...១៤....ខែ...តុលា....ឆ្នាំ២០២០... ដល់ថ្ងៃទី...២៧...ខែ...វិច្ឆិកា...ឆ្នាំ២០២០...ឃុំសំព្រោជធ្វើការរៀបចំបិទផ្សាយជាសាធារណៈនូវឯកសារ និងផែនការប្រើប្រាស់ដីអនាគតដែលសម្រេចបាន នៅទីតាំងសាលាឃុំខាងលើ ដើម្បីធ្វើការពិនិត្យ កែសម្រួល និងផ្តល់យោបល់។

អាស្រ័យហេតុនេះ សូមបងប្អូនប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ មេត្តាជួយផ្សព្វផ្សាយ និងចូលរួមពិនិត្យផ្តល់យោបល់អោយបានកុះករ កុំបីអាក់ខានឡើយ ។

សូមបងប្អូនជនរួមជាតិ មេត្តាទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ ។

ប្រធានក្រុមប្រឹក្សាឃុំ និងជា
មេឃុំសំព្រោជ

ពាញ្ញ.ពូល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលស្រុកស្ទោង
ក្រុមប្រឹក្សាឃុំ សំព្រោជ

របាយការណ៍ការបូកសរុប
លទ្ធផល នៃការបិទផ្សាយជាសាធារណៈ នូវឯកសារផែនទី និង
សៀវភៅផែនការប្រើប្រាស់ដីនៅក្នុងឃុំ សំព្រោជ

យោង: - កិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១៣ រវាង រាជរដ្ឋាភិបាលកម្ពុជា និង ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

- កិច្ចសន្យាលេខ CON-LUP/RICE-SDP/CLUP/MUMUPC/CS/ ០១ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០១៧ រវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយក្រុមហ៊ុន SBK Research & Development Co.,Ltd។
- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។
- ក្រុមប្រឹក្សាឃុំសំព្រោជ បានបិទផ្សាយជាសាធារណៈនៅទីតាំង សាលាឃុំសំព្រោជ នូវឯកសារផែនទីនិងសៀវភៅពង្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជ (បានប្រជុំអនុម័តថ្នាក់ស្រុកស្ទោងរួចរាល់ជាស្ថាពរ) ចាប់ពីថ្ងៃទី.១៤..ខែ..តុលា...ឆ្នាំ ២០២០ ដល់ថ្ងៃទី.២៧..ខែ.វិច្ឆិកា...ឆ្នាំ ២០២០ មានរយៈពេល ៤៥ ថ្ងៃជាលទ្ធផលមានដូចខាងក្រោម៖

១. ផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សំព្រោជ

- បានធ្វើការបិទផ្សាយផែនទីប្រើប្រាស់ដីលម្អិតបច្ចុប្បន្ន មានទំហំជាខ្នាត A0
- បានធ្វើការបិទផ្សាយផែនទីប្រើប្រាស់ដីអនាគតសម្រាប់រយៈពេល ១៥ឆ្នាំ ២០១៧ ដល់ ២០៣២ មានទំហំជាខ្នាត A0
- **ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន**

២. សៀវភៅផែនការប្រើប្រាស់ដីនៅក្នុងឃុំ សំព្រោជ

- ជំពូក ១ ៖ ព័ត៌មានស្តីពី ស្ថានភាពឃុំសំព្រោជ
  - ចាប់ពី ១.១. ស្ថានភាពទូទៅនៃឃុំ ១.១.១. ទីតាំងរដ្ឋបាលឃុំ រហូតដល់ ១.៤. ទីផ្សារ និង ខ្សែសង្វាក់ផលិតផល ១.៤.៣. ឧបសគ្គ និង ឱកាស។
  - **ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន**
- ជំពូក ២ ៖ ការវិភាគតម្រូវការ សក្តានុពល និង ឧបសគ្គសម្រាប់អនាគត
  - ចាប់ពី ២.១. តម្រូវការសម្រាប់អនាគត់ ២.១.១. ផែនការអភិវឌ្ឍន៍ឃុំ រហូតដល់ ២.៥. បញ្ហា មូលហេតុ និង ដំណោះស្រាយ។
  - **ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន**
- ជំពូក ៣ ៖ ផែនការប្រើប្រាស់ដីសម្រាប់ពេលអនាគត ឆ្នាំ២០១៧ ដល់ ២០៣២
  - ចាប់ពី ៣.១. តម្រូវការ ស្ថានភាព និង សក្តានុពលជាក់ស្តែង ៣.១.១. តម្រូវការដីទៅតាមប្រភេទ រហូតដល់ ៣.៥. សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់ ២០៣២)
  - **ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន**
- **ការវាយតម្លៃ** : ផ្អែកតាមឯកសារភស្តុតាង និងទិន្នន័យជាក់ស្តែង ដែលប្រមូលបាន លទ្ធផលនៃការបិទផ្សាយសាធារណៈនូវឯកសារ ផែនទី និង សៀវភៅពង្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សំព្រោជ សម្រាប់ឆ្នាំ ២០១៧ ដល់ ២០៣២ ជាយោបល់គួរដាក់ជូនគណៈកម្មាធិការរៀបចំដែនដី និង នគរូបនីយកម្មខេត្តកំពង់ធំ ដើម្បីពិនិត្យ និង សម្រេចដ៏ខ្ពង់ខ្ពស់។

ថ្ងៃ..........ខែ..........ឆ្នាំ..........ស័ក ព.ស. ២៥៦៤
សំព្រោជ ថ្ងៃទី...២៧....ខែ...វិច្ឆិកា..........ឆ្នាំ ២០២០

ប្រធានក្រុមប្រឹក្សាឃុំ និងជា
មេឃុំ សំព្រោជ

ពាញ្ញ.ពូល

សកម្មភាពផ្សព្វផ្សាយជាសាធារណៈសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំសំព្រោជ

ឯកសារយោង

ឯកសារយោង

១. ឯកសារព័ត៌មានស្ថានភាពឃុំសំព្រោជស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៣ របស់មន្ទីរផែនការខេត្ត
២. ឯកសារព័ត៌មានស្ថានភាពឃុំសំព្រោជស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៤ របស់មន្ទីរផែនការខេត្ត
៣. ឯកសារព័ត៌មានស្ថានភាពឃុំសំព្រោជស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៥ របស់មន្ទីរផែនការខេត្ត
៤. ឯកសារព័ត៌មានស្ថានភាពឃុំសំព្រោជស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៦ របស់មន្ទីរផែនការខេត្ត
៥. ឯកសារព័ត៌មានស្ថានភាពឃុំសំព្រោជស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៧ របស់មន្ទីរផែនការខេត្ត
៦. ផែនការអភិវឌ្ឍន៍ឃុំរយៈពេលប្រាំឆ្នាំ(២០១៨-២០២២)របស់ឃុំសំព្រោជ ស្រុកស្ទោង ខេត្តកំពង់ធំ
៧. ផែនការអភិវឌ្ឍន៍ស្រុករយៈពេលប្រាំឆ្នាំ(២០១៨-២០២២)របស់ស្រុកស្ទោង ខេត្តកំពង់ធំ
៨. កម្មវិធីវិនិយោគឃុំសំព្រោជ ឆ្នាំ២០១៧ របស់ឃុំសំព្រោជ ស្រុកស្ទោង ខេត្តកំពង់ធំ
៩. របាយការណ៍ស្តីពីការវិភាគប្រព័ន្ធគ្រ្សេត្រ-បរិស្ថាន ឃុំសំព្រោជ ស្រុកស្ទោង ខេត្តកំពង់ធំ ឆ្នាំ២០១៧
១០. អនុក្រឹត្យស្តីពីការកំណត់ដែនព្រៃលិចទឹក ៦៤៧,៤០៦ហិកតា ស្ថិតនៅក្នុងខេត្តទាំង៦ជុំវិញបឹងទន្លេសាប (កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប)
១១. អនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ៨៨.អនក្រ.បក ស្តីពីការបង្កើតតំបន់ការពារទេសភាពទំនាបខាងជើងទន្លេសាប ។